# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំទី ៣២ លេខ ១២ ខែធ្នូ

ព.ស. ២៥០៣ គ.ស. ១៩៦០

ភ្នំពេញ

# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយខាងសាសនា និងអក្សរសាស្ត្រ

ចេញរាល់ខែពីពុទ្ធសាសនបណ្ឌិត្យ

## បញ្ជីរឿង


*ផ្នែកសាសនា* — *ទំព័រ*

- ពុទ្ធជីវប្បវត្តិ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . . . ១៣២១
- ព្រះអភិធម្មបិដក គម្ពីរព្រះកថាវត្ថុ (តមក) លោក ប៊ូ-ប៉ូ រៀបរៀង . ១៣៣៥
- មធុរសវាហិណី (តមក) សម្ដេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង ព្រះញាណកោសល ញាណ-ឈឺន ពិនិត្យ . . . . ១៣៤៤
- មហោសថជាតក (តមក) លោក អ៊ឹម-ភន បម្លងពីសាស្ត្រាស្លឹករឹត ព្រះពុទ្ធវង្ស កឹម-តួរ ពិនិត្យ . . . . . . ១៣៥០

*ផ្នែកអក្សរសាស្ត្រ*

- រឿងមរណមាតា (តមក) លោក ប៊ី-សុវណ្ណ បម្លងពីសាស្ត្រាស្លឹករឹត . . ១៣៦១
- រឿងសាមកុក (តមក) ទកញ៉ា គួ-កន ប្រែ . . . . . ១៣៧០
- រឿងស្ដេចបាយស្ករ លោក ញ៉ែម-ទឹម រៀបរៀង . . . . . ១៣៨៦
- រឿងព្រេងប្រទេសវេណេហ្សុយអេឡា ភិក្ខុ ម៉ែន-វៀម រៀបរៀង . . . ១៣៩៧
- តួរជីងទំនៀមខ្លះនៅប្រទេសឥណ្ឌូណេស៊ី អ្នកស្រីពេជ-សល់ តាមដើមសារិះយ៉ាន់ ប្រែ ១៤០៦
- រឿងជ្រូកតបួកៈ លោក ហេង-សមអាន រៀបរៀង . . . ១៤១១

*ផ្នែកកំណត់ទំនីប្រវត្តិការណ៍*

- ពត៌មានរបស់ក្រសួងធម្មការ អំពីពិធីបុណ្យព្រហ្មទាន លោក វ៉ាយ-ប៊ុក រៀបរៀង ១៤២៤
- វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ប៉ាង-ខាត់ រៀបរៀង . ១៤៣៨



មួយឆ្នាំ មាន ១២ សៀវភៅ ដំឡៃជាវ ២៣០:០០

# KAMBUJASURIYA

Revue mensuelle de Culture religieuse et littéraire
publiée par l'Institut Bouddhique de Phnom-Penh


## sommaire

### Partie religieuse :


— La Vie du Buddha (suite) par Prah màha PANG-KHAT . 1321
— Prah Abhidhammapitaka( Kathavathu) (suite) par M. BOU-PO 1335
— Madhurasavahini (suite) traduit par Samdec Prah Dhamma-Likhita LOUIS-EM. revu et corrigé par le Vén. NHEAN-CHHOEUN . . . 1344
— Prah Mahosothajataka (suite) relevé du manuscrit sur feuilles de latanier par M. IM-PHON. revu par le Vén-KEM-TO 1350


### Partie littéraire :


— Légende de Marana Màtâ(suite) relevées du manuscrit sur feuilles de latanier par M. BY-SOVANN . . . . . . . 1361
— Histoire de Sam-Kok (suite) traduite par l'Oknha NOU-KAN. 1370
— Légende du Roi Bayanko par M. NHEM-KHEM . . . . 1386
— Contes et Légendes de Venezuela par le bonze MEN RIEM . 1397
— Quelques coutumes indonésiennes traduites par Mme PICH-SAL née SARIS-YANN . . . . . . . 1406
— Légende du porc Tacchaka (en poème) par M. HENG-SAM AN 1411


### Notes et Chroniques :


— Nouvelles du Ministère des Cultes La distribution des Prix aux bonzes par M. RAY-BUK . . . . . . 1424
— Dictionnaire Samscrit-khmer (suite) par Vén.PANG-KHAT . 1438



Prix d'abonnement annuel (comprenant 12 numéros): 230$00 .

# ផ្នែកសាសនា

## ពុទ្ធជីវប្រវត្តិ

(តមក)

ព្រះមហាប៉ាង - ខាត់ រៀបរៀង

### ៩- ទ្រង់ធ្វើទុក្ករកិរិយា

ព្រះបរមពោធិសត្វ កាលព្រះអង្គបានធ្វើវត្តប្រតិបត្តិរបស់និគ្រន្ថតិរ្ថិយ ទិនពួកគណាចារ្យទាំងឡាយ ដោយមានបំណងថាល្បងមើល ព្រោះគេសន្មតថាប្រសើរណាស់ក្នុងសម័យនោះ ទ្រង់ឃើញថាមិនជាប្រយោជន៍ដល់ការត្រាស់ដឹងរបស់ព្រះអង្គទេ ទើបទ្រង់លះបង់ចោលហើយចៀសចេញទៅ។ ថ្ងៃមួយទ្រង់នឹកដល់កាលដែលទ្រង់នៅជាព្រះរាជកុមារ គឺកាលស្តេចទៅទតពិធីច្រត់ព្រះនង្គ័លរបស់ព្រះបិតា ទ្រង់បានបំពេញអានាបានស្សតិកម្មដ្ឋាន ទើបទ្រង់តាំងព្រះទ័យធ្វើអានាបានស្សតិកម្មដ្ឋាន ប្រព្រឹត្តយ៉ាងតឹងរ៉ឹង តឹងរាល់តែដក គ្មានអ្នកណាមួយអាចធ្វើដូចបាន ម្ល៉ោះជាគេមានឈ្មោះប្រាកដថាទុក្ករកិរិយា គឺអំពើដ៏ក្រក្រៃដែលមិនអាចបុគ្គលណាមួយធ្វើបានងាយ ដូចពុទ្ធភាសិតដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារថា (១)

---

១- ពោធិរាជកុមារសូត្រ រាជវគ្គ, ម.ម- សៀវ ២៤, ទំព័រ ៣៧៥ ។

ភារៈទី ១- ម្នាលរាជកុមារ ! តថាគតត្រិះរិះថា "គួរតែអាត្មាអញខាំធ្មេញដោយធ្មេញ ទល់ពីតានដោយអណ្ដាតសង្កត់សង្កិនបៀតបៀន ដុតកំដៅចិត្តដោយចិត្ត, កាលតថាគតធ្វើដូច្នោះ ញើសក៏ហូរចេញតាមក្លៀកទាំងសងខាង ប្រៀបដូចជាបុរសដែលមានកំឡាំង ចាប់បុរសមានកំឡាំងខ្សោយជាងត្រង់ក្បាលឬក ហើយសង្កត់សង្កិនបៀតបៀនញាំញីយ៉ាងដូច្នោះដែរ ។ ម្នាលរាជកុមារ ! សេចក្ដីព្យាយាមដែលតថាគត បានប្រារព្ធហើយក៏មិនធូរថយ សតិដែលតថាគតបានដំកល់មាំមួនហើយក៏មិនរាយមាយ ប៉ុន្តែកាយរបស់តថាគត ក៏នៅតែក្រវល់ក្រវាយ មិនបានស្ងប់រម្ងាប់សោះ ព្រោះសេចក្ដីព្យាយាមដ៏លំបាកនោះ មកបណ្ដាលបាក់ដោត ។

ភារៈទី ២-ម្នាលរាជកុមារ ! តថាគតត្រិះរិះថា អាត្មាអញគួរតែសំឡឹងឈានមិនដកដង្ហើមជាអារម្មណ៍ គឺអត់ខ្យល់អស្សាស:បស្សាស:តាមមាត់តាមច្រមុះ កាលតថាគត ធ្វើដូច្នោះសំឡេងខ្យល់ដែលចេញតាមរន្ធត្រចៀកខ្លាំង លើសប្រមាណ

ប្រៀបដូចជាស្នប់របស់ជាងលោហជាតិ ដែលកំពុងសប់មានសំឡេងខ្លាំងដូច្នោះឯង ៗ ម្នាលរាជកុមារ ! សេចក្ដីព្យាយាមដែលតថាគតបានប្រារព្ធហើយមិនធូរបយ សតិដែលតថាគតដំកល់មាំហើយក៏មិនវាយមាយ ប៉ុន្តែកាយរបស់តថាគត ក៏នៅតែក្រវល់ក្រវាយ មិនទាន់ស្ងប់រម្ងាប់ ព្រោះសេចក្ដីព្យាយាមដ៏លំបាកនោះ មកបណ្ដាលបាក់ដោត ៗ

ភារៈទី ៣-ម្នាលរាជកុមារ ! តថាគតត្រិះរិះថា អាត្មាអញគួរសំឡឹងឈានមិនដកដង្ហើមជាអារម្មណ៍ទៀត,គឺអត់ខ្យល់អស្សាសបស្សាសៈតាមមាត់តាមច្រមុះនឹងតាមរន្ធត្រចៀក កាលតថាគតធ្វើដូច្នោះ ខ្យល់យ៉ាងខ្លាំងលើសប្រមាណក៏វិលមកបាក់ដោតត្រង់ក្បាល ប្រៀបដូចជាបុរសដែលមានកំឡាំង បោះក្បាលដោយដែកស្រួចយ៉ាងមុតដូច្នោះឯង ៗ ម្នាលរាជកុមារ ! សេចក្ដីព្យាយាម ដែលតថាគតបានប្រារព្ធហើយ ក៏មិនធូរបិយ សតីដែលតថាគតបានដំកល់មាំហើយ ក៏មិនវាយមាយ ប៉ុន្តែកាយរបស់តថាគត ក៏នៅតែក្រវល់ក្រវាយ មិនទាន់ស្ងប់រម្ងាប់

ព្រោះសេចក្ដីព្យាយាមដ៏លំបាកនោះ មកបណ្ដាលចាក់ដោត ។

វារៈទី៤—ម្នាលរាជកុមារ ! តថាគតត្រិះរិះថា អាត្មាអញគួរសំឡឹងឈាន មិនដកដង្ហើមជាអារម្មណ៍ទៀត គឺអត់ខ្យល់អស្សាសបស្សាសៈតាមមាត់តាមច្រមុះនិងតាមរន្ធត្រចៀក កាលណាតថាគតធ្វើដូច្នោះ វេទនាកើតក្នុងក្បាល ខ្លាំងលើសប្រមាណ ប្រៀបដូចជាបុរសមានកម្លាំង បង់ត្រឡែងស្អិតចំណងក្បាលព័ទ្ធក្បាល ដោយព្រ័ត្រដ៏មាំដូច្នោះឯង ។ ម្នាលរាជកុមារ ! ប៉ុន្តែសេចក្ដីព្យាយាមដែលតថាគតបានប្រារព្ធហើយ ក៏មិនធូរថយ សតិដែលតថាគតបានដំកល់មាំហើយ ក៏មិនរាយមាយ ទាំងកាយរបស់តថាគតក៏នៅតែក្រវល់ក្រវាយ មិនទាន់ស្ងប់រម្ងាប់ទៀត ព្រោះសេចក្ដីព្យាយាមដ៏មាំនោះឯង មកបណ្ដាលចាក់ដោត ។

វារៈទី -ម្នាលរាជកុមារ ! តថាគតត្រិះរិះថា គួរតែអាត្មាអញសំឡឹងឈាន មិនដកដង្ហើមជាអារម្មណ៍ទៀត គឺអត់ខ្យល់អស្សាសបស្សាសៈតាមមាត់តាមច្រមុះនិងតាមរន្ធត្រចៀក

កាលតថាគតធ្វើដូច្នោះ ខ្យល់លើសប្រមាណក៏កាត់នូវដំបារផ្ទៃ ប្រៀបដូចជាបុរសអ្នកសម្លាប់គោក្តី អ្នកជំនួយរបស់អ្នកសម្លាប់គោក្តី ជាអ្នកប្រសប់វាងវៃ កាត់ដំបារពោះគោដោយកាំបិតដ៏មុតសម្រាប់កាត់ពន្លះនូវសាច់គោ ដូច្នោះឯង ។ ម្នាលរាជកុមារ ! សេចក្តីព្យាយាម ដែលតថាគតបានប្រារព្ធហើយ មិនធូរថយ សតិដែលតថាគតបានដំកល់មាំហើយ ក៏មិនវាយមាយ ឯរាងកាយរបស់តថាគត ក៏នៅតែក្រវល់ក្រវាយ មិនទាន់ស្ងប់រម្ងាប់ទៀត ព្រោះសេចក្តីព្យាយាមដ៏លំបាកនោះឯងមកបណ្តាលហាក់ដោត ។

វារៈទី៦ ម្នាលរាជកុមារ ! តថាគតត្រិះរិះថា គួរតែអាត្មាអញសំឡឹងឈាន មិនដកដង្ហើមជាអារម្មណ៍ទៀត គឺអត់ខ្យល់អស្សាសបស្សាសៈ តាមមាត់ តាមច្រមុះ តាមរន្ធត្រចៀក, កាលតថាគតធ្វើដូច្នោះ សេចក្តីក្តៅក្រហាយដ៏ខ្លាំងលើសប្រមាណ ក៏កើតមានក្នុងកាយ ប្រៀបដូចជាបុរសមានកំឡាំងពីរនាក់ ចាប់បុរសដែលមានកំឡាំងខ្សោយ ត្រង់ដើម

ដែមា្ខងម្នាក់ ហើយយកទៅផ្តើរក្នុងរណ្តៅរងើកភ្លើង ឲ្យក្រហល់ក្រហាយថ្ងៃប្លោះឯង ។ ម្នាលរាជកុមារ ! កាលតថាគតអត់ខ្យល់អស្សាសបស្សាសៈ តាមមាត់ តាមច្រមុះ តាមរន្ធត្រចៀកហើយ សេចក្តីក្តៅក្រហល់ក្រហាយ ខ្លាំងលើសប្រមាណក៏កើតមានក្នុងកាយ ។ ម្នាលរាជកុមារ ! សេចក្តីព្យាយាម ដែលតថាគតបានប្រារព្ធហើយ ក៏មិនធូរថយ សតិដែលតថាគតបានដំកល់មាំហើយ ក៏មិនវាយមាយ ឯកាយរបស់តថាគត ក៏នៅតែក្រវល់ក្រវាយមិនស្ងប់រម្ងាប់ទៀត ព្រោះសេចក្តីព្យាយាមដ៏មាំនោះឯង មកបណ្តាលបាក់ដោត ។

ម្នាលរាជកុមារ ! គ្រានោះ ពួកទេវតាឃើញតថាគតហើយ បាននិយាយគ្នាយ៉ាងនេះថា ព្រះសមណគោតម ធ្វើមរណកាលទៅហើយ, ទេវតាពួកខ្លះបាននិយាយគ្នាថា ព្រះសមណគោតម មិនទាន់ធ្វើមរណកាលទេ តែព្រះសមណគោតមនឹងធ្វើមរណកាលឥឡូវនេះ, ទេវតាពួកខ្លះនិយាយគ្នាថា

ព្រះសមណគោតម មិនទាន់ធ្វើមរណកាលទេ ទាំងមិនទាន់ធ្វើមរណកាលឥឡូវនេះដែរ ព្រះសមណគោតមជាព្រះអរហន្តនុះជាវិហារធមិទេតើ ! សភាពយ៉ាងនេះ រមែងមានដល់ព្រះអរហន្ត ។

វារៈទី ៣–ម្នាលរាជកុមារ ! តថាគតត្រិះរិះថា គួរតែអាត្មាអញ ប្រតិបត្តិដើម្បីផ្តាច់បង់អាហារ ដោយប្រការទាំងពួង ។ លំដាប់នោះពួកទេវតាទាំងនោះ បានចូលមករកតថាគតហើយបបួលគ្នានិយាយថា "បពិត្រអ្នកនិរទុក្ខ ! អ្នកកុំប្រតិបត្តិដើម្បីផ្តាច់បង់អាហារ បើទ្រង់ប្រតិបត្តិដើម្បីផ្តាច់បង់អាហារដោយប្រការទាំងពួងហើយ ពួកយើងនឹងបញ្ចូលឱជាជាទិព្វតាមរន្ធរោមរបស់ព្រះអង្គ នឹងញុំាងព្រះអង្គឲ្យរស់នៅដោយឱជាជាទិព្វនោះ" ។ ម្នាលរាជកុមារ កាលនោះ តថាគតត្រិះរិះថា បើអាត្មាអញនឹងប្តេជ្ញាចំពោះពួកទេវតា ក្នុងកាលឥឡូវនេះទៅពួកទេវតាទាំងនេះនឹងបញ្ចូលឱជាជាទិព្វតាមរន្ធរោមរបស់អាត្មា

អញ ចំណែកខាងអាត្មាអញគប្បីញ៉ាំងជីវិតឲ្យរស់នៅដោយឱជាជាទិព្វនោះ ពាក្យនោះនឹងជាពាក្យកុហកដល់អាត្មាអញ ។ ម្នាលរាជកុមារ ! តថាគត ឃាត់ពួកទេវតាទាំងនោះហើយនិយាយថា “ ល្មោយកុំឡើយ ” ។ ម្នាលរាជកុមារ ! តថាគតត្រិះរិះថា គួរតែអាត្មាអញសម្រេចអាហារកិច្ចបន្តិច ៗ ចំនួនជាមួយទុកដៃខ្លះ ប៉ុនសាច់គ្រាប់សណ្ដែកបាយខ្លះ ប៉ុនសាច់គ្រាប់ពពាយខ្លះ ប៉ុនសាច់គ្រាប់សណ្ដែកកង់ខ្លះ ពុំនោះសោតប៉ុនសាច់គ្រាប់រលីងល្អូកខ្លះ ។ ម្នាលរាជកុមារ ! កាលតថាគតសម្រេចអាហារកិច្ច បន្ថយចុះបន្តិចម្ដង ៗ ដូច្នេះ កាយរបស់តថាគត ក៏ដល់នូវអាការស្គាំងស្គមខ្លាំងលើសប្រមាណ ។

អវយវៈតូចធំរបស់តថាគត ប្រៀបដូចវល្លិមានថ្នាំងច្រើន និងវល្លិមានថ្នាំងខ្មៅ ទ្រគាករបស់តថាគត ក៏ស្ដៀតបួលគ្នា ដូចជាស្នាមជើងឱដ្ឋ ទ្រនុងឆ្អឹងខ្នងរបស់តថាគត ក៏រដិបរដុប ដូចខ្សែរស្លួសដែលគេវេញបួលគ្នា របៀបឆ្អឹងជំនីរតថាគត ក៏

រគឹមរគាម ដូចជាបង្គង់នៃសាលាចាស់ ប្រស្រីភ្នែករបស់តថាគត ក៏ជ្រៅខូងចូលទៅក្នុងរណ្ដៅភ្នែក ដូចកំពែងទឹកដ៏ខូងជ្រៅចូលទៅក្នុងអណ្ដូងទឹកដ៏ជ្រៅ ។ សម្បុរស្បែកក្បាលសម្រាប់ទទួលសម្ផស្សរបស់តថាគត ក៏ស្វិតជ្រីវទៅ ដូចផ្លែឃ្លោកខ្ចីដែលគេកាត់ចេញអំពីទង ហើយស្វិតស្រពោនដោយខ្យល់នឹងកំដៅថ្ងៃដូច្នោះ ព្រោះទោសដែលមានអាហារតិចនោះឯង ។ ម្នាលរាជកុមារ , តថាគតនោះគិតថា នឹងស្ទាបស្បែកពោះ ក៏ចាប់ត្រូវឆ្អឹងខ្នងវិញ គិតថា នឹងស្ទាបឆ្អឹងខ្នងក៏ចាប់ត្រូវស្បែកពោះវិញ, ស្បែកពោះរបស់តថាគត ជាប់គ្នានឹងឆ្អឹងខ្នង តថាគតនោះគិតថា នឹងបន្ទោរបង់នូវវច្ចមុត្រ ក៏ដួលពោបនៅក្នុងទីនោះ ព្រោះទោសអាហារតិចនោះឯង ។ ម្នាលរាជកុមារ ! តថាគត កាលធ្វើកាយនេះឲ្យស្រួលហើយទើបស្ទាបខ្លួនដោយដៃ, កាលតថាគតស្ទាបខ្លួនដោយបាទដៃទៅ រោមទាំងឡាយមានឫសស្អុយ ក៏ជ្រុះចេញពីកាយ ព្រោះ

ទោសអាហារតិចនោះឯង ។ ម្នាលរាជកុមារ ! គ្រានោះមនុស្ស ទាំងឡាយឃើញតថាគតហើយ ក៏នាំគ្នានិយាយថា ព្រះសមណគោតមមានសម្បុរខ្មៅ ខ្លះនិយាយថា ព្រះសមណគោតម មិនមែនមានសម្បុរខ្មៅទេ ព្រះសមណគោតមសម្បុរសណ្តែកបាយទេតើ ! ពួកខ្លះនិយាយថា ព្រះសមណគោតមមិនមែនមានសម្បុរខ្មៅទេ ទាំងមិនមែនមានសម្បុរសណ្តែកបាយទេ គឺព្រះសមណគោតមមានសម្បុរប្រផេះទេតើ ! ។ ម្នាលរាជកុមារ ! ឆវីវណ្ណរបស់តថាគត ដ៏បរិសុទ្ធដល់ម្លោះហើយ ត្រឡប់ទៅជាអាប់អន់ទៅវិញ ព្រោះទោសអាហារតិចនោះឯង ។

១០- ទេវតាចូលទៅថ្វាយដំណឹងព្រះវរបិតា

*ខណៈនោះ ទេវតាមួយអង្គជាពួកមារ គិតស្មានថា ព្រះបរមពោធិសត្វស្តេចទីវង្គតហើយ ក៏ចូលទៅកាន់ក្រុងកបិលពស្តុ យកសេចក្តីថ្វាយព្រះបាទសុទ្ធោទនថា " ឥឡូវនេះ ព្រះរាជបុត្រនៃព្រះអង្គទ្រង់ទីវង្គតហើយ " ។ ព្រះបាទសុទ្ធោទនៈទ្រង់ព្រះសណ្តាប់ហើយ ទើបត្រាស់សួរថា „ ព្រះរាជឱរសរបស់យើង បានត្រាស់ជាព្រះសម្មា-*

*សម្តេចហើយឬនៅ?» ទេវតាតបថា "ស្តេចនៅមិនទាន់បានត្រាស់ដឹងនៅឡើយទេ» ។ ព្រះបាទសុទ្ធោទនៈទ្រង់ព្រះសណ្តាប់ហើយ បណ្តេញថា «អ្នកចូរចៀសចេញឲ្យឆាប់ទៅ នរសរបស់យើង បើមិនទាន់បានត្រាស់ប្រាជ្ញាសារពេជ្ញញាណទេ នឹងមិនទាន់ធ្វើមរណកាលទេ" ។ ទេវតានោះ ក៏អន្តរធានបាតកជនិវេសន៍បាត់ទៅ ។*

## ១១- ទ្រង់ត្រឡប់បរិភោគអាហារវិញ

*ទ្រង់ពិចារណាឃើញទោសការបរិភោគអាហារតិចពេក ទើបទ្រង់បរិភោគអាហារតាមប្រក្រតីដើមឡើងវិញ ដូចសេចក្តីដែលទ្រង់ត្រាស់ចំពោះរាជកុមារថា* (១)

"... ម្នាលរាជកុមារ ! តថាគតត្រិះរិះថា ពួកសមណព្រាហ្មណ៍ឯណាមួយ ក្នុងអតីតកាលក្តី ក្នុងអនាគតកាលក្តី ក្នុងបច្ចុប្បន្នកាលនេះក្តី ដែលកំពុងតែរងទុក្ខវេទនាផ្សាដ៍ក្តៀវក្លា ដែលកើតអំពីសេចក្តីព្យាយាម មានកំណត់ត្រឹមប៉ុណ្ណោះ មិនលើសជាងនេះទៅទៀតបាន តែទោះបីដូច្នោះ តថាគតក៏នៅតែមិនទាន់ត្រាស់ដឹង ឧត្តរិមនុស្សធម៌ ជាគុណវិសេសគួរដើម្បី

១- ពោធិរាជកុមារសូត្រ រាជវគ្គ, ម.ម. សៀវ ២៤. ទំព័រ ៣៨៥ ។

ឃើញដោយប្រាជ្ញាព្រះអរិយៈ ដោយទុក្ករកិរិយាដ៏ខ្លោចផ្សានេះ បានឡើយ ទំនងជាផ្លូវត្រាស់ដឹងនឹងមានជាយ៉ាងដទៃទេដឹង?។

ម្នាលរាជកុមារ ! តថាគតត្រិះរិះថា តថាគតនៅចាំបាន កាលព្រះបិតាប្រត់ព្រះនង្គ័ល តថាគតអង្គុយក្រោមម្លប់ជម្ពូព្រឹក្សដ៏ត្រជាក់ បានស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ក៏ចូលកាន់បឋមជ្ឈានមានវិតក្កៈវិចារៈ មានបីតិនិងសុខៈដែលកើតអំពីវិវេក ហើយគិតថា “ នេះជាផ្លូវត្រាស់ដឹងបានដែរឬ ? ” ។ កាលនោះ វិញ្ញាណដែលស្ទុះទៅតាមសតិ ក៏កើតឡើងដល់តថាគតថា “ នេះហើយប្រាកដជាផ្លូវត្រាស់ដឹង ” ។ ម្នាលរាជកុមារ ! តថាគតត្រិះរិះថា អាត្មាអញខ្លាចសេចក្ដីសុខដែលជាសុខវៀរស្រឡះចាកកាមទាំងឡាយ ដែលជាសុខវៀរស្រឡះចាកអកុសលធម៌ទាំងឡាយដែរឬ ? ប៉ុន្តែសេចក្ដីសុខបែបនេះ តថាគតមិនខ្លាចឡើយ សេចក្ដីសុខនោះដែលបុគ្គលមានរាងកាយ មានកាយដល់នូវសេចក្ដីស្គាំងស្គម លើសប្រមាណ

យ៉ាងនេះ មិនងាយនឹងសម្រេចបានឡើយ បើដូច្នោះ គួរតែអាត្មាអញបរិភោគអាហារដ៏គ្រោតគ្រាត គឺបាយ នឹងនំកុម្មាសឡើងវិញ ទើបទ្រង់បរិភោគអាហារតាមធម្មតាឡើងវិញ ។

១២- បញ្ចវគ្គិយតាបសលះបង់ពោធិសត្វ

*លុះទ្រង់បរិភោគវិញហើយ បញ្ចវគ្គិយក៏បោះបង់ព្រះអង្គចោលទៅ ដូចព្រះតម្រាស់ដែលទ្រង់ត្រាស់ចំពោះពោធិរាជកុមារថា*(១)

“. . . ម្នាលរាជកុមារ ! សម័យនោះឯង ពួកបញ្ចវគ្គិយតាបសអ្នកបំរើតថាគត គឺតគ្នាថា បើព្រះសមណគោតមត្រាស់ដឹងធម៌ណា នឹងសំដែងធម៌នោះ ប្រាប់ដល់យើងទាំងឡាយ តែឥឡូវនេះទ្រង់បរិភោគអាហារដ៏គ្រោតគ្រាតគឺបាយនឹងនំកុម្មាសវិញហើយ ។ គ្រានោះ ពួកបញ្ចវគ្គិយតាបសអម្បាលនោះ ក៏នឿយណាយនឹងតថាគតហើយ ចៀសចេញទៅដោយគិតថា ពីងអ្វីនឹងកើតបើសមណគោតមជាអ្នកល្មោភឃ្លាតចាកសេចក្តីព្យាយាម ត្រឡប់មកដើម្បីល្មោភវិញ ។ ម្នាល

១- ពោធិរាជកុមារសូត្រ រាជវគ្គ. ម.ម. សៀវ ២៤ , ទំព័រ ៣៨៧ ។

រាជកុមារ! លុះតថាគតបរិភោគអាហារដ៏គ្រោតគ្រាតហើយ ក៏បំប៉ុនរាងកាយឲ្យមានកំលាំង ស្ងាត់ចាកកាមទាំងឡាយ ” ។

*ឯពួកបញ្ចវគ្គិយតាបស ប្រដាប់នូវបាត្រនិងចីវរ ក៏លះបង់ព្រះបរមពោធិសត្វ ហើយបបួលគ្នាដើរទៅកាន់ព្រៃឥសិបតនមិគទាយវ័ន ទៀបក្រុងពារាណសី អស់ចម្ងាយផ្លូវ ១៨ យោជន៍ ចូលទៅជ្រកអាស្រ័យនៅក្នុងដងព្រៃនោះ ។ ចំណែកព្រះពោធិសត្វ លុះពួកបញ្ចវគ្គិយតាបស ចេញចាកចោលព្រះអង្គហើយ ទ្រង់ក៏បានសម្រេចចតុត្ថជ្ឈាន សម្រេចសម្រាន្តនៅដោយឥរិយាបថទាំង ៤ ។*

(នៅមានត)

# ព្រះអភិធម្មបិដក

## គម្ពីរព្រះកថាវត្ថុ

(តមក)

លោក ប៊ូ-ប៉ូ ប្រែរៀបរៀង

---

## កុសលចិត្តកថា

ក្នុងលំដាប់នេះ នឹងបានវិសជ្ជនាក្នុងអរហន្តកុសលចិត្តបរិនិព្វានកថា តទៅ តាំងជាសកវាទីបរវាទីមានសេចក្ដីថា ៖

សកវាទី- កុសលចិត្តោ បរិនិព្វាយតិ ព្រះអរហន្តដែលអស់អាសវៈហើយនោះ មានចិត្តជាកុសលចូលកាន់ព្រះបរិនិព្វានមែនឬទេ?

បរវាទី.- អាមន្តា អើ! ត្រូវពិតដូចពាក្យអ្នកថាហើយ ព្រះអរហន្តដែលអស់អាសវៈហើយនោះ កាលនឹងលះខន្ធចូលកាន់ព្រះបរិនិព្វានមានចិត្តជាកុសល ។

សកវាទី ដែលអ្នកថា ព្រះអរហន្តមានចិត្តជាកុសល ចូលកាន់ព្រះនិព្វាននោះ ខ្ញុំនៅសង្ស័យទើសទាក់ចិត្តមិនទាន់យល់ស្របតាមពាក្យរបស់អ្នកទេ ព្រោះហេតុថាព្រះអរហន្តនោះ រមែងធ្វើនូវបុញ្ញាភិសង្ខារ, អបុញ្ញាភិសង្ខារ, អនេញ្ជាភិសង្ខារ គឺព្រះនិព្វានជាបច្ច័យគឺអកុសលតាក់តែងមែនឬទេ ?

បរវាទី – មិនមែនទេ ! អសង្ខតធម្មានំ ព្រះនិព្វាននោះ គ្មានបច្ច័យ គឺកុសលនិងអកុសលប្រជុំតាក់តែងទេ ។

សកវាទី – ព្រះនិព្វាននោះ អ្នកនិយាយថា បច្ច័យគឺអកុសលប្រជុំតាក់តែង ខ្ញុំក៏យល់ឃើញតាមផងបាន ព្រោះហេតុព្រះនិព្វានប្រកបដោយសុខមួយចំណែក ជាសុខពិតប្រាកដមិនលាយឡំទៅដោយទុក្ខ ដែលនិងថា ព្រះនិព្វានកុសលមិនបានប្រជុំតាក់តែងនោះ ខ្ញុំនៅសង្ស័យ ព្រោះហេតុព្រះនិព្វានទៅបាន ចំពោះតែព្រះអរហន្តមួយពួកប៉ុណ្ណោះ កាលលោកទៅនោះទៀត ក៏មានចិត្តជាកុសលទើបទៅបាន ។

បរវាទី–អ្នកគប្បីចូលចិត្តថា ព្រះនិព្វានពុំមានបច្ច័យប្រជុំតាក់តែងទេ ដ្បិតព្រះនិព្វានជាអព្យាកតធម៌ ប៉ុន្តែ បុគ្គលនឹងទៅកាន់ព្រះនិព្វានបាន ដោយអំណាចនៃមហគ្គតកុសល អ្នកគប្បីចូលចិត្តដោយន័យដូច្នេះចុះ ។

កុសលចិត្តកថា ចប់ប៉ុណ្ណោះ ។

---

ទិដ្ឋិសកថា

ទិដ្ឋិសោ ការលោសេ ឧជហតិ សការធាតាមីតិ អាមន្តា សការធាតាមិមត្តេន ចត្តារិ ទិដ្ឋិវិប្បយុត្តា ទ្វេ ធោមនស្សសហគតានិ ទិដ្ឋារិការការមកតព្យាធាន-

ទេសេន ន ចិត្តានិ បហាយន្តិ ។

ពាក្យនេះ ទំងបានវិសជ្ជនាក្នុងឱធិសកថា ពណ៌នាក្នុងសកិទាគាមិ-បុគ្គលតទៅ ។ អ្នកប្រាជ្ញគប្បីសន្និដ្ឋានថា សម្តេចព្រះបរមសាស្តាចារ្យប្រទានព្រះសទ្ធម្មទេសនាជាសកវាទីបរវាទី ដូចន័យដែលបានសំដែងមកហើយ ក្នុងបឋមប្រស្នា គឺត្រាស់បុច្ឆាហើយត្រាស់វិសជ្ជនា ដូចតទៅនេះ ៖

សកវាទី - កិលេសេ បជហាតិ ព្រះសកិទាគាមិបុគ្គលនោះ លះកិលេសបានតែជាចំណែកៗ ឬក៏លះបានដាច់ស្រឡះទាំងអស់តែម្តង ។

បរវាទី - អាមន្តា អើ ! ព្រះសកិទាគាមិបុគ្គលលះកិលេសបានតែជាឯកទេសចំណែកៗ មិនបានលះទាំងអស់តែម្តងទេ នៅមានកិលេសសេសសល់ ព្រះសោតាបុគ្គលលះកិលេសបានដូចម្តេច ព្រះសកិទាគាមិ-បុគ្គលក៏លះកិលេសបានដូច្នោះដែរ ។

សកវាទី - ហញ្ចិ បើដូច្នោះ មិនឈ្មោះថា ឯកទេសសកិទា-គាមិបុគ្គលទៅហើយឬ ?

បរវាទី - ន ហេវំ វត្តព្វេ អ្នកកុំថាយ៉ាងនោះ មិនសមគួរទេ ព្រះសកិទាគាមិបុគ្គល មិនមែនលះកិលេសបានជាឯកទេសសកិទា-គាមីទេ ។

សកវាទី - កាលខ្ញុំសួរពីដំបូង អ្នកឆ្លើយថា ព្រះសកិទាគាមិបុគ្គលលះកិលេសបានដោយឯកទេសដូចព្រះសោតា លុះដល់ខ្ញុំសួរថា ព្រះសកិទាគាមីមិនបានឈ្មោះថា ឯកទេសសកិទាគាមីទេឬ អ្នកត្រឡប់ជាឆ្លើយថា មិនមែនជាឯកទេសសកិទាគាមីទេ ពាក្យដែលអ្នកឆ្លើយមុនមិនសមនឹងពាក្យឆ្លើយក្រោយសោះ អ្នកចូរទទួលនូវទោសដែលអ្នកនិយាយខុស ទើបខ្ញុំអត់ទោសឲ្យអ្នក ។ ចុះព្រះសកិទាគាមិបុគ្គលនោះលះកិលេសបានប៉ុន្មាន ?

បរវាទី – ព្រះសកិទាគាមិបុគ្គលនោះ ចាប់ផ្តើមមុនដំបូង ជម្រះសីលប្រាំបីឲ្យបរិសុទ្ធ កាត់បោសនូវបលិពោធដប់ប្រការ មានកង្វល់ដោយអាវាសជាដើម ហើយចូលទៅជិតនូវមិត្តមានចិត្តជាកុសលមានគុណជាអាទិ គឺជាមនុស្សដែលស្រឡាញ់ត្រេកអរស្មោះត្រង់ ហើយទើបរៀនព្រះកម្មដ្ឋាន វៀរលែងវិហារគឺលំនៅមិនសមគួរ ១៨ កន្លែង មានអាវាសធំជាដើម មានអាវាសដែលខ្លួនមិនបាននូវកល្យាណមិត្តជាបរិយោសាន ហើយទៅនៅក្នុងវិហារប្រកបដោយអង្គប្រាំ មានវិហារមិនឆ្ងាយពេកមិនជិតពេកល្មមទៅមកបានជាដើម ហើយលះបង់នូវកង្វល់មានក្រចកវែងនិងសក់វែងហួសប្រមាណជាអាទិ៍ ហើយចំរើននូវព្រះកម្មដ្ឋានប្រកបជានិច្ចដោយសមាធិ៣ប្រការ គឺបរិកម្មសមាធិ ១ ឧបចារសមាធិ ១ អប្បនាសមាធិ១

បាននូវបដិភាគនិមិត្តនិងឧគ្គហនិមិត្ត បានរូបាវចរឈានហើយបានអរូបាវ-ចរសមាបត្តិ លុះបានសមាបត្តិប្រាំបីប្រការហើយ ប្រាថ្នានឹងឲ្យដល់ព្រះអរហត្ត ក៏ញុំាងញាណទស្សនវិសុទ្ធិឲ្យប្រាកដ ក្នុងលំដាប់នៃវិសុទ្ធិប្រាំមួយប្រការ មានសីលវិសុទ្ធិជាដើម មានមគ្គាមគ្គញាណទស្សន-វិសុទ្ធិជាទីបំផុត ហើយទើបយឹតយកនូវព្រះនិព្វានជាអារម្មណ៍ ក៏នឹងផុតនូវបុថុជ្ជនគោត្រភូញាណ ចូលកាន់ព្រះអរិយគោត្រភូញាណ ក្នុងលំដាប់នៃអរិយគោត្រភូញាណនោះ ក៏កំណត់នូវទុក្ខអរិយសច្ចមានជាតិទុក្ខជាដើម ហើយលះបង់នូវសមុទយអរិយសច្ច គឺសេចក្តីប្រាថ្នាក្នុងកាមភព, រូបភព, អរូបភព ធ្វើឲ្យជាក់ច្បាស់នូវនិរោធអរិយសច្ច និងចំរើននូវមគ្គសច្ច ហើយលះបង់នូវកិលេសបានដោយកាល តាំងទៅក្នុងឋានអរិយភូមិគឺព្រះសោ-តាបន្ន ហើយធ្វើសេចក្តីព្យាយាមដើម្បីនឹងឲ្យដល់នូវមគ្គជាគំរប់ពីរគឺព្រះសកិទាគាមិមគ្គ ព្រះសកិទាគាមិផល ធ្វើសេចក្តីព្យាយាមញុំាងកាមរាគ គឺសេចក្តីតម្រេកក្នុងកាម នឹងសេចក្តីព្យាបាទឲ្យវិនាសបាត់សូន្យ ចាកខន្ធសន្តាន ហើយពិចារណានូវសង្ខារទាំងប្រាំ គឺរូប, វេទនា, សញ្ញា, សង្ខារ និងវិញ្ញាណ ដោយព្រះត្រៃលក្ខណញ្ញាណ ពិចារណាបញ្ច-សង្ខារដោយព្រះ អនិច្ចំ, ទុក្ខំ, អនត្តា គឺឃើញថាបញ្ចសង្ខារមិនទៀងនាំមកនូវទុក្ខនឹងមិនមែនជារបស់ខ្លួន លុះពិចារណាឃើញដូច្នេះ

ហើយ កំយាន៍ចុះកាន់វិបស្សនាវិថី តាស្សេរ៉ុ បដិបន្នស្ស កាល ប្រតិបត្តិដោយប្រការដូច្នេះហើយ អនុលោមគោត្រភូញាណទាំងឡាយ ក៏បង្កើតកុសលជាប់នៃគោត្រភូញាណនោះ ព្រះសកិទាគាមិមគ្គក៏បង្កើតកុសលជាប់នោះ ផលចិត្តទាំងឡាយក៏បង្កើត បានឈ្មោះថាសកិ-ទាគាមិបុគ្គល លះបង់នូវចិត្តជាទិដ្ឋិវិប្បយុត្តបួនដួង ចិត្តប្រកបដោយទោមនស្សពីរដួង និងលះបង់នូវកាមរាគនិងព្យាបាទ ជាចំណែកៗឯព្រះស-កិទាគាមិបុគ្គលនោះ បែកចេញទៅទៀតបាន២២ពួកបានជាហៅថាសកិ-ទាគាមិបុគ្គលនោះ ព្រោះថានឹងមកកាន់លោកនេះមួយគ្រាទៀត បាន សម្រេចព្រះសកិទាគាមិផលក្នុងមនុស្សលោកនេះ លុះអស់ជីវិតិន្ទ្រិយ៍ បានទៅកើតក្នុងទេវលោកនៅក្នុងទេវលោកនោះ ដរាបដល់អស់កំណត់ កាល លុះរលត់បញ្ចសង្ខារហើយចុះមកកើតក្នុងលោកនេះ បានសម្រេច មគ្គផលដរាបដល់ព្រះអរហត្តផល លុះអស់ជីវិតហើយចូលកាន់ព្រះនិព្វាន ក្នុងមនុស្សលោកនេះ ។

សកវាទី - សច្ចំ ឯកពីជោ ព្រះសកិទាគាមិបុគ្គលនឹងឯក-ពីជិសោតានោះ មានហេតុផ្សេងគ្នាដូចម្តេច ដ្បិតព្រះសកិទាគាមីក៏មក កាន់លោកនេះមួយជាតិទៀត ព្រះសោតាដែលឈ្មោះថាឯកពីជិនោះក៏ មកកើតក្នុងលោកនេះមួយជាតិទៀតដូចគ្នាដែរ ?

បរវាទី - ឯកោរ បដិសន្ធិ ឯកពីជិសោតានោះ មានបដិសន្ធិគឺតភ្ជាប់បញ្ចក្ខន្ធតែមួយជាតិប៉ុណ្ណោះ ឯព្រះសកិទាគាមិបុគ្គលនោះ មានបដិសន្ធិពីរដង គឺ ជាជាការណាំ ហេតុផ្សេងគ្នានៃព្រះសកិទាគាមិបុគ្គលនឹងឯកពីជិសោតានោះដូច្នេះ ៗ

សកវាទី - តើ បជហាតិ ព្រះអនាគាមិបុគ្គលលះកិលេសបាន ប៉ុន្មាន ?

បរវាទី - ព្រះអនាគាមិបុគ្គលលះកិលេសបានដោយឯកទេស គឺ លះកិលេសបានជាចំណែកៗ ដូចព្រះសោតាលះបានដែរ ៗ

សកវាទី - បើដូច្នោះ នឹងហៅថាឯកទេសអនាគាមីខ្វះហៅថាអនាគាមីខ្វះបានដែរឬទេ ?

បរវាទី - ឯ ហោវំ អ្នកកុំនិយាយយ៉ាងនោះ មិនគួរទេ ព្រះអនាគាមិបុគ្គលនោះ មិនមែនជាឯកទេសអនាគាមីទេ ៗ ព្រះអនាគាមិបុគ្គល កាលមិនទាន់បានសម្រេចព្រះអនាគា កំពុងតាំងនៅក្នុងភូមិនៃព្រះសកិទាគានោះ រមែងធ្វើព្យាយាមដើម្បីនឹងលះបង់នូវកាមរាគៈ ព្យាបាទ ដោយឥតសេសសល់ ប្រកបនូវសេចក្តីព្យាយាមដើម្បីនឹងឲ្យដល់នូវព្រះអរិយភូមិជាគំរប់បី គឺព្រះអនាគាពិចារណាសាចុះសាឡើងនូវបញ្ចសង្ខារ ដោយព្រះត្រៃលក្ខណញ្ញាណវិបស្សនា កាលប្រតិបត្តិដូច្នេះ អនុលោម

គោត្រភូញាណទាំងឡាយក៏បង្កើត ក្នុងកាលជាលំដាប់នៃគោត្រភូញាណនោះ ព្រះអនាគាមិមគ្គក៏បង្កើត ក្នុងលំដាប់នៃព្រះអនាគាមិមគ្គនោះ ផលចិត្តទាំងឡាយក៏បង្កើត លុះផលចិត្តទាំងឡាយបង្កើតហើយ ក៏បានឈ្មោះជាព្រះអនាគាមិបុគ្គល ជាព្រះអរិយបុគ្គលគំរប់បី មិនបាច់ព្យាយាមដើម្បីឲ្យបានសម្រេចព្រះអនាគាមិផលទៀតទេ ។

អដ្ឋចត្តាឡីស បើនឹងចែកព្រះអនាគាមិបុគ្គលចេញទៅទៀត មានដល់ ៤៨ ពួក គឺ ដើមដំបូងចាត់ជាដប់ប្រាំ (១៥) ជាអន្តរាបរិនិព្វាយីប្រាំពីរ (៧) ជាឧបហច្ចបរិនិព្វាយីមួយ (១) ជាឧទ្ធំសោតអកនិដ្ឋគាមីមួយ (១) ហើយចែកចេញទៅជាអសង្ខារបរិនិព្វាយីប្រាំ (៥) តាំងអំពីជាន់ អវិហា អតប្បា សុទស្សា សុទស្សី ទាំងបួនជាន់នេះស្មើគ្នា ប៉ុន្តែជាន់អកនិដ្ឋនោះលើកឧទ្ធំសោតអកនិដ្ឋគាមីមួយពួកចេញ ព្រោះគ្មានក្នុងជាន់អកនិដ្ឋទេ ។ ព្រះអនាគាមិបុគ្គលលះអកុសលចិត្តបានប្រាំមួយដូចគ្នា ឧបបាតិកោ អនាវត្តិធម្មោ ព្រះអនាគាមិបុគ្គលនោះលុះលែងបញ្ចក្ខន្ធចាកមនុស្សលោកហើយ រមែងទៅបង្កើតដោយអំណាចនៃឧបបាតិកៈកំណើតក្នុងជាន់សុទ្ធាវាសទាំងប្រាំ លែងចុះមកកាន់មនុស្សលោកនេះទៀត អន្តរាបរិនិព្វាយី ព្រះអនាគាមិបុគ្គលពួកណាមិនទាន់ដល់ពាក់កណ្តាលអាយុបានកិលេសនិព្វាន ព្រះអនាគាមិបុគ្គល

ពួកនោះឈ្មោះថាអន្តរាបរិនិព្វាយី ។

ព្រះអរិយបុគ្គលឈ្មោះអន្តរាបរិនិព្វាយីនោះ ចែកចេញជាបីពួក បានដល់អនាគាមិបុគ្គលដែលកើតក្នុងជាន់អវិហា ទើបដល់នូវព្រះអរហត្តក្នុងទីនៃខ្លួនកើត បើមិនបានដល់នូវព្រះអរហត្តក្នុងទីនៃខ្លួនកើតទេ ក៏ចូលដល់ក្នុងទីបំផុតនៃវ័យនៃកប្បជាបឋម យ៉ាងនេះឈ្មោះថាអន្តរាបរិនិព្វាយីមួយពួក ។ ព្រះអនាគាមិបុគ្គលពួកដទៃមិនអាចដល់នូវព្រះអរហត្តដូច្នេះ ទើបដល់នូវព្រះអរហត្តក្នុងទីបំផុតនៃពីរវ័យកប្ប ក៏ឈ្មោះថាអន្តរាបរិនិព្វាយីមួយពួក ទៅដល់អរហត្តក្នុងទីបំផុតនៃបួនវ័យកប្បមួយពួក ក៏ឈ្មោះថាអន្តរាបរិនិព្វាយីដូចគ្នា ។ ព្រះអនាគាមិបុគ្គលឈ្មោះថាអន្តរាបរិនិព្វាយីនោះ មានបីពួកដូចវិសជ្ជនាមកនេះ ។

បញ្ចសត្តកាបរ្ស ឧបហច្ច ព្រះអនាគាមិបុគ្គលមិនបានកន្លងបង់នូវវ័យនៃកប្បគម្រប់ប្រាំ ទើបបានសម្រេចព្រះអរហត្តបាត់ឈ្មោះថាឧបហច្ចបរិនិព្វាយី អ្នកប្រាជ្ញគប្បីចូលចិត្តដោយន័យដូច្នេះ តាំងអំពីជាន់អវិហាជាដើមទៅ ។

សសង្ខារបរិនិព្វាយីនោះ បានដល់ព្រះអនាគាមិបុគ្គលកើតក្នុងជាន់សុទ្ធាវាសណាមួយ ប្រកបសេចក្ដីព្យាយាមដើម្បីឲ្យបានដល់ព្រះអរហត្តដោយលំបាក យ៉ាងនេះឈ្មោះថាសសង្ខារបរិនិព្វាយី ។

(នៅមានត)

# មធុរសវាហិណី

(តមក)

សម្តេចព្រះធម្មលិខិត ល្វី-ឯម ប្រែរៀបរៀង

ឯព្រះបច្ចេកពុទ្ធអង្គនោះ កំពុងតែធ្វើចីវរកម្មក៏ខ្វះសំពត់អនុវាត ចុះចីវរពុំគ្រប់គ្រាន់ ព្រះអង្គប្រារព្ធនឹងស្វែងរកសំពត់មកបំពេញថែមទៀតឲ្យគ្រប់គ្រាន់ ។

កុដុម្ពិក បានឃើញព្រះបច្ចេកពុទ្ធធ្វើអាកប្បកិរិយាដូច្នោះហើយ ក៏ទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ! ព្រះអង្គមានកិច្ចអ្វី ? ព្រះបច្ចេកពុទ្ធ ក៏លោកពុំបានពោលតបវិញដល់តិចតួចឡើយ ព្រោះព្រះអង្គជាអ្នកប្រាថ្នាតិច ។ ឯកុដុម្ពិកសោត កាលបើព្រះបច្ចេកពុទ្ធពុំបានពោលតបដូច្នោះហើយ ក៏បានដឹងថា ប្រាកដជាសំពត់ចីវររបស់ព្រះបច្ចេកពុទ្ធនេះពុំគ្រប់គ្រាន់ ទើបយកសំពត់បង់ករបស់ខ្លួន ទៅដំកល់ទុកទៀបព្រះបាទនៃព្រះបច្ចេកពុទ្ធ ហើយដើរចៀសចេញទៅក្នុងកាលនោះឯង ។

ចំណែកឯព្រះបច្ចេកពុទ្ធ ក៏បានកាន់យកសំពត់សាដកនោះមកប៉ះថែមជាសំពត់អនុវាត បានដេររួចស្រេចគ្រប់គ្រាន់ ពុំមានខ្វះខាតឡើយ ហើយជ្រលក់ប្រើប្រាស់ជាដរាបទៅ ។

កុដុម្ពិកនោះសោត កាលបើធ្វើមរណកាលអស់ជីវិតហើយ ក៏បាន

ឡើងទៅ កើតក្នុងស្ថានតាវតឹ្តសពិភព សោយទិព្វសម្បត្តិ ដរាបដល់អស់អាយុ ហើយច្យុតមកកើតក្នុងត្រកូលមួយមាននាមពុំប្រាកដ ក្នុងនគរជាទីជិតក្រុងពារាណសី មានចម្ងាយប្រមាណជាមួយយោជន៍ប៉ុណ្ណោះ ។

ឯមាតាបិតា ក៏បានឲ្យឈ្មោះថា ននកុមារជាមង្គលសួស្តីដល់បុត្រនោះឯង ។

រីឯននកុមារនោះ មានបងប្អូនប្រាំមួយនាក់ ។ បងប្អូនទាំងប្រាំមួយនាក់នោះ ក៏ខំខ្វល់ខ្វាយក្នុងការងារផ្សេង ៗ សន្សំរបស់មកចិញ្ចឹមមាតាបិតាអស់កាលជានិច្ច ។

ចំណែកឯននកុមារ ឥតមានរវល់ធ្វើការងារអ្វីឡើយ តែងនៅតែក្នុងផ្ទះ ពុំបានយកចិត្តទុកដាក់ ប្រឹងប្រែងធ្វើការងារទាំងនោះដល់តិចសោះ ។ ព្រោះហេតុដូច្នោះ បានជាបងប្អូនដ៏សេសគេប្រគ្នាទឹងទែងននកុមារតែរាល់ ៗ គ្នា គេរិះគន់ថា ជាមនុស្សខ្ជិលឥតពិចារណា គេបានព្រមានដល់មាតាបិតាឲ្យប្រដៅផងទៀត ។

ឯមាតាបិតា ក៏ចូលហៅននកុមារមកនិយាយឲ្យដំបូន្មានប្រៀនប្រដៅ ឲ្យខំយកចិត្តទុកដាក់ធ្វើការងារកុំឲ្យខ្ជិលច្រអូសតទៅទៀត ។

ននកុមារលុះបានស្ដាប់ពាក្យប្រដៅមាតាបិតាហើយ ក៏ធ្វើព្រងើយកន្តើយ ពុំស្ដីនិយាយតបតថាអ្វីឡើយ នៅតែប្រព្រឹត្តដូចមុន គឺឥត

មានធ្វើការងារអ្វីផល់តិចតួចសោះ, លុះដល់មកកាលជាខាងក្រោយទៀត មាននក្ខត្តឫក្សគឹកកង់ក្នុងស្រុកនោះឯង, ជនទាំងឡាយគេចប្អូលគ្នាស្លៀកសំពត់ពាក់អាវស្អាតអាត្មាទៃ ៗ ដើម្បីលេងនក្ខត្តឫក្សក្នុងកាលនោះ ។

គ្រានោះ នន្ទកុមារនិយាយទៅនឹងមាតាថា: បពិត្រអ្នកមេដ៏មានគុណ ! សូមអ្នកមេឲ្យបានសំពត់សាដកមួយមកខ្ញុំ ៗ នឹងស្លៀកគ្រាន់លេងនក្ខត្តឫក្សនឹងគេក្នុងកាលឥឡូវនេះ ។

មាតាក៏បានយកសំពត់សាដកមួយ ដែលខ្លួនបានលាងស្អាតឲ្យទៅនន្ទកុមារជាបុត្ររបស់ខ្លួន ។ ឯនន្ទកុមារ កាលបើបានឃើញសំពត់នោះហើយ ក៏និយាយឃាត់មាតាថា: បពិត្រអ្នកមេ ! សំពត់នេះមានសាច់គ្រាសណាស់ ខ្ញុំពុំត្រូវការឡើយ សូមអ្នកមាតាឲ្យសំពត់យ៉ាងល្អដ៏មានសាច់ម៉ដ្ឋដទៃមកខ្ញុំវិញ មាតាក៏យកសំពត់សាដកដទៃមកឲ្យទៀត ។

នន្ទកុមារបានឃាត់ទៀត ពុំព្រមទទួលយកសំពត់សាដកដែលមាតាឲ្យនោះឡើយ ។ កាលនោះ មាតានិយាយទៅនឹងនន្ទៈជាបុត្តរបស់ខ្លួនថា: ម្នាលកូនអើយ ! ក្នុងផ្ទះយើងនេះពុំមានសំពត់ណាដទៃល្អលើសសំពត់នេះឡើយ បើបុណ្យរបស់អ្នកមានគង់តែនឹងបានសំពត់ល្អវិសេស ដ៏មានសាច់ម៉ដ្ឋជាងសំពត់នេះដោយពិត ។

ឯនន្ទកុមារជាបុត្ត លុះបានស្ដាប់ពាក្យមាតាហើយ ក៏និយាយតបវិញថា: បពិត្រអ្នកមេ ! បើដូច្នេះ ខ្ញុំនឹងទៅស្វែងរកសំពត់សាដក

ដីមានសាច់ម៉ដ្ឋនោះ តាមទឹកខ្ទិនដែលគួរបាន តាមបំណងរបស់ខ្ញុំ ។

មាតាបានស្ដាប់ហើយ ក៏និយាយផ្ដួនថែមទៀតថា: ម្នាលកូនសម្លាញ់អើយ ! ចិត្តមាតាដែលស្រឡាញ់រាប់អានបា មានប្រាថ្នាចង់ឲ្យបាបានសោយរាជសម្បត្តិក្នុងនគរពារាណសីទាំងអស់ ក្នុងថ្ងៃនេះជាយ៉ាងក្រៃលែង ។

ឯននកុមារជាបុត្ត លុះបានស្ដាប់ពាក្យមាតាពោលយ៉ាងនេះហើយ ក៏មានចិត្តត្រេកអរពន់ពេក ទើបពោលតបថា: បពិត្រអ្នកមេ ! ពាក្យដែលអ្នកមេពោលមកនេះ ប្រពៃណាស់ ៗ ហើយលើកដៃឡើងសំពះមាតា ដើរប្រទក្សិណបីជុំពោលលាថា: ខ្ញុំសូមលាអ្នកមេទៅហើយ សូមអ្នកមេស្ថិតនៅឲ្យបានសេចក្ដីសុខសប្បាយចុះ និយាយលាស្រេចហើយ ក៏ដើរចៀសចេញទៅក្នុងកាលនោះឯង ។

ចំណែកមាតា ក៏មានសេចក្ដីតក្កៈគិតថា កូនអាត្មានេះវានឹងទៅណា វានឹងទៅអង្គុយលេងក្នុងផ្ទះគេឯនេះខ្លះឯនោះខ្លះ ហើយវានឹងត្រឡប់មកកាន់ផ្ទះនេះវិញ ដូចការពីមុន ៗ ពុំលែងឡើង ។

ចំណែកឯននកុមារវិញសោត គឺបុណ្យដែលខ្លួនបានថ្វាយសំពត់សាដកដល់ព្រះបច្ចេកពុទ្ធ ប៉ះធ្វើជាអនុវត្តចរពីអតីតជាតិនោះ ហាក់ដូចជាមានចិត្តគិតរំលឹកដាស់តឿនរឿយៗ ក្នុងចិត្តកុមារនោះ ដែលចេញអំពីស្រុកសំដៅទៅកាន់នគរពារាណសី ហើយនៅអាស្រ័យក្នុងផ្ទះនៃ

អាមាត្យម្នាក់ ឈ្មោះសេនគុត្ត ក្នុងក្រុងនោះឯង ។

ដល់ថ្ងៃមួយជាខាងក្រោយ នៅវេលាយប់នន្ទកុមារនោះបាននិយាយចរចារនូវការផ្សេងៗ ជាមួយនឹងសេនាគុត្ត លុះអង្គុយយូរទៅក៏ងោកដួចដេកលក់ ស្រាប់តែបានឃើញសុបិននិមិត្ត ហាក់ដូចពោះវៀនរបស់ខ្លួនចេញអំពីមាត់ លៀនវ៉ៃងផ្សាយទៅព័ទ្ធជម្ពូទ្វីបទាំងអស់ ហើយចូលមកខាងក្នុងពោះវិញ ។ លុះភ្ញាក់ឡើងកិតភ័យញាប់ញ័រ ស្រែកសម្រែកលាន់ឮខ្លាំងក្នុងខណៈនោះឯង ។

គ្រានោះ សេនាគុត្តបានឮសំឡេងស្រែកហើយក៏សួរថា: ម្នាលនន្ទ:អ្នកឯងស្រែកថ្វី ឮសំឡេងខ្លាំងដល់ម៉្លេះ ។

នន្ទកុមារនោះក៏និយាយប្រាប់ថា: ខ្ញុំស្រែកនេះព្រោះខ្ញុំបានឃើញសុបិននិមិត្តប្លែកណាស់ ។

កាលបើសេនាគុត្តបានសួរសុបិននិមិត្តនោះហើយ ក៏និយាយប្រាប់សព្វគ្រប់ តាមនិមិត្តដែលខ្លួនបានឃើញនោះឯង ។

ក្នុងកាលនោះ សេនាគុត្តក៏បានសួររឿងសុបិននិមិត្តនោះ ចំពោះបរិព្វាជិកា ដែលជាអ្នកចូលមកកាន់ត្រកូលនៃខ្លួនថា: បពិត្រនាងជាម្ចាស់! ថាបើបុគ្គលណាមួយ បានឃើញនូវសុបិននិមិត្តដ៏ប្រាកដយ៉ាងនេះ បុគ្គលនោះនឹងបានទទួលផលដូចម្តេច ? នឹងមានទោសដូចម្តេច ? ។

លុះនាងបរិព្វាជិកាបានស្តាប់ហើយ ក៏ទំនាយសុបិននិមិត្តនោះថា:

ម្នាលសេនាគុត្ត     បើស្ត្រីបានឃើញសុបិនទិមិត្តយ៉ាងនេះ នឹងបានទូវឋានន្តរ អគ្គមហេសីនៃព្រះរាជាវង់នៃថ្ងៃទី ៧ ដោយពិត, ជាបើបុរសបានឃើញសុបិននិមិត្តយ៉ាងនេះ នឹងបានជាស្តេចសោយរាជសម្បត្តិក្នុងវង់នៃថ្ងៃទី ៧ ដូច្នោះដែរ ។

ឯសេនាគុត្ត កាលបើបានស្តាប់ទំនាយនិមិត្ត ដែលនាងបរិព្វាជិកាទាយនោះហើយ ក៏គិតពិចារណាថា: អញនឹងធ្វើនូវកុមារនេះឲ្យជាញាតិរបស់អញ  លុះគិតដូច្នេះហើយ ក៏ហៅកូនស្រីទាំង ៧ នាក់ឲ្យចូលមកជិតហើយសួរតាមលំដាប់ថា: ម្នាលនាងទាំងឡាយដ៏ចំរើន ! នាងចូលចិត្តនៅជាមួយ កុងសំណាក់នន្ទនេះដែរឬដូចម្តេច ?

កូនស្រីទាំងនោះពុំបានទទួលយល់ស្របឡើយ  ហើយពោលព្រមគ្នាថា: យើងទាំងឡាយ ពុំបានស្គាល់នន្ទនេះ ដែលជាអ្នកទើបមកពីចម្ងាយថ្មីៗឡើយ មិនដឹងជាគាត់មានត្រកូលពូជពង្សល្អ ឬអាក្រក់យ៉ាងណាៗទេ យើងទាំងឡាយនឹងនៅរួមជាមួយដូចម្តេចបាន ។

ឯសេនាគុត្ត បានស្តាប់ពាក្យកូនស្រីទាំង ៦ រូបនោះហើយ ក៏ហៅកូនស្រីប្អូនពៅបង្អស់  មកសួរជាខាងក្រោយ  កូនពៅនោះក៏ទទួលព្រមថា: ស្រេចលើលោកមាតាបិតាចុះ នឹងឲ្យខ្ញុំទៅនៅជាមួយនឹងអ្នកណាខ្ញុំក៏ពុំបានទទឹងតាស់នូវពាក្យនៃមាតាបិតាឡើយ ។

(នៅមានត)

# មហោសធជាតក

(តមក)

លោក អ៊ឹម-កន ចម្លងពីសាស្ត្រាស្លឹករឹត

ព្រះពុទ្ធវង្ស កឹម-គួរ ពិនិត្យ

---

វិសាខសេដ្ឋីទូលវិញថា បពិត្រមហារាជអើយ រីមហោសធក្មេងក្តាត់ហោង, ឥឡូវនេះ ជុំតែក្លិនទឹកដោះនៅមាត់ឡើយគួរ នឹងនៅបំរើព្រះអង្គស្វាមីភក្តិ ព្រះបាទអ្នកជាអម្ចាស់ម្តេចបាន កាលណាបើមហោសធចំរើនធំឡើងហើយ ក៏សឹមមកនៅបំរើជាស្វាមីភក្តិព្រះបាទអម្ចាស់នោះហោង ។ ស្តេចបន្ទូលថា ម្នាលសេដ្ឋី អំពីថ្ងៃនេះទៅ កុំបីព្រះស្តែងអាល័យបាមហោសធឡើយ, មហោសធនេះ ចូរឲ្យមកនៅជាកូនអញអំពីថ្ងៃនេះឯង, នាព្រះស្តែងនឹងចិញ្ចឹមកូនរក្សាកូនព្រះស្តែងដូចម្តេចមិញ ក៏អញនឹងចិញ្ចឹមរក្សាព្យាបាលកូនអញដូច្នោះឯងហោង ។ ស្តេចថាអម្បាលនោះហើយ ស្តេចឲ្យដំណើរសេដ្ឋីនោះថា ម្នាលសេដ្ឋី ចូរព្រះស្តែងចូលទៅហោង ។

សេដ្ឋីនោះ ថ្វាយបង្គំមហាសត្វឱបរឹតផ្តេកទៅអ្នកប្រាជ្ញលើទ្រូងថើបក្បាល ឲ្យដំបូន្មានប្រដៅព្រះមហាសត្វថា ម្នាលកូនសួនសំឡាញ់ពេញ

ចិត្តអាពុកអើយ បាហោងជាថ្មើមដង្ហើមជាក្អែកអាពុក ហៃបាមហោសថ កុំបីបាធ្វើឲ្យយើងកំព្រាជាអ្នកឥតពំនាក់ឡើយ អំពីថ្ងៃនេះទៅ ចូរបាខំស្វាហាប់បំរើព្រះបាទអ្នកជាអម្ចាស់កុំប្រហែសឡើយ ៗ ព្រះមហាសត្វអ្នកសំពះព្រះបិតាហើយថា បពិត្រអ្នកអាពុក កុំបីអ្នកគិតបារម្ភនឹងខ្ញុំឡើយ ៗ ព្រះមហាសត្វអ្នកឲ្យដំណើរព្រះបិតាទៅហោង ៗ

លំដាប់នោះ, ស្ដេចបន្ទូលដណ្ដឹងទៅអ្នកប្រាជ្ញថា ម្នាលបាមហោ-សថបានឹងបំរើឯក្នុង ឬនឹងបំរើឯក្រៅ ៗ ព្រះមហាសត្វអ្នកគិតថា អញមានបរិវារច្រើន ដូច្នេះគួរអញបំរើឯក្រៅវិញចុះ ៗ ទើបព្រះមហាសត្វថា បពិត្រព្រះបាទអម្ចាស់អើយ អញខ្ញុំនឹងបំរើឯក្រៅវិញហោង ៗ

ឮដំកាលនោះ ស្ដេចប្រើអ្នកផងឲ្យធ្វើផ្ទះគួរនឹងព្រះមហាសត្វនៅ ហើយស្ដេចប្រើឲ្យដាក់ស្បៀងឲ្យគេនិងអស់ទាំងមួយពាន់ជាដើម ប្រើឲ្យសព្វគ្រប់គ្រឿងប្រដាប់សម្រាប់អំពីសម័យថ្ងៃនោះរៀងទៅហោង ៗ រីព្រះមហាសត្វសោត អ្នកតែងចុះគាល់ហៅបំរើស្ដេចពុំដែលដាច់ឡើយ ៗ

មានកាលសម័យថ្ងៃមួយ ស្ដេចទ្រង់ចង់ល្បងលប្រាជ្ញានៃចៅមហោសថអ្នកប្រាជ្ញ, ស្ដេចគិតថា ម្នាលចៅមហោសថអ្នកប្រាជ្ញអញឮថា អ្នកមានប្រាជ្ញាឈ្លាសវៃអាចដោះអាថ៌ប្រស្នាទាំងពួង តែតិះមោះ រីអញពុំដែលបានយល់ឲ្យជាក់ច្បាស់ប្រាកដនឹងភ្នែកអញឯង, អញនឹងល្បងចៅអ្នក

ប្រាជ្ញឲ្យប្រាកដនឹងភ្នែកអញឯង ។ ស្ដេចគិតអម្បាលនោះហើយ ទើបប្រើរាជអាមាត្យមួយឈ្មោះ (អនុជិត) ឲ្យយកកែវមណីរ័តន៍ឡើងទៅដាក់ញ្ជំសម្បុកក្អែកមានលើចុងត្នោត ទៀបនឹងឆ្នេរស្រះមិនឆ្ងាយអំពីទ្វារព្រះនគរទិសឯត្បូង ពុំឲ្យអ្នកផងដឹងឡើយ លុះព្រះអាទិត្យរះត្រចះចាំងមកត្រូវកូវ រីស្រមោលមណីរ័តន៍នោះចុះប្រុះយល់ប្រាកដនាក្នុងទឹកស្រះនោះ ។ រីអស់អ្នកផងយល់ហើយ សឹងទៅទូលស្ដេចថា មណីរ័តន៍មាននៅក្នុងស្រះនោះ, ស្ដេចបន្ទូលដណ្ដឹងអាចារ្យសេនកថា ម្នាលអាចារ្យសេនកអញឮថាមានមណីរ័តន៍នៅក្នុងស្រះ យើងនឹងយកមណីរ័តន៍នោះម្ដេចហ្នឹង ? អាចារ្យសេនកទូលថា គួរគប្បីយើងបង្ហូតទឹកចេញ ក៏ស្ដេចបន្ទូលថា បើដូច្នោះអំពើទាំងពួងនេះទុកជាទម្ងន់នៅអាចារ្យ ចូរអាចារ្យធ្វើឲ្យបានដូចគំនិតនោះហោង ។ រីអាចារ្យសេនកឲ្យជំនុំប្រជុំនូវមនុស្សផងច្រើនហើយឲ្យបង្ហូតទឹកភក់ចេញ ជីកជីកកាយក៏ពុំយល់ឡើយ ហើយបើកទឹកដាក់វិញ ក៏យល់ស្រមោលមណីរ័តន៍នោះវិញទៀត ។ រីអាចារ្យសេនកនោះឲ្យធ្វើព្រួលទល់ ហើយឲ្យបង្ហូតទឹកចេញវិញ នោះក៏មិនយល់មណីរ័តន៍ឡើយ ។

លំដាប់នោះ, ស្ដេចបន្ទូលនឹងទៅអ្នកប្រាជ្ញថាដូច្នេះ ម្នាលបាមហោសថ មានមណីរ័តន៍មួយយល់ប្រាកដក្នុងស្រះ ។ រីអាចារ្យសេនកឲ្យ

បង្ហូតទឹកបាកេក់ចេញ កាប់ដីកកាយរកក៏ពុំឃើញមណីរ័ត្ននោះ លុះបង្ហូតទឹកចូលវិញ ក៏ឃើញវិញទៀតដដែល ៗ ម្នាលបាមហោសថអ្នកប្រាជ្ញ បាអាចយកមណីរ័ត្ននោះបានឬទេហ្ន៎? ព្រះមហាសត្វទូលថា បពិត្រមហារាជ រីអំពើទឹងយកមណីរ័ត្ននោះមិនជាទម្ងន់ក្រឡើយ អញខ្ញុំនឹងយកថ្វាយបង្ហាញព្រះបាទអម្ចាស់ហ្ន៎ ៗ ស្ដេចមានព្រះហឫទ័យត្រេកអរថា អញនឹងបានមើលកំឡាំងប្រាជ្ញាចៅអ្នកប្រាជ្ញឥឡូវនេះ ៗ ស្ដេចលីលាយាត្រាចេញអំពីព្រះរាជមន្ទីរ មានមហាជនផងច្រើនជាបរិវារ ស្ដេចត្រាស់ចេញទៅគង់ទៀបឆ្នេរស្រះនោះ, រីឯព្រះមហាសត្វអ្នកឈរនៅឰដ៏ថ្នល់ស្រះនោះ ហើយអ្នករមិលមើលមណីរ័ត្នដឹងថា មណីរ័ត្នមាននាចុងត្នោតនោះហ្ន៎មិនទេឡើយ, អ្នកដឹងដូច្នោះហើយ អ្នកទូលថា បពិត្រមហារាជ រីមណីរ័ត្នមិនអង្គឹមានក្នុងស្រះនោះទេ, ស្ដេចថា ម្នាលបាអ្នកប្រាជ្ញ បាថាមិនឃើញមណីរ័ត្នក្នុងស្រះនេះ ម្ដេចក៏បាថាដូច្នោះហ្ន៎ ? ព្រះមហាសត្វអ្នកថា បពិត្រមហារាជ ថាបើអម្ចាស់មិនជឿពាក្យខ្ញុំដូច្នោះ ចូរអម្ចាស់ទតហ្ន៎ ៗ ទើបអ្នកយកទឹកដាក់ក្នុងភាជន៍មួយមកដំកល់ហើយ អ្នកទូលថា បពិត្រមហារាជ ចូរអម្ចាស់ទតស្រមោលមណីរ័ត្នក្នុងស្រះឯងក្ដី ក្នុងទឹកភាជន៍នេះក្ដី ? ក៏ឃើញប្រាកដហ្ន៎ ៗ ស្ដេចបន្ទូលថា ម្នាលបាមហោសថអ្នកប្រាជ្ញអើយ មើ

ដូច្នោះតើមណីរ័ត្ននោះនៅឯណា ? ព្រះមហាសត្វថា បពិត្រមហារាជ សូមឲ្យរុកស្រះក្តី រុកទឹកការជន់ក្តី កុំយល់តែស្រមោលទេត្រូវ រីឯត្បូងមណី-រ័ត្នឥតអន្តិមានព្រងឃាំងនេះទេ មហារាជ , រីមណីរ័ត្ននេះ ទីងមាននាគរុង សម្បុកក្អែកព្រៃដំបូងត្នោតនោះត្រូវ, អ្នកថាអម្បាលនោះហើយអ្នកប្រើបុរស មួយឲ្យឡើងយកមណីរ័ត្ននោះមក ។ ស្តេចបន្ទូលថាឲ្យយកមកនឹង មើល ។ ព្រះមហាសត្វអ្នកយកមណីរ័ត្ននោះមកថ្វាយ ។ ស្តេច ទទួលយកមណីរ័ត្ននោះមកដំកល់ដាក់ព្រងំបាតព្រះហស្ត ។ រីឯសព្វពួក មហាជនជនទាំងឡាយ សឹងដំរេត្រកអរឲ្យសព្វសាធុការដល់ចៅអ្នកប្រាជ្ញ ហើយក៏ជេរត្មះតិះដៀលអាចារ្យសេនកថា មណីរ័ត្នមាននាចុងត្នោត ឯណោះ រីឯអាចារ្យសេនកតេញ្ចុតមិញ ឲ្យបុរសហៅពលច្រើនទៅ បើកទំលាយឯស្រះវិញហ៎ះ, ហើយមកស្រដីសរសើរព្រះមហោសថថា នាប័ហៅថាអ្នកប្រាជ្ញឲ្យដូចចៅមហោសថនេះ ទើបហៅថាអ្នកប្រាជ្ញ ប្រសើរហោង ។

រីព្រះបាទវិទេហរាជ ស្តេចមានព្រះហឫទ័យត្រេកអរសាទរ ទ្រង់ព្រះករុណាព្រះមហាសត្វនោះក្រៃពេក ហើយស្តេចដោះមុក្តាហារត្រ-ណោតមកជាគ្រឿងប្រដាប់សំរាប់ព្រះសូរង់ព្រះអង្គឯង ព្រះរាជទានឲ្យ ទៅចៅមហោសថអ្នកប្រាជ្ញ ហើយស្តេចឲ្យដោះកងមុក្តាទៅឲ្យក្មេង

សំរាប់ព្រះមហោសថតាំងមួយពាន់នោះ ស្តេចទ្រង់ព្រះករុណាបើក ព្រះមហាសត្តិ គ្រឿងជាបរិវារក្តី ឲ្យឡើងចុះគាល់ហៅ ឲ្យបំរើជាបរិវារ តាមពាក្យសច្ចានេះហោង ។

ឯកាទសិតបញ្ហា និដ្ឋិតោ ។ រឿងការល្បែងអាចប្រស្នាម្ពុះ១ មានល្បែងសាច់ជាដើម ស្រេចមកដល់ល្បែងកែវ ត្រូវជា ១៩ គ្រប់បរិបូណ៌ ហោង ។

បុណ្ណកកិរសំ មានកាលសម័យថ្ងៃមួយវិញទៀត, ព្រះបាទវិទេហរាជ ស្តេចទៅប្រពាតឧទ្យាន នូវចៅមហោសថអ្នកប្រាជ្ញ ។ ព្រម កាលនោះ មានសត្វបង្កួយមួយអាស្រ័យនៅលើចុងតោរណៈ (ខ្លោងទ្វារ) បង្កួយនោះឃើញព្រះបាទវិទេហរាជ ស្តេចមកនូវយសបរិវារច្រើន ។ រី បង្កួយនោះ មានចិត្តកោតខ្លាចនូវអំណាចស្តេច ហើយគិតថា អញនេះ ពុំគួរនៅលើបានខ្ពស់ដូច្នេះសោះ បង្កួយនោះលោតចុះមកអំពីចុងតោរណៈ ហើយក្រាបនៅប្រឹថពី ស្តេចទតឃើញនូវអំពើបង្កួយនោះ ស្តេចដណ្តឹងថា ម្នាលចៅអ្នកប្រាជ្ញ បង្កួយនេះ ធ្វើនូវអំពើអ្វីដូច្នេះហ្ន៎ ? ទើបព្រះមហាសត្វថា បពិត្រមហារាជ រីបង្កួយនេះ វាចុះមកគាល់ព្រះអង្គព្រះបាទអម្ចាស់ ។ ស្តេចថា ម្នាលចៅអ្នកប្រាជ្ញ ថាបើវាមកគាល់ហៅដូច្នោះពិត ក៏កុំថាឲ្យវាឥតប្រយោជន៍ឡើយ ចូរបាឲ្យសម្បត្តិវាហោង ។

ព្រះមហាសត្វទូលថា បពិត្រមហារាជ រីនឹងឲ្យសម្បត្តិទ្រព្យធនអ្វីមាន ទឹងវាជាបង្គួយនោះឡើយ ឲ្យតែចំណីចំណុកគួរនឹងវាហោង ៗ ព្រះមហាសត្វថា បពិត្រមហារាជ អម្ចាស់ឲ្យតានចំណីវាហោង ៗ ស្តេចថា វាឆីអ្វី ? ព្រះមហាសត្វថា អម្ចាស់វាឆីសាច់, ស្តេចថា សាច់ប៉ុន្មានគួរនឹងវា ? ព្រះមហាសត្វថា បពិត្រមហារាជ គួរតែសាច់មួយចម្មៅក្អែកហោង ៗ ព្រះបាទវិទេហរាជ ស្តេចបង្គាប់បុរសមួយថា ឆាបហៅអាណាយតែមួយចម្មៅក្អែកដូច្នោះមិនគួរឡើយ ម្ល៉ោះហើយស្តេចក៏ឲ្យមាសកន្លាស់សណ្តែកជាមួយក្រមថា ចូរកាយកទៅទិញដូរសាច់ឲ្យបង្គួយនេះវាឆីសព្វៗ ថ្ងៃកុំបីដាច់ឡើយ ៗ រីបុរសនោះទទួលព្រះបន្ទូលថា សាធុ ! គាប់ហោង ៗ អំពីថ្ងៃនោះទៅ បុរសនោះតែងទៅទិញសាច់អំពីផ្សារ ឲ្យជាចំណីបង្គួយនោះជាប្រក្រតីពុំដែលដាច់ឡើយ ៗ មានកាលសម័យថ្ងៃមួយ ជាថ្ងៃ៖ឧបោសថសីល អ្នកផងមិនសម្លាប់សត្វលក់ឡើយ, បុរសនោះទឹងទៅរកទិញសាច់ជាចំណីបង្គួយពុំបានឡើយ ហើយបុរសនោះគិតទឹងយកមាសកន្លាស់សណ្តែកនោះ មក·ចោះជាតខ្សែធ្វើជាគ្រឿងប្រដាប់បំពាក់ទូវកបង្គួយនោះ, ដ្បិតបុរសនោះគិតក្រែងបង្គួយនោះវាខឹង ដ្បិតពុំបានឲ្យចំណីវាឆី ហើយបុរសនោះយកមាសចង់កបង្គួយនោះវាខឹងវត់បាត់នោះហោង ៗ អំពីកាលបុរសនោះ យកមាស

មកធ្វើជាគ្រឿងប្រដាប់នោះមិញ រីបក្ខីយនោះអាស្រ័យទីងមាសជាគ្រឿង ប្រដាប់ ក៏មានះកើតឡើងអំពីកាលនោះហោង ។

មានកាលសម័យថ្ងៃមួយនោះឯង ស្តេចទៅលេងនាទខ្យាន នូវទៅ អ្នកប្រាជ្ញ បក្ខីយនោះយល់ស្តេចមកដូច្នោះក្តី ក៏នោះកើតមានះ ហេតុ ពីងមាសមួយក្រោមនោះហោង ក៏ធ្វើជំកើងអាត្មាដូចមួយអន្ទើទីងស្តេច គិតក្នុងចិត្តឯងថា នាស្តេចវិទេហរាជអ្នកមានទ្រព្យច្រើន ឬអញនេះមាន ទ្រព្យច្រើន ? រីបក្ខីយនោះគិតដូច្នោះហើយ មិនចុះមកឡើយ ប្រឹងប្រែង ពួតក្អេងជំកើងអាត្មា អន្ទ្រីនក្បាលនៅលើចុងតោរណៈនោះហោង, រីព្រះ បាទវិទេហរាជ ស្តេចទមិលមើលបក្ខីយនោះ ហើយមានព្រះបន្ទូលដណ្តឹង ព្រះមហាសត្វថា ម្នាលបាមហោសថ រីបក្ខីយនេះយល់មិនដូចអំពីមុនហ្ន៎ះ? ឥឡូវនេះ ហេតុអ្វីក៏មិនចុះមករកស្តេចហើយដណ្តឹងជាគាថាដូច្នេះថា :

ឆាយំ បុរេ ឧណ្ណាមតិ តោរណគ្គេ កកណ្ឌកោ
មហោសធ វិជានាហិ កេន ថទ្ធោ កកណ្ឌកោ ។

សេចក្តីថា: ម្នាលបាមហោសថអើយ, រីបក្ខីយនេះមិនចុះមកអំពីចុង តោរណៈឡើយ នឹកក្បាល ពួតក្អេង ជំកើងអាត្មាព្រងើយទៅវិញ; មហោសថអើយ បក្ខីយនេះមិញ ខ្វៃប្រជារឹងត្អឹងដូច្នេះ ហេតុអ្វី? ចូរ បាជីងហេតុនោះហោង ។

លំដាប់នោះ, ចៅអ្នកប្រាជ្ញស្តាប់ហើយ ក៏ជឿដោយនូវប្រាជ្ញាអធ្យាស្រ័យទូលថា បពិត្រមហារាជ រីបុរសដែលព្រះបាទអម្ចាស់ឲ្យចិញ្ចឹមបង្កួយនេះ នាំពីម្សិលមិញជាថ្ងៃឧបោសថសីល ដ្បិតឥតគេសម្លាប់សត្វ ក៏បុរសនោះរកចំណីមិនបានសោះឲ្យបង្កួយធំឡើយ, ក៏បុរសនោះយកមាសមួយក្រាមដំឡៃហាប់នោះមិញ មកដោតខ្សែត្របកបង្កួយនោះ ហេតុតែវាបានមាសមួយក្រាមនោះហោង វាប្រែជារឹងធ្អឹងវិញ ព្រះមហាសត្វស្រដីទូលស្តេចជាគាថាដូច្នេះវិញទៀតថា :

អលទ្ធបុព្វំ លទ្ធាន អឌ្ឍមាសកំ កកណ្ឌកោ
អតិមញ្ញតិ រាជានំ វេទេហំ មិថិលគ្គហន្តិ ។

បពិត្រមហារាជ! រីបង្កួយនេះ អំពីមុនមកវាមិនដែលបានមាស ក៏ឥឡូវនេះ លុះវាមកបានមាសមួយក្រាម ក៏វាមើលងាយព្រះបាទអម្ចាស់ ដ៏ជាព្រះមហាក្សត្រាធិរាជ ដ៏មានប្រាង្គប្រាសាទធំបំពេញដ៏កណ្តាលមិថិលាមហានគរ ដ៏រុងរឿងល្អ, ហេតុវាគិតដូច្នេះថា ព្រះបាទវិទេហរាជនោះមានទ្រព្យច្រើន, អញសោតក៏មានទ្រព្យច្រើន ។

ឯដ៏កាលនោះ ស្តេចឲ្យហៅបុរសរក្សាបង្កួយនោះមកដណ្តឹងសួរ ៗ បុរសនោះទូលដោយនូវពាក្យពិត ៗ ព្រះបាទវិទេហរាជ ស្តេចមានព្រះហឫទ័យជ្រះថ្លាក្រៃពេកក្នុងព្រះមហាសត្វ ហើយបន្ទូលសរសើរចៅ

អ្នកប្រាជ្ញថា ឮមហោសថអ្នកប្រាជ្ញនេះ ពុំបានដឹងមុនដល់តិច ក៏ស្រាប់តែមកដឹងអធ្យាស្រ័យចិត្តបុរសនេះ ហាក់ដូចប្រាជ្ញា សពេជ្ញតាញាណហោង ហើយស្តេចបើកស្រុកឲ្យជំទាវទាំង ៤ បូជា សឹងមានស្នូយវៃជាផ្ទាន់នៃព្រះពោធិសត្វទាកាលនោះហោង ។ ព្រះមហាក្សត្រ ស្តេចទ្រង់ភ្ញាល់ទឹងបុរសនោះ ផ្តោះទោសទឹងឲ្យក្ស័យជីវិតនោះ ។ ព្រះមហាសត្វអ្នកទូលឃាត់ថា បពិត្រក្សត្រថ្លៃប្រសើរអើយ នាសត្វបុរសតិបាននេះ មិនគួរគេប្រព្រះអង្គទឹងឲ្យធ្វើទោសឡើយ សូមព្រះអង្គអត់ទោសនៃសត្វបុរសនេះ ។ ព្រះមហាក្សត្រាធិរាជ កាន់យកនូវពាក្យព្រះមហោសថ ហើយក៏ស្តេចអត់ទោសបុរសនោះ ស្តេចឲ្យស្រាយយកមាសអំពីក ហើយលែងឱ្យបុរសនោះចេញទៅហោង ។

កាកណ្ឌកបញ្ហោ និដ្ឋិតោ ។ បពិត្រអើយ, រឿងស្រដីអាចប្រស្នាបុរសនេះមិញ ជាសុរេចនូវប្រការអម្បាលនេះឯងហោង ៗ

អថេកោ មិថិលវាសី បិង្គុត្តរោ នាម មាណវោ តក្កសិលំ គន្ត្វា ទិសាបាមោក្ខស្ស អាចរិយស្ស សន្តិកេ សិប្បំ សិក្ខន្តោ ខិប្បមេវ សិក្ខិ ។

បពិត្រអើយ, កាលនោះ មានបុរសមួយនៅកំឡុងក្នុងស្រុកមិថិលាមហានគរ ឈ្មោះបិង្គុត្តរមាណព ១ នោះឯង, ប្រាសលះលែងស្ទែងទៅ

រៀនសិល្បមន្តអាគម ឯស្រុកតក្កសីលាមហានគរអំពីបុរាណ ក្នុង
សំណាក់អាចារ្យទិសាបាមោក្ខព្រាហ្មណ៍ ចង្គុត្តរមាណពនោះឯង ទៅ
រៀនសិល្បសាស្ត្រឈ្លាសសព្វគ្រប់ចប់ស្រេចហើយ ចង្គុត្តរមាណពយក
រង្វាន់ខាន់ខៅទ្រព្យប្រដាប់ប្រដាគ្រូស្រេចហើយ ទើបលាគ្រូអាចារ្យទៅ
លំនៅតាត្វា ។ បពិត្រអើយ ក្សណនោះ វិទិសាបាមោក្ខាចារ្យ
បណ្ដាលនូវចិត្តគិតថា វិបូតិបវេណីសាស្ត្រគ្រូអាចារ្យយើង បើមានកូន
ច្បង គ្មានកូនប្រុសឡើយ មានតែកូនស្រីនោះ គប្បីទឹងរៀបធ្វើអាពាហ៍
ពិពាហ៍ផ្សំឲ្យជាប្រពន្ធសិស្សជាច្បងនោះឯងហោង ។ បពិត្រអើយ
វិអាចារ្យទិសាបាមោក្ខមិញ គាត់មានកូនក្រមុំមួយ ( ឈ្មោះនាងកុមារី )
ប្រកបនូវរូបនោះដ៏ទ្រង់នូវលក្ខណាល្អអស់ទាំងពួង បីដូចស្រីសួគ៌ មុខ
គួរតែចង់ពិតពិលរមិលមើល ។

អជ ធំ អាចរិយោ ធីតរំ ទេ តាត ឧសភ្ជមិ
តំ អានាយ គមិស្សសិតិ អាហា ។ លំដាប់នោះ វិទិសា
បាមោក្ខាចារ្យ គ្រអាលនូវពាក្យមេត្រីស្រដីទៅនឹង ចង្គុត្តរមាណពនោះថា
ម្នាលចង្គុត្តរមាណពអើយ រីនៅឯងជាសិស្សច្បងអញហោង, អញទឹង
យកកូនក្រមុំផ្សំជាប្រពន្ធនៃទៅ ក៏ចូរទៅធ្វើដោយនូវពាក្យអញហោង ។

(នៅមានត)

## ផ្នែកអក្សរសាស្ត្រ

# រឿងមរណមាតា

(តមក)

បើតាក្រោយ ពាន់លង់ទំលាយ នគរម៉េគ្រ ព្រះទាត ត្រោន់ ក្អែកមាន់កាមកេ កំស្លុលអន្ទើយ ក្អកនៅខាងក្រោយ ៗ ចេកទុំចេកទេស កំរើកនាងកែស នាងក្ងោស ណ្ដាយ សណ្ដែក ពង់ក្អួ បំព្រំទឹកបាយ ប្រមាត់ខ្លាខ្លាយ ក្រួចក្រាយរមាស ៗ ដំរីប្រាំ ដក ប្រមាត់ចចក កន្ទ្រង់ទ្រៀកព្រាស ទំលាយស្លង់ស្ពៅ ពកទូ ចេកមាស ក្បាលរុយអង្គា– ដីដង្កៀបក្តាម ៗ ត្បាល់ដៃកអង្រែ- ដៃកដើមជ្រៃជ្រ ប្រពាលប្រពាម តពេចចង្អា ក្តុលក្តារស្លាព្រាម ចំរូងព្រះពម ព្រះរកដៃកស ៗ ក្អែកទាស្វាកែត ចេមចង្អណ្ដែត ចេសចុងអង្ករ ក្រចកអណ្ដើក កំរើកកម្រ ដាក់ដើមសំណ សំណកពីងពាង ៗ កំទេចពពេល ពពុះទឹកសែល ចង្កូមស្ការ នាង ក្រចកក្រៀលក្រ ដកពព្រះលាង ព្រលប់ត្រើមនាង– ទូទទូ សត្វា ៗ ស្តុកស្ទុរស្តើស្ដៅ ឈើកែសតាត្រៅ កន្ទុំអាចម៍ខ្លា ត្រថុកត្រចៀង កណ្ដៀងឈាមក្រា រំដេង ប្រះស្វា ព្រះស្វិត

តាខ្មៅ ៗ អណ្ដាតត្រកួត ដំរីចង់ចូត ស្រឡូកស្រឡៅ សម្បក ពពេច កំះទបឈើខ្មៅ គោមួយប្រឡៅ អំពិលពោធិ៍បាយ ៗ ឯឈើគ្រឿងទេស ថ្នាំទិព្វវិសេស វិសាលឆើតឆាយ បើមានរោគា គ្រាំគ្រាក្នុងកាយ យកឈើទាំងឡាយ ផ្សំតាមតម្រា ៗ ស្ងោរផឹកជា សះ ជូរខ្ទង់ល្អណាស់ ចូលបាយណាស់ណា ពោះក្លួនប្រជិត រង់រឹតកាយា រាក់ជ្រេញក្តីណា ឫសដូងវិលមុខ ៗ ក្អកក្អួតរបង ខ្សោះខ្សាបសម្ងួន កួនហល់ទល់ចុក ចុះរាកមួលសាញ អផ្ញាញ អផ្ទក អផ្ទង់ពំលក់ ប្រមេះទឹកបាយ ៗ គ្រុនស្រៀវញាក់ ញាប់ ប្រមេះមានគ្រាប់ យូងស្រែងទាំងឡាយ ដំបៅពកពួច បារូបខ្មោចព្រាយ អាបចូលរាយមាយ សន្និបាតមាត់ ៗ យកដើមប្រពាក់ ស៊ុកមួយមកដាក់ ខ្មោចស្ទះរតបាត់ ក្រេកឡើង ចាស៊ី ជម្ងឺខ្លាយខ្លាត រោគាក៏បាត់ អាយុយឺនក្រៃ ៗ

ព្រះបទុមវង្ស កាលព្រះអង្គទ្រង់ រៀនសិល្បសាស្ត្រសៃយ រៀន ចប់ត្រៃវេទ សាស្ត្រសេដ្ឋចាប់វៃ ឥសីសីលក្រៃ ប្រដៅបានបទ ៗ ក្បួនខ្នាតគុណហារ ថ្នាំរោគតម្រា បេះឃ្នាត់ប្រាកដ ប្រពាលគជ់គង់ ព្រះអង្គបេះហ្មត់ បារតបៀមអត់ – បាយបានដប់ថ្ងៃ ៗ សព្វសិល្ប សាស្ត្រា សក្តិសិទ្ធិក្បៀវក្លា លើសលោកភពត្រៃ ព្រះអង្គប្រាប់ថ្នាំ ខ្វះ

ចាំអាក្រៃ យកមកសំចៃ បំរុងអាត្មា ៗ អស់ពលទាំងឡាយ ដើរលេង សប្បាយ ស្កប់ស្កល់ចិន្តា ស្រេចហើយប្រៀបប្រុង រៀបវង់ក្សត្រា ទុក ស្បៀងអាហារ គ្រប់ក្រុមទីទៃ ៗ ពួកនាយដំរី រៀបរង់ហត្ថី គ្រឿងគ្រប់ ប្រពៃ ពួកនាយរថ អាសាអាជានេយ្យ រៀបរថពិជ័យ ចងគ្រឿង រចនា ៗ នាយសេះចងអាន ចងគ្រឿងគ្រប់ប្រាណ សឹងរ័ត្នរេខា ពល ថ្មើរជើងជាតិ រៀបស្អាតកាយា ទ័ពស្បៀងអាហារ រៀបរង់គ្រប់ ប្រាណ ៗ រទេះដឹកស្បៀង ដឹកគ្រឿងរៀបរៀង រៀបរង់ក្សត្រក្សាន្ត រទេះព្រះស្វាយ រៀបដោយពួកបាន ក្រវីនគ្រប់ប្រាណ គ្រប់តួគ្រប់ គ្នា ៗ ដំរីទីនាំង ចងគ្រឿងគ្រប់ទាំង ប្រដាប់រចនា ក្បូរក្បាច់ផ្ទុះផ្ទុក ល្អឯកជ្រះថ្លា ចាំងសែងសុរិយា ព្រាក ៗ ស្មើ ៗ ព្រះពជយាន កើយ កែវសូរ្យកាន្ត រៀបរង់ចក្រី ព្រះកុស់មូលក្ខុំ អភិម្យរង្សី គ្រប់ក្រុម សេនីយ រៀបរួចប្រុងប្រាណ ៗ ព្រះមហាក្សត្រថ្វៃ ប្រពាតព្រឹក្សព្រៃ សប្បាយក្សេមក្សាន្ត បានមួយខែគត់ កំណត់ប្រមាណ ស្តេចលើកទាហាន ចូលក្រុងភាព ៗ ពួកពលទាហាន បានដល់ទីឋាន ឃើញបុត្រភរិយា សួរញាតិសន្តាន ព្រៀងលានគ្រប់គ្នា រៀបភ័ស្តុជាជា ចងដៃត្រេកអរ ៗ សេនាមន្ត្រី ហៃក្សត្រធិបតី ចូលក្នុងនគរ នាហ្មឺនក្នុងវាំង តាំងគ្រឿងបវរ ទទួលស្តេចបវរ ចូលវាំងរចនា ៗ សម្តេចក្សត្រី អាឃិអគ្គមហេសី មរណ-

មាតា ដល់ស្រេចហើយនាង យាសយានយាត្រា ទៅក្រាបវន្ទា សុវណ្ណពជព្រឹក្ស ៗ ទៀនធូបភ្ញីផា គោជនវក ជូនបន្ទន់ទូវទឹក-អប់ ក្រអូបសាយ នាងថ្វាយពជព្រឹក្ស ស្រេចហើយស្រោចទឹក ក្រអូបក្លិនសាយ ៗ ស្រេចហើយព្រះនាង វិលវិញបំភាន ឡើងប្រាង្គទើតឆាយ ខុនណានចាស់ទុំ ស្ទិទស្ទំអករ៍យាយ ឡើងតាល់រៀនពយ សាគរសួរសន្ធនា ៗ សួរសព្វទុក្ខសោក ដកបដល់មក បូលក្រុងកាក នាងសោតរៀបរាប់ សាសព្វនានា អករ៍យាយស្រីង្គារ ស្តាប់ហើយខ្សឹកខ្សួល ៗ សង្វេគអនិច្ចា អាណិតជីតា ទ្រាអន់អួល អនអាកអាណិត ក្តុនចិត្តរំជួល ដង្ហើមខ្សឹកខ្សួល ជោរជលនេត្រា ៗ ស្រេចហើយជូតមុខ កំសាន្តនៈសោកទុក្ខ រករៀបទុជា- រសៃតនព្រះស្នាយថ្វាយដោយមុខង៉ារ រៀបថ្វាយរាជា នឹងអគ្គមហេសី ៗ ហើយគន់មើលអង្គ លម្អលម្អះត្រចង់ ដូនក្ព្រែបមប្រើយ ទើតឆាយលើសមុទពាន់គុណទៀតខ្ញី មើលភ្ញូបស្នាតើ ពុំដូនអាត្មា ៗ ខ្វះថាម្ចាប់យើងលម្អប្លែកថ្កល់ថ្កើន ដូចស្រីទេព្តា មើលហើយមើលទៀត មិនឆ្អែតនេត្រាស្ទំខ្ញុំទូលថា អម្ចាស់មានបុណ្យ ៗ ទ្រង់សោយថ្នាំអ៊ី ប្រកបសិរី ព្រះអង្គលើសមុន នាងប្រាប់កិច្ចការ សព្វសារៈពីគុណ ថ្នាំទិព្វលើសលន់ពុំមានមុសា ៗ អស់ស្នំទាំងឡាយ ស្រីង្គារអករ៍យាយ បានស្តាប់ជីតា

សព្វគ្រប់សេចក្តី ឥតថីសង្កា សរសើរវាសនា ក្សត្រកល្យាណ ។
នាហ្មឺនតូចធំ ឡើងគាល់ជួបជុំ ទូលសួរស្មោះស្មាន ហើយថ្វាយកស្តុ
ការ ពស្ត្រាគ្រប់ប្រាណ ថ្វាយនាងកល្យាណ ច្រើនឥតឧបមា ។ ខ្លះ
ថ្វាយប្រាក់មាស ត្បូងកែវពេញពាស កោសេយ្យកោសា ទទុម្ពរ័ត្ន និល
ផាត់ផុះផ្កា លូកករហត្ថា ដញ្ញាត់ព្រលឹង ។ ភ្លេងជួរជន្ត្រី ត្រែស័ង្ខ
ខ្លុយប៉ី សូរសព្ទទ្រហឹង ថ្វាយជ័យមង្គល សកលអ៊ឹងអ៊ឹង ស្រេចហើយ
វិលវិញ ឋានគ្រប់អាត្មា ។ ព្រះបាទវិមល ធម្មកដ៏ថ្កើងថ្កល់ បរម
ក្សត្រា នៃបទិងមហេសី សិរីសេដ្ឋា ក្សេមក្សាន្តសុខ មនោរមេ ។ ទើប
ស្តេចប្រទាន ប្រាសាទមាសមាន រូតរ័ត្នបាន ព្រះបទុមវង្ស ស្តេចគង់
សុខស្នេហ៍ ប្រទានពលរេហ៍ បំរើបុត្រា ។ រីរូបមន្ត្រី ឈ្មះឈ្មប្រិម-
ប្រើយ សុខសិនកញ្ញា ប្រាំយស្អិតស្អាង គ្រប់នាងធីតា បំរើបុត្រា
សព្វថ្ងៃប្រក្រតី ។ ក្មេងប្រុសមួយពាន់ ឡើងគាល់តាមតាន់ ភ្លេង
ជួរជន្ត្រី ក៏លៀងមេទិ ជួបជុំប្រក្រតី អស់ទាំងមន្ត្រី ឡើងគាល់
បុត្រា ។ ព្រះបទុមវង្ស ថ្កល់ថ្កើងទ្រើសទ្រង់ រឹតរឹងក្លៀវក្លា ព្រះបិ-
តាទ្រង់ ថ្នមបុត្រថ្ងៃថ្វា មិនឲ្យបុត្រា អន់អាក់ព្រះទ័យ ។ ឯនាង
ធីតា នាំពជបុត្រា ឡើងគាល់ក្សត្រថ្ងៃ ឯព្រះពជបុត្រ បរិសុទ្ធប្រពៃ
គាល់មាតាថ្ងៃ តាមក្រឹត្យក្សត្រា ។ សម្តេចមហេសី បរមក្សត្រី

នាងទ្រង់ចិន្តា គិតគុណគណ្ឋារ វិមលថ្លៃថ្លា លុះនាងយាត្រា ទៀង
គាល់ស្វាមី ។ នាងទូលរៀបរាប់ សេចក្តីសាសព្ទ កាលជាបក្សី បាន
ស្តេចគណ្ឋារ យន់យល់មេត្រី មេត្តាប្រណី បានរស់រូបា ។ ឥឡូវ
ខ្ញុំសុំ ពរក្សត្រឧត្តម សូមទ្រង់មេត្តា ប្រាមប្រាប់អស់រាស្ត្រ ទាំង
ផ្តាសនានា កុំឲ្យហឹនវា គណ្ឋារទាំងឡាយ ។ ស្តេចស្តាប់មហេសី
ទូលទើបចក្រី បន្ទូលប្រាប់ប្រាយ ប្រាប់អស់មន្ត្រី សេនីយទាំងឡាយ
ឲ្យពេញប្រញាយ គ្រប់ខេត្រគ្រាមា ។ ឲ្យវាយគងប្រាប់ អស់រាស្ត្រ
ធ្វើក្រាប់ កុំឲ្យពាធា គណ្ឋារតូចធំ ត្រូវកុំវាយវា ឲ្យក្ស័យជន្មា គណ្ឋារ
ទាំងនោះ ។ ថាបើពុំតាម ពុំស្តាប់បំរាម ច្បាប់ថាត្រូវកោះ យកមក
លក់ថ្លៃ យកថ្លៃខ្លួននោះ ជាប្រាក់បំពោះ មួយពាន់ដំឡឹង ។ អស់
រាស្ត្រជិតឆ្ងាយ ក្នុងក្រៅបន្ទាយ ពុំហ៊ានរបឹង ឥមាត្យប្រាប់សព្វ គ្រឡប់
វិលវិញ គណ្ឋារបានខពឹង ដោយបុណ្យក្សត្រា ។ សម្តេចក្សត្រី គាប់
អគ្គមហេសី បរិសេដ្ឋា នាងទ្រង់ជញ្ជឹង រំពឹងគនិច្ចា គិតថាសង្សារ
ពិតពុំទៀងទាត់ ។ ប្រាកដដោយភ័យ ដោយទុក្ខសង្រៃ សង្រេង
ក្តៅក្តាត់ មានក្តីអន្តរាយ ខ្វាត់ខ្វាយបង់បាត់ បានសុខចិត្តក្តាត់ តប
ក្តីសប្បាយ ។ នាងគិតយល់ច្បាស់ ប្រាកដពេកណាស់ ពិតនឹងព្រះ
កាយ ច្បាស់នឹងព្រះនេត្រ យល់ហេតុទាំងឡាយ នាងពុំសប្បាយ

ទីងសង្សាក ៗ គិតស្រេចក្សត្រី យកទ្រព្យពិសី ប្រដាប់ប្រដា ឲ្យ
ទៅជាទាន ពុំមានរញ្ញក ដំណើរគិតជា មាសផ្លូវបរិសុទ្ធ ៗ សែន
ចូនពុំខាន ដំរីផ្ទៃមែនខាន មួយថ្ងៃចំហុត មានកេងសង់នៅ ទ្វារ
ក្រៅបំផុត ទ្វារទាំងបួនសុទ្ធ សឹងកេងដាក់ទាន ៗ អស់សម្ប
កំសត់ គោកយាកទុគិត ជិតឆ្ងាយសឹងមាន ចិត្តត្រេកសាទរ ស្មោះ
សគ្រប់ប្រាណ ទទួលព្រះទាន ប្រទះទ្រព្យល្អ ៗ ហេតុដោយជា
ពស្ត្រ មិនដែលបានមាស ប្រាក់ប្រុះកុះករ ហូលព្រែបរបាប់ ចំណាប់
ល្អ ៗ ធ្លាប់ជាអ្នកក្រ ពាក់ចិញ្ចៀនស្លាន់ ៗ ប្រទះបានមាស ដាក់ត្បូង
ធ្នុះធ្នាស យ៉ាងល្អសំខាន់ ត្រេកអរសេនូប់ ចប្រប់កាំងកាន់ ខ្ទះបាន
ទោខាន់ កាសាយមនា ៗ តាមចិត្តចង់បាន ត្បូងកែវសូរ្យកាន្ត របស់
ជា ៗ គ្រឿងប្រើបានស្រាប់ ប្រដាប់ពល់គ្នា ចំណីកស្តារ បរិភោគ
សឹងបាន ៗ សម្តេចមហេសី បរមក្សត្រី ប្រសើរថ្កើងថ្កាន ឲ្យសង់
សាលា នៅនាក្រៅវាំង ទិសទាំង ៤ បាន មាននាយរក្សា ៗ
សំរាប់សំណាក់ អាគន្តុកៈ ដើរមកកាលណា ឲ្យក្រាលចៀមចំ ព្រែ
ព្រំពស្ត្រ កម្រាលអាស្នា តែសព្វៗថ្ងៃ ៗ ព្រឹករៀបចង្ហាន់ ប្រគេន
ឡូឆាន់ ព្រមទាំងបច្ច័យ ទាំងបួនប្រគេន មែនមានដំឡៃ ចតុបច្ច័យ
ប្រគេនគ្រប់អង្គ ៗ ហើយមហាក្សត្រី ស្មាទានប្រក្រតី សីល ៥

ពុំបង់ ឧបោសថបាន ស្នាទានផ្ចិតផ្ចង់ សព្វសីលហើយទ្រង់ សង្រួម
កាយា ៗ ហើយនាងនឹកគុណ ទេព្ដាពីមុន ដែលប្រោសអាត្មា
ទើបនាងឱ្យមាន សង់កនទេព្ដា ទាំងបួនទិសា ពីការប្រក្រតី ៗ នាង
នឹកដល់គុណ កណ្ដុរសមុទ កាលជាបក្សី ហើយនាងចាត់ចែង ជូ
ជាចំណី កណ្ដុរក្នុងដី លើផ្ទះក្ដីណា ៗ នាងឱ្យចំណី ចេកទុំនំ
ក្ដី គ្រប់គោជនា ឱ្យទានកណ្ដុរ ស្កប់ស្កល់គោក្ដា សព្វថ្ងៃគេក្រ ពុំ
ដែលខានខាន ៗ នាងនឹកគុណទា ដែលពាំស្រកា ត្រីពីលោកបាន
ទុកឱ្យស្រីថ្ងៃ ប្រពៃកល្យាណ នាងរៀបឱ្យទាន ទាបរុំគោក្ដា ៗ
នាងនឹកដល់ឆ្មា ពាំបុសរុក្ខា ឱ្យកាលនោះណា នាងរៀបចំណី ពិ
សីពិសា ឱ្យឆ្មាគោក្ដា សព្វថ្ងៃប្រក្រតី ៗ ទោះជ្រូកមានទា កណ្ដុរ
ឆ្កែឆ្មា ក្អែកសត្វអ្វី ៗ នាងឱ្យអាហារ គោក្ដាប្រក្រតី សព្វសត្វអ្វី ៗ
តិរច្ឆាននានា ៗ ទោះមនុស្សប្រុសស្រី ចង់បានទ្រព្យអ្វី ព្រះកជ·
ធីតា តើបឱ្យតាមចិត្ត គន់គិតប្រាជ្ញា ត្បិតកែវមុក្ដា កញ្ញាបសិទ្ធ ៗ
សព្វគ្រប់ធនធាន ក្សត្រីពុំមាន កំណាញ់ទ្រព្យអ្វី បាយទឹកគោក្ដា
អាហារចំណី ក្មេងចាស់ប្រុសស្រី យកបានគ្រប់គ្នា ៗ អ្នកក្សត្រជាមាន
ដោយសារព្រះទាន ក្សត្រីសោភា អស់អ្នកនគរ សាទរមហិមា
បានអស់ពលគ្នា ស្កប់ចិត្តឆ្អែតឆ្អល់ ៗ និទានតាំងត ខែឆ្នាំមួយមក

កាលនាងទិមិ.ប កើតជាសារិកា កោក្តាក់សុផល ដកបមកដល់ បាន ជាមនុស្ស ៗ បានរៀបអភិសេក ជាក្សត្រឯក គ្រប់ស្នំបរិវារ នាង គិតគុណគ្រប់ សព្វសត្វទេព បរិបូណ៌កូលជា ខ្សែប្រាំពីរពិត ៗ

## រឿងមរណមាតាបប់តែប៉ុណ្ណោះ

# កណ្ឌទី ៤២

ឧកញ៉ាវិបុលរាជសេនា នូ-កន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាសបើបានអាន
នឹងបេះឧបាយកលបំណាន
ទាំងមានសត្តានស្នេហាជាតិ។

ម៉ាអៀនឮហើយខឹងណាស់ បរសេះចូលទៅប្រយុទ្ធគ្នាមិនទាន់ទាំងបានប៉ះពាល់ដល់អាវុធផង កាំឡេងក៏បកដាវមុខមុតកាប់ម៉ាអៀនដាច់ពាក់កណ្ដាលខ្លួនធ្លាក់ពីលើសេះស្លាប់ ទៀវគីស្ទុះចូលទៅប្រញាប់តនឹងកាំឡេងទៀត កាំឡេងក៏បរសេះចូលប្រយុទ្ធនឹងទៀវគី ហើយស្រែកដោយសំឡេងសន្ធាប់យ៉ាងខ្លាំង ទៀវគីក៏ភ័យស្លុងកាំងគេចរត់មកក្រោយ កាំឡេងដេញទាន់ទៀវគីទឹមស្មា យារដាវឡើងកាប់ត្រូវទៀវគីស្លាប់ពីលើសេះធ្លាក់ចុះ ទាហានទាំងអស់ក៏បែកខ្ញែករត់ព្រាត់ព្រាយវិលទៅប្រាប់ចូចូ ។ ឮហើយក៏នាំទាហានរត់វាំងគម្រង់ទៅផ្លូវហាន់ហ៊ុយ ។

ឯស៊ុនគួនដែលលើកទ័ពទៅតាំងនៅជំរុំអ៊ុយតេនោះ លុះឃើញពន្លឺភ្លើងឆេះឡើង ត្រង់ឆ្ងាយទាហានចូចូគឺសោមទស្សនាណាស់ គិតថា គ្រានេះជីវយើធ្វើការមានជ័យជំនះចូចូហើយ ទើបប្រើឲ្យក្រុមស៊ុនឲ្យអុចភ្លើងឡើងជាសំគាល់ ។ លុះថៃស៊ូជូទៅជួបនឹងស៊ុនគួន ។ ក៏ឲ្យក្រុមស៊ុនទីងថៃស៊ូជូប្រមូលទាហានចូលគ្នា ហើយលើកស្រុតទៅជួបនឹងជីវយើយកជ័យជំនះចូចូឲ្យបាន ឲ្យកស៊ុនទីងថៃស៊ូជូក៏លើកស្រុតទៅស្នាក់ផ្លូវចូចូ ។ ឃើញកងទ័ពក្រុមស៊ុនទីងថៃស៊ូជូលើកទៅស្នាក់ពីមុខ ក៏នាំទាហានរត់កាត់ចៀសផ្លូវទៅត្រង់ជំរុំអ៊ីឡេង ទទួលប្រទះនឹងកងទ័ពទៀតទាប់ចូចូក៏ឲ្យកងទ័ពតស៊ូពីខាងក្រោយជាមួយនឹងទៀតលៀវ ហើយបរសេះរត់សៀវពងទៅមុខ លុះជិតភ្លឺស្រាងក្រឡេកមើលទៅក្រោយ ឃើញពន្លឺភ្លើងឆ្ងាយណាស់ ក៏ធូរស្រាលក្នុងចិត្ត ទើបងាកមកសួរទាហានទាំងពួងថា ទីនេះឈ្មោះជំរុំអ្វី ? ។ ទាហានឆ្លើយថា មកដល់នេះជិតដល់ជំរុំហ៊ូលីមហើយ ។

ចូចូឮដូច្នោះ គិបន្តិបរសេះនាំទាហានទៅតាមផ្លូវប្រកក្ខ, ឯទីនោះជាព្រៃរហោឋានធំណាស់ ចូចូងើបមើលលើហើយអស់សំណើចជោយសំឡេងខ្លាំង អស់ទាំងទាហានឮដូច្នោះក៏ជំពប់សួរថា គ្រានេះបរាជ័យសឹកសង្គ្រាមរត់មក មហាចបកជះសើចដោយហេតុអ្វី ? ។ ចូចូឆ្លើយថា

យើងសើចនេះព្រោះឃើញថា ជម្រិះរិះគិតរបស់ខុនបេនទឹងដាវយ៉ែនោះ តិចពេកណាស់ មិនសមនឹងល្បីដែលឮ បើជាយើងធ្វើការដូចខុនបេនទឹងដាវយ៉ែវិញ យើងត្រូវចាត់កងទ័ពមកចន្លប់ក្នុងព្រៃនេះ កាលណាសត្រូវរត់រួចនឹងដៃយើង នេះខុនបេនដាវយ៉ែមិនចេះគិតដូចយើងសោះ លុះថាល្ងាចផុតមាត់ទទួលឮស្គរជាវ ទឹងស្គរមនុស្សស្រែកហោអុចភ្លើងឆេះឡើងទាំងសងខាងផ្លូវ ទាហានក៏ស្ទុះស្រូវចេញទៅជាច្រើនណាស់ ជូឡុងស្រែកមកទៀតថា ខុនអញឈ្មោះជូឡុង ខុនបេនប្រើឲ្យមកចាំស្កាត់ចាប់អាសត្រូវកជសម្បត្តិសម្លាប់ចេញ ចូឆូឮដូច្នោះក៏ភ័យណាស់ ស្ទុះបរសេះថយមកក្រោយ ឲ្យទៀវលៀវៈ ទៀវខាប់ចូលប្រញាប់តនឹងជូឡុង ៗ ចូឆូក៏រត់លឿនស្ទុះទៅក្រោយបណ្ដោយផ្លូវទៅស្រុកកេងដាវ ៗ

ខណៈនោះ ចូឆូខុបខាតទាហាននឹងសេះហើយនឹងគ្រឿងសស្ត្រាវុធច្រើនណាស់ខ្លះដែលរួចរស់ក៏ដោះខ្លួនរត់តាមចូឆូទៅ ៗ ឯជូឡុងនឹងពលទាហានក៏ចាប់បានសេះនឹងគ្រឿងសស្ត្រាវុធទុកជាច្រើន ៗ កាលចូឆូរត់ទៅនោះ ខ្យល់សលាត័នក៏បក់បោកមកមិនឈប់ តាំងពីពេលព្រលប់ចាល់ភ្លឺស្រាង ភ្លៀងក៏ធ្លាក់យ៉ាងធំ ៗ លុះភ្លៀងរាំងហើយ, ទាហានទាំងអស់ក៏នាំគ្នាទៅវាយដណ្ដើមយកបាយ ទឹកចំណីអាហាររបស់អាណាប្រជានុរាស្ត្រអ្នកស្រុកមកបរិភោគ ៗ ចូឆូក៏បានប្រទះគ្នានឹងខៅជូ ស៊ុឡុង

នូវពួកទីប្រឹក្សាជាលំដាប់ប្រហែល ៤–៥ នាក់ ក៏បានធូរស្រាលក្នុងចិត្ត បាត់ព្រួយហើយសួរទាហានថា ព្រៃនេះឈ្មោះអ្វី ? ។ ទាហានឆ្លើយថា ដែនព្រៃដំបន់អ៊ីឡេងបែកជា ២ ផ្លូវ ។ ចូច្ចូសួរថា យើងទៅស្រុកឡាំកុងទីងទៅតាមផ្លូវណាឲ្យរហ័សឆាប់ ? ។ ទាហានឆ្លើយប្រាប់ថា ទៅផ្លូវក្រោមឆាប់ដល់ជាងផ្លូវលើ គាត់ដម្រង់ចេញតាមមាត់ផ្លូវទៅដំបន់ហោលោកុក ។ ចូច្ចូព្វង់ហោះក៏នាំទាហានស្រូតទៅ លុះទៅដល់ដំបន់ហោលោកុក ឃើញទាហានទាំងឡាយនឿយហត់អស់កំឡាំងណាស់ ក៏ឲ្យឈប់សម្រាកកំឡាំងទីងដាំបាយទឹកបរិភោគ ហើយឲ្យសម្លាប់សេះវះយកសាច់ចែកគ្នា បណ្ដាទាហានក៏ដោះអាវដោះក្រើះគ្រឿងប្រដាប់ហាលថ្ងៃឲ្យស្ងួត ហើយក៏ចងសេះឲ្យស៊ីស្មៅ ។

ខណៈនោះពួកទាហានទាំងអស់ក៏នាំគ្នាបោះពៅដាំស្ល បាយទឹរ សម្លមិនទាន់ឆ្អិននៅឡើយ ឯចូច្ចូក៏អង្គុយនៅក្រោមម្លប់ឈើក្រឡេកមើលលើហើយសើចម្ដងទៀត ។ ទាហានទាំងពួងក៏ភ្ញាក់សាកសួរព្រោះមន្ទិលសង្ស័យថា កាលជិតក្ដីមុននេះយើងសើចម្ដង ហើយថាខុងបេងនិងជីវយីមិនចេះគិត ជូឡុងចេញពីព្រៃងឹតមកចោមរោមចាល់តែអន្ទាក់យកអស់ រត់ដោះខ្លួនទើបមកដល់ទីនេះ មិនទាន់អស់ហត់ផង ឥឡូវហេតុម្ដេចលោកមកសើចដល់ ២ ដងដូច្នេះ ។ ចូច្ចូថា ដែលយើង

សើចទេះ ព្រោះឃើញថាគំនិតគិតរបស់ខុង ចង់ទីងដីរឃើនោះតិចណាស់ ធ្វើការមិនឲ្យប្រហូតធ្លុះធ្លាយ បើដូចខ្លួនយើងបានធ្វើការសម្លាយដូចគេវិញ ដូច្នេះ យើងនឹងបេះបាតកងទ័ពមកបង្កប់ចាំនៅមាត់ផ្លូវនេះ ១ ក្រុម បើសត្រូវគេមកប្រជុំតាមផ្លូវនេះ គឺនឹងចាប់ខ្លួនបានដោយងាយ លុះនិយាយផុតមាត់ ទទួលឃើញភ្លើងឆេះព្រោងប្រុះគ្រប់ទិសទាំង ៤ សំឡេងទាហានក៏ស្រែកហៅ ហោផ្លូនលើកចេញមកស្ទាក់មាត់ផ្លូវ ១ កង ពីមុខពីក្រោយខ្លួនក៏ចេញមកទៀត ព័ទ្ធជុំវិញទាំងអស់ច្រើនណាស់ ៗ ឯទៀវហ៊ុយក៏ស្ទុះមកស្រែកថា អាចូចូជាសត្រូវផែនដី ខុងបេងឲ្យអញមកចាំស្ទាក់ផ្លូវនៅនេះ មួងនេះមុខជាអាឯងមិនរួចពីដៃអញទេ ៗ ចូចូក្រឡេកឃើញទៀវហ៊ុយប្រែកផ្លូវច្បាះ កំលោះព្រលឹងស្មារតី រវៀសរវៃលោតឡើងសេះនាំទាហាន ៤-៥ នាក់ស្ទុះរត់ទៅមុន ឯទាហានក្រៅពីនោះក៏ស្ទុះរត់ទៅមុនបែកខ្ញែកគ្នាទៅតែខ្លួ, ទៀវលៀវទីងសុំឡុងតតាំងច្បាំងនឹងទៀវហ៊ុយការពារពីក្រោយ ហើយដោះរត់ទៅតាមចូចូ ទាហានទៀវហ៊ុយក៏ដេញកាប់សម្លាប់ យកបានគ្រឿងអាវុធនឹងសេះច្រើនណាស់ ទៀវហ៊ុយក៏មិនបានដេញដិតដោយចូចូទៅ វិលត្រឡប់មកក្រោយវិញ ៗ

ឯចូចូលុះរត់ទៅឆ្ងាយហើយ ក្រឡេកឃើញទាហានរបស់ខ្លួន

ដែលគាមមកនោះត្រូវអាវុធរបួសពិការគ្រប់គ្នា កំសួរទាហានទាំងពួងថា យើងនឹងទៅស្រុកឡាំកុននោះ ទៅផ្លូវណាទើបឆាប់រហ័ស ? ។ ទាហានខ្លះឆ្លើយថា ផ្លូវកាត់នោះតូចរហ័សជាងផ្លូវធំ ៤០០ សិន តែថាផ្លូវកាត់ដើរទៅពីបាក ព្រោះជាទីប្រកក្មមានដុំថ្មថ្មុកចង្អុកជាច្រើន ចាំខ្ញុំបាទប្រូតទៅមើលខាងផ្លូវកាត់សិន ទាហានម្នាក់ទៅក៏ឃើញមានភ្លើងឆេះត្រង់ផ្លូវនោះ វិលមកប្រាប់ចូចូវិញ ។ ចូចូក៏ប្រាប់ថា ត្រូវយើងទៅតាមផ្លូវកាត់ដែលមានភ្លើងឆេះនោះវិញ ទាហានថា ផ្លូវកាត់ដែលមានភ្លើងនោះ ខ្ញុំបាទឃើញថាពួកសត្រូវ នឹងមកបង្កប់ពួន នៅទីនោះជាប្រាកដ ហេតុម្តេចបានជាលោកនឹងឲ្យទៅផ្លូវនោះវិញ ។

ចូចូថា យើងដឹងថាគំនិតខុងបេងគិតនោះ ប្រុងនឹងបញ្ឆោតយើងទើបក្លែងឲ្យយកភ្លើងមកគរដុតនៅមាត់ផ្លូវកាត់ ហើយយកទាហានទៅបង្កប់ទុកខាងផ្លូវធំ បំណងនឹងឲ្យយើងគិតខ្លាចខាងផ្លូវដែលមានគំនរភ្លើងនោះ នឹងមានទាហានពួនបង្កប់តែជាយពិតនោះដូច្នេះទេ គឺប្រាកដជាមានទាហានបង្កប់នៅខាងផ្លូវធំ ។ ទាហានពួកចូចូឮដូច្នោះ ក៏យល់ឃើញដូចចូចូថាទាំងអស់គ្នា នាំគ្នាម្នីម្នាគេចជ្រមង់ទៅតាមផ្លូវកាត់ ដែលមានគំនរភ្លើងដុតនោះវិញ ។

កាលចូចូរត់ទៅនោះ អស់ពួកទាហានសឹងតែមានរបួសពិការ

ដោយគ្រឿងសស្ត្រាវុធជាច្រើន មានសេចក្តីលំបាកណាស់ ខ្លះក៏រមៀល ហត់ដោយអត់អាហារ ខំស្រូតដើរទៅស្ទើរមិនរួច ខ្លះក៏ល្ហួលលបឈប់ ក្រោមម្លប់ឈើ ខ្លះក៏ដើរចូលផ្ទះដោយប្រកក្ខ ខ្លះក៏យំប្រយ៉ាំគ្នា ប៉ុច្ឆ អាក់អួលសួរថា ហេតុម្តេចបានជាគ្នាស្រែកទៀតឆាប់ គេហានតក់ឆ្លើយ ប្រាប់គ្នា ៗ ថា ព្រោះឃើញចាប់ផ្ដើមរបួសពិការ, មានគំនិតចាយជាប់ ស្រយាលណាស់ ទំស្លុះស្លៀងដើរកាត់ផ្លូវបង្ហូរច្បាប់សិនតែឫស្សឈើ តាំងតាំងមកតាមផ្លូវ ព្រោះពីព្រឹកធ្លាក់ភ្លៀងមកត្រូវផ្លូវគំរអិលភក់ជ្រុំ ដោយរលុងអណ្ដែងពិបាកណាស់ ទាំងសេះទាំងមនុស្សក៏ពិបាកដូចគ្នា បានជាពាក់រកប្រកែកគ្នាទៅដូច្នេះ ។

ប៉ុច្ឆពួជ្ជបោះខឹងណាស់ថា កាលពីដើមយើងខឹងលើកកងទ័ពមក នោះ ទាំងអស់គ្នាសុទ្ធតែសុំយកកាសាថាខឹងតស៊ូធ្វើចម្បាំង ត្រាតែអស់ ជីវិត ពោះបក្កខឹងទ័កមកប្រាំងជិតនៅពីមុខក៏ត្រូវតែតត្រសុកចូលទៅឲ្យ ដល់ គួរខឹងធ្វើបណ្ដោងចងស្ពានថ្នល់ធ្លងទៅក៏ត្រូវតែធ្វើឲ្យបាន មិនត្រូវ ឈប់ខានឲ្យយូរការ ឬអ្នកទាំងអស់គ្នាកោតខ្លាចញញើតណាស់ទៅ ហើយ ប៉ុច្ឆនិយាយហើយ ក៏ហៅមនុស្សដែលឈឺរបួសនោះក្រោក ដើរមកពីខាងក្រោយ ឲ្យពួកហានដែលដើរមុនកាប់ឈើរមកជំរៀបរាយ លើផ្លូវភក់ដីរលុងអណ្ដូង ឲ្យសេះទាំងហ្វូងដើរទៅជាស្រួលបាន បើអ្នក

ឯណា ឈប់ខានមិនព្រមធ្វើតាម ត្រូវឲ្យកាត់ក្បាលទុកជាបំរាមគេទៅ ហើយឲ្យទៅជួប, សុំឲ្យនាំទាហានត្រួតត្រាការពារពីក្រោយ ហើយឃើញអ្នកប្រុសឯណាមិនចំដើរ ឬណាក្លាយឲ្យយឺតយូរ គឺត្រូវឲ្យសម្លាប់ចេញកុំឲ្យសត្រូវមកជួបប្រទះឃើញឲ្យសោះ ។ ពួកទាហានអម្បាលណោះ ក៏បឹងតែធ្វើតាមប្តូរបង្គាប់ ។ ប្តូរក៏បង្ខំកងទ័ពឲ្យស្រូតដើរទៅ ខណៈនោះទាហានទាំងពួងក៏ចំស្រូតរូតដើរពារប៉ះលើគ្នា ពួកដែលប្រុសពិការក៏ដួលស្លាប់ទៅខ្លះ ៗ ដែលចំដើរទៅមិនរួចសោះ ទាហានទាំងនោះក៏សម្លាប់ចោលទៅខ្លះ ពួកប្រុសក្រៅពីនោះក៏ចេះតែភ័យខ្លាច នាំគ្នាស្រែកយំរងំតាមផ្លូវទៅ ។

ប្តូរឮសំឡេងយំសោកដូច្នោះ ក៏ខឹងណាស់ស្រែកថា ហេតុម្តេចបានជាទាំងគ្នាយំរងំសោកដូច្នេះ ការដែលរស់ទឹងស្លាប់នោះក៏ស្រេចតែបាប-កម្មប្រចាំរូបកាយទាំងអស់គ្នា ៗ លុះយាត្រាទៅផុតប្រកក្តី ក៏ក្រឡេកមកក្រោយ ឃើញទាហានដែលសល់ទៅជាមួយនោះ ប្រហែល ៣០០នាក់ ប្តូរក៏បង្ខំឲ្យមេនាយស្រូតដើរទៅ ទាហានទាំងអស់ក៏និយាយព្រមឡើងថា សេះនឹងមនុស្សក៏អស់កម្លាំងណាស់ទៅហើយ សុំឲ្យលោកបង្អង់ឈប់បន្តិចសិន រួចសឹមលើកទៅទៀត ៗ ប្តូរថាឲ្យចំទៅឲ្យដល់ស្រុកកេងជីវស៊ិនសិមឈប់ចុះ ហើយក៏ស្រូតបរសេះទៅពីនោះ

បានប្រហែល ៥០ ស៊ិន ( ២គម ) ដល់ដំបន់ហ៊ូយ៉ុង ចូឆូក៏អស់សំណើចឡើងទៀត ។ ទាហានទាំងឡាយពួកនោះ ក៏មានសេចក្ដីសង្ស័យសួរទៅចូឆូថា លោកសើច ២ ដងមកហើយ ចេះតែមានហេតុឲ្យភ័យគ្រប់គ្រា ឥឡូវលោកសើចធ្វើអ្វីទៀត ? ។ ចូឆូថាៈ យើងសើចចំអកគំនិតគិតរបស់ខុនបេងនិងជីវយី ព្រោះទីនេះចំណាប់ស្រួលណាស់ មិនគួរនឹងមិនបង្កប់ទាហានទុក បើសិនណាជាមានពួកខុនបេង ជីវយីមកបាំងស្កាត់នៅត្រង់ណោះ យើងក៏នឹងបានសេចក្ដីអន្តរាយជាប្រាកដ លុះ-និយាយផុតមាត់ក៏ឮសំឡេងផាវ ហើយឃើញគួនអ៊ូជិះសេះកាន់ផាវចេញមកព្រមទាំងទាហាន ឈរទទឹងមុខត្រង់ផ្លូវដែលនឹងទៅនោះ ។

ចូឆូឃើញដូច្នោះ ក៏តក់ស្លុតស្មារតីភ័យណាស់ នឹងរកច្រកលុករត់ចៀសទៅខាងណាក៏មិនបាន ហើយមានចិត្តមានះឡើងថា ឥឡូវយើងពលគ្នាទាល់ច្រក នឹងរត់ជ្រកទៅខាងណាមិនរួច, ត្រូវតែតាំងចិត្តស៊ូច្បាំងឲ្យគ្រប់គ្នាទៅខាងមុខចុះ ។ ទាហានទាំងពួងនោះក៏ឆ្លើយថា ពួករបស់យើងទន់ថយកំឡាំងអស់ហើយ ទាំងសេះក៏អស់កំឡាំង ឃើញថានឹងប្រឹងទៅមិនបាន ព្រោះមិនមានកំឡាំងទាំងមនុស្សទាំងសេះស្មើគ្នា ។ ធៀយ៉ុកឆ្លើយថា បើនឹងរត់ចៀសទៅខាងណាក៏មិនបាន ព្រោះមិនមានកំឡាំងទាំងមនុស្សទាំងសេះស្មើគ្នា ។

ទៀយឺកឆ្លើយថា បើទីងរត់ចៀសទៅខាងណាក៏មិនបាន ឯសន្តានចិត្តរបស់គួនអ៊ីនោះ ជាជាតិទាហានក៏មែន តែថាបើឃើញអ្នកឯណាមិនហ៊ានតស៊ូនឹងចម្បាំងហើយ ក៏មិនបានធ្វើអន្តរាយដល់អ្នកនោះទេ ។ ប្រការ ១ ទៀត គួនអ៊ីជាមនុស្សមានសេចក្តីសត្យានុស័ត្យ ព្រមទាំងកតញ្ញូដឹងគុណគេជាទីបំផុត ប្រសិនបើលោកនឹងចូលទៅនិយាយល្អួងលោមដោយលំអុតល្អសុភាព មុខជាគួនអ៊ីនឹងជ្រួតជ្រាបក្នុងចិត្ត មិនបានគិតនឹងធ្វើអន្តរាយដល់លោកទេ ។ ប៊ូឆ្វយល់ឃើញត្រូវ ក៏ញាក់សេះបរចូលទៅជិត ហើយបន្ទន់ខ្លួនខុនគំនាប់ស្រែកសួរថា តាំងពីអ្នកឃ្លាតឆាកពីយើងមក អ្នកបានប្រកបដោយសេចក្តីសុខសប្បាយទេឬ ។

គួនអ៊ីឮដូច្នោះក៏បង្អោនខ្លួនគំនាប់តបហើយថា សុខទំនុកនោះក៏ជាប្រមាណ តែឥឡូវខុងបេងឲ្យខ្ញុំមកសម្លាប់មហាឧបរាជបេញ ។ ប៊ូឆ្វថា ដែលខ្ញុំបែកទ័ពរត់ត្រឡប់មកដល់ទីនេះ ក៏បានសេចក្តីទុក្ខលំបាកពន់ប្រមាណណាស់ អ្នកគួរឃើញផ្លូវមេត្រីរបស់ខ្ញុំដែលបានចងអារម្មណ៍ទុកនឹងអ្នកមកពីដើមនោះចុះ សុំឲ្យអ្នកអនុគ្រោះបើកផ្លូវឲ្យខ្ញុំទៅផង ។ គួនអ៊ីថា ដែលមហាឧបរាជមានឧបការគុណដល់ខ្ញុំនោះ ក៏មែនណាស់ ខ្ញុំក៏ចាំច្បាស់ប្រាកដ តែថាកាលគ្រាអ៊ូនសៀវលើកទ័ពទៅច្បាំងនឹងលោកនៅជំបន់ថៃប៉ៃនោះ ខ្ញុំក៏ទទួលកាសាចេញទៅកាប់សម្លាប់ងនលៀង,

ប៉ុនដីតបគុណលោករួចហើយ ព្រោះនេះជាការរបស់ខុនបេងប្រើឲ្យខ្ញុំមក ដែលលោកទឹងឲ្យខ្ញុំបើកផ្លូវឲ្យទៅនោះ ខុនបេងនឹងមិនយកទោសខ្ញុំប៉ុះ ៗ

ឯចូច្ចថា ដែលអ្នកថាបានតបគុណខ្ញុំគ្រានោះម្តងហើយក៏មែន តែកាលអ្នកយាមល្បាតបេញ្ញមកដល់ប្រាំដំបន់ជាលំដាប ហើយបានចាំងសម្លាប់នាយគយល្បាតនឹងហៅហ្វាយស្រុក និងអស់ទាហានរបស់ខ្ញុំខ្ទបខាតជាច្រើន ខ្ញុំក៏មិនតបដឹង ព្រោះបានដឹងដល់ពាក្យដែលអ្នកនិយាយទុកពីថ្ងៃមុនចាំងអស់ វេលានោះខ្ញុំក៏បានបេញសំបុត្រទៅដល់ហៃហ្វិទុន ដែលនៅឈរទីទេន្ទហងហោថាឲ្យបើកអ្នកទៅ ឥឡូវនេះខ្ញុំចូលមកជាប់បំណាម បង្ខំចមនុស្សធ្លាក់ទឹក ហើយខ្ញុំក៏មិនបានទឹកនឹងគស្មីនឹងអ្នកទេ គួរអ្នកឃើញសេចក្តីមេត្រីរបស់ខ្ញុំដែលបានអង្វរលន់តួនេះបុះ សុំឲ្យអ្នកអនុគ្រោះបើកខ្ញុំឲ្យបានរួចផុតពីភ័យអន្តរាយ ។ គួនអ៊ូពូចច្ចនិយាយដូច្នោះ ក៏កើតសេចក្តីអាណិតផ្អែកគ្នុនទុកគិតពីចារណាឃើញដល់គុណដែលមានមកពីដើម ក៏ញាក់សេះវេះចេញពីផ្លូវ នាំទាហានលើកទៅផុតពីទីនោះ ។

ចូច្ចឃើញដូច្នោះ ក៏ស្បើយល្ហើយក្នុងចិត្ត ខំពង្រឹតពលទាហានឲ្យស្រួតរួតហួសទៅ ៗ ឯទាហានដែលសល់នៅប្រហែល ៣០ នាក់ដើរតៅក្រោយ ៗ គួនអ៊ូឃើញទាហានដើរបណ្តោយតាមចូច្ចទៅក៏ស្រែកគំហកដោយសំឡេងខ្លាំង ៗ ទាហានដែលជិះសេះដើរដើង បានឮដូច្នោះក៏

ក៏យកកាំស្ទុតលុតជង្គង់ចុះគំនាប់គួនអ៊ូទាំងអស់គ្នា ។ គួនអ៊ូឃើញទាហានទាំងនោះមិនហ៊ាននាំគ្នាតតៃ ក៏មានសេចក្តីអាណិតមេត្តាមិនហ៊ានជាក្រការស្តេច ទាហានទាំងនោះក៏គំនាប់លាគួនអ៊ូស្រូតតាមចូឆូទៅ ។

កាលចូឆូទៅដល់ដំបន់ហ៊្វាយ៉ុងហើយ ក្រឡេកមើលក្រោយឃើញទាហានដែលតាមមក២៧នាក់ ។ ខណៈកាលដើរផ្លូវនោះ ចូឆូក៏សរសើរគួនអ៊ូថាមានសេចក្តីស័ត្យកតញ្ញូណាស់ លុះវេលាព្រលប់ចូឆូក៏ឃើញកងទ័ព ១ ក្រុមដុតគប់ភ្លើងលើកមកពីខាងមុខច្រើនណាស់ គិតតក់ស្លុតក្នុងចិត្តថាគ្រានេះជីវិតនឹងដល់សេចក្តីអន្តរាយហើយ លុះជិតចូលមកក៏ក្រឡេកស្គាល់ច្បាស់ថាហេហ៊ិន ចូឆូស្រាលក៏យកិត ។ ហេហ៊ិនចូលមកគំនាប់ចូឆូហើយនិយាយថា ខ្ញុំបាទដឹងដំណឹងថា មហាឧបរាជបរាជ័យនឹងសឹកសត្រូវ បានជាលើកទាហានកាត់ផ្លូវមកត្រង់ទីនេះ ដើម្បីនឹងចាំទទួលលោក ។ ចូឆូក៏រៀបរាប់ប្រាប់ទុក្ខលំបាកឲ្យហេហ៊ិនស្តាប់ ហើយក៏នាំទាហានចូលទៅក្នុងស្រុកឡាំកុន ។ ហេហ៊ិនក៏ឲ្យរៀបតុលៀងអាហារ អញ្ជើញចូឆូនឹងប្រឹក្សាបរិភោគផឹកស្រា ព្រោះថានឹងឲ្យស្បើយល្ហើយទុក្ខ ។

ខណៈកាលកំពុងបរិភោគអាហារនោះ ចូឆូក៏ងើយយំ ។ ទីប្រឹក្សានឹងទាហានទាំងពួងឃើញដូច្នោះ ក៏សង្ស័យណាស់ ទើបនាំគ្នាសួរចូឆូថា កាលបែកទ័ពមកកណ្តាលផ្លូវ បានសេចក្តីទុក្ខលំបាកវេទនាជាច្រើនជាន់

ណាស់ ហើយខ្ញុំក៏ឃើញថា លោកគ្មានក្រាន់ទិនព្រួយប៉ុន្មាន ឥឡូវនេះ ហួសទុក្ខបានសេចក្តីសុខក្សេមក្សាន្តបន្តិចមកហើយ គួរតែទិនប្រមូលបញ្ចូលសេនាទាហានលើកទៅធ្វើការសងសឹកសត្រូវវិញឲ្យបាន ហេតុម្តេចក៏លោកមកព្រួយរំខានយំសោកដូច្នេះ? ។ ចូឆូថា ដោយយើងយំសោកដូច្នេះ ព្រោះហេតុគិតដល់គុយកែ បើគុយកែរស់នៅមិនស្លាប់គ្រានេះ ក៏គង់ជាប់មកជាមួយទិនយើង យើងក៏មិនមកព្រួយលំបាកវេទនាដល់ទីនេះ ថាដូច្នោះហើយក៏យំសោករលីកអាល័យដល់គុយកែ ។

លុះវេលាព្រឹក ចូឆូក៏និយាយនឹងហោយ៉េនថា យើងនឹងត្រឡប់ទៅស្រុកហ៊ូតោសិន ដើម្បីនឹងចាត់ចែងប្រុងប្រៀបរៀបចំបំរុងទាហាននឹងលើកមកវាយយកស្រុកកាំងតាំងឲ្យបាន ខ្លួនអ្នកត្រូវនៅរក្សាស្រុកឡាំកុនយើងនឹងសរសេរសំបុត្របិទស្រោមទុកឲ្យបម្រុងរក្សាខ្លួន បើជួបអាប់ចុនវេលាណា ក៏ឲ្យហែកស្រោមមើល ហើយឲ្យធ្វើតាមសេចក្តីពន្យល់ក្នុងសំបុត្រនោះឲ្យសព្វគ្រប់ ទើបពួកស្រុកកាំងតាំងនឹងមកញាំញីមិនបានហើយក៏សរសេរសំបុត្របកស្រោមប្រគល់ឲ្យទៅហោយ៉េន ។ ទទួលយកសំបុត្រហើយថា ស្រុកហ៊បផ្ទះនោះជាដែនតដែនទីស្រុកកាំងតាំង តើលោកនឹងឲ្យនរណានៅឈររក្សា ចូឆូថា ស្រុកកេងជីវទីងស្រុកឡាំកុន នោះទៅចូររក្សាទុកឲ្យមាំមួនចុះ ឯស្រុកសុងយ៉ុងនោះយើងនឹងឲ្យហែហ្លួទុន

ទៅឈរគេគ្រា តែស្រុកហ៍បប៉ាយើងត្រូវឲ្យទៀវលៀវធ្វើទៅហ្វាយស្រុក ឲ្យលើទៀនទឹងផ្ទុកជិនធ្វើបាលដ្ឋ បើមានការអ្វីជាកម្រកឲ្យរៈធ្វើសំបុត្រទៅ គ្នាទឹងមកជួយ ហើយបុច្ចុកប្រុងប្រៀបតាហាន ទឹងខាម៉ុនគ្រប់ក្អាក់ង៉ារ ស្រុកគេនដើរជាស្រេច កំលើកទ័ពត្រឡប់ទៅស្រុកហ្ពូតោ ហោយចិនកំឲ្យ ហោហានជាប្អូនលើកតាហានទៅនៅរក្សាគយអ៊ុំឡេង ។

ឯគួនអ៊ីគ្រោដែលបើកផ្លូវឲ្យបុច្ចូទៅហើយ កំលើកតាហានត្រឡប់ទៅ ដល់មុខបន្ទាយហៃទៅ ព្រមគ្នាទឹងទៀវហ៊ុយ, ជូឡុង កង់ខណៈនោះ ទៀវហ៊ុយ, ជូឡុង បានតាហានទឹងសេះនូវអស់គ្រឿងសស្ត្រាវុធរបស់ ទ្រព្យផ្សេង ៗ នាំទៅជូនខុងបេង ៗ លុះដឹងថាគួនអ៊ីមកដល់មុខបន្ទាយ កំនាំឡៅពីធ្វើជាបេញទៅទទួល ហើយនិយាយសួរទៅគួនអ៊ីថា យើង ដឹងថាអ្នកមានចិត្តសុចរិតជួយទំនុកបំរុងផែនដី បានទៅកាត់សិរសី តួ សឹកសត្រូវពជសម្បត្តិមក បានជាយើងចេញមកចាំទទួលអ្នកដោយ សេចក្តីត្រេកអរដ៏ក្រៃលែង ។

គួនអ៊ីឮដូច្នោះកំស្ងៀមមិនឆ្លើយ ខុងបេងឃើញគួនអ៊ីធ្វើធ្មឹងដូច្នោះ ក៏ក្លែងជាទើបនឹងសួរថា អ្នកតូចចិត្តនឹងយើង ព្រោះមិនបានចេញទៅទទួល ដល់ពាក់កណ្តាលផ្លូវឬអ្វី ? ហើយងាកទៅបន្ទោសតាហានដទៃថា ហេតុ មេចបានជាអ្នកពលគ្នាមិនស្រួតមកប្រាប់យើងឲ្យដឹង ទឹងបានចេញមក

ទទួលគួនអ៊ិជនោះ គួរតែយកទោសខុសទាំងអស់គ្នា ពីព្រោះចង់ឲ្យគួនអ៊ិ ទាស់ចិត្តបានជាមិនមាត់មិនស្តីនឹងយើង ។ គួនអ៊ិឮខុនបេងនិយាយឲ្យដូច្នោះក៏ឆ្លើយថា ខ្ញុំបាទនឹងមកទទួលទោស ។ ខុនបេងក៏កួងសួរទៅវិញថា អ្នកទៅធ្វើការនោះមិនជួបនឹងបួចទេឬ ឲ្យអ្នកមកកាត់យកក្បាលយើងជំនួសបុះ ។ គួនអ៊ិឆ្លើយថា ខ្ញុំបាទបានទៅជួបនឹងបួចដូចប្រសាសន៍លោកថាព្រាកដ តែថាខ្ញុំបាទដូចជាអត់ចូដៃសោះ ឯបួចក៏ជោះអត់ទៅបាន ។ ខុនបេងឮហើយក៏អស់សំណើច ហើយសួរគួនអ៊ិថា ដែលបួចតែរួចខ្លួនទៅនោះ បុះចំណែកពាហានរបស់បួច តើអ្នកចាប់បានមកខ្លះដែរឬទេ ? គួនអ៊ិឆ្លើយថា សូម្បីពាហានរបស់បួចក៏ខ្ញុំបាទចាប់ខ្លួនពុំបាន ខុនបេងក៏ធ្វើជាខឹងហើយថា ខ្លួនអ្នកឯងបានទៅជួបប្រទះនឹងបួចហើយ មេចឡើយក៏បើកឲ្យតែរួចទាំងខ្លួនបួចនឹងពួកពាហានអស់ទៅ ឬអ្នកឯងមកគិតនឹកលើកគុណគេ ទើបបានជាមិនចាប់ខ្លួនកាត់យកក្បាលមកឲ្យយើង ទោសអ្នកឯងធ្ងន់ណាស់ ដែលអ្នកបានធ្វើកតិកាសញ្ញាទុកនឹងយើង នោះអ្នកភ្លេចអស់ហើយឬ ? ។ គួនអ៊ិឆ្លើយថា ដែលខ្ញុំបាទធ្វើសញ្ញាទុកនឹងលោកថា បើខ្ញុំបាទបានប្រទះជួបនឹងបួចហើយមិនបានកាត់យកក្បាលមកជូនលោកទេ ឲ្យកាត់ក្បាលខ្ញុំបាទតាមសញ្ញាវិញចុះ ហើយក៏ហូតក្រប៊ីឡើងនឹងកាត់ក្បាលរបស់ខ្លួនជូនខុនបេង ។ ឃើញគួនអ៊ិហូត

ក្របីនឹងកាត់ក្បាលខ្លួនជូនបោះ ក៏ស្ទុះចូលទៅដណ្ដើមយកក្របីពីដៃចេញបាន ហើយឃាត់ហាមថា ដែលយើងព្រមប្រើអ្នកឲ្យទៅធ្វើការគ្រោះនេះ ប្រាថ្នានឹងឲ្យអ្នកទៅតបស្នងសងគុណចូចឲ្យរួចទេ យើងមិនបានប្រុងនឹងយកទោសអ្នក នឹងកាត់ក្បាលឲ្យយើងតាមសញ្ញានោះក៏ត្រូវហើយ ព្រោះជាពាក្យស័ត្យពិតត្រង់គួរជាជាតិទាហានឲ្យទៅចុះ ។ គួនអ៊ិញជូនបោះក៏សោមនស្សត្រេកអរ សុំយកក្របីទៅស៊កក្នុងស្រោមវិញ ខុងបេងនឹងទៀតក៏នាំគួនអ៊ិចូលទៅក្នុងបន្ទាយឲ្យរង្វាន់បំណាច់តាមសមគួរ ។

ឯជីវយើ កាលបានជ័យជំនះឈ្នះចួចហើយ ក៏លើកកងទ័ពត្រឡប់ទៅបន្ទាយ ឲ្យចែករង្វាន់បំណាច់សេនាទាហានធំតូចទាំងពួងតាមគុណបំណាច់ ហើយក៏ឲ្យយកទូកចម្បាំងផ្ទុកទាហានចួចដែលចាប់បានជាឈ្លើយនោះ បញ្ជូនទៅឲ្យស៊ុនគួនដល់មាត់កំពង់ស្រុកកាំងតាំង ហើយជីវយើក៏លើកកងទ័ពទៅតាំងនៅទីជំរំលើមកាំង ចាំនឹងរិះគិតទៅវាយយកស្រុកខ្លាំកុនទៀត ។

ឯទៀតី ក៏ចាត់របស់ទ្រព្យសម្រាប់លៀងទាហានឲ្យស៊ុនខៀននាំទៅគំនាប់ជីវយើ ស៊ុនខៀនក៏នាំយករបស់ទៅឲ្យជីវយើ ។ ក៏សួរស៊ុនខៀនថា ឥឡូវនេះឡៅពីទៅហ្វាយអ្នកឯងនៅទីជំរំណា? ។ ស៊ុនខៀនឆ្លើយថា ឡៅពីនឹងខុងបេងនាំទាហានទៅតាំងនៅកំពង់ស្រុកអ៊ីកាំង ។

(នៅមានត)

# រឿងស្ដេចបាយស្កោរ

លោក ញ៉ែម-ខឹម រៀបរៀង

កាលសម័យព្រេងនាយ ក្រុងស្រីអយុធ្យាជានគរមួយសប្បាយក្រៃលែង ។ ព្រះមហាក្សត្រនៃប្រទេសនោះព្រះនាមស្ដេចគំលង់ ព្រះមហាក្សត្រិយានីព្រះនាមនាងសក់ក្រអូប ។ ព្រះមហាក្សត្រទាំងពីរព្រះអង្គទ្រង់គង់នៅឯក្នុងព្រះបាទជាន់ជុំ ទ្រង់មានព្រះរាជបុត្រពីរព្រះអង្គ មួយជាព្រះរាជបុត្រា មួយជាព្រះរាជបុត្រី ។ ព្រះរាជបុត្រាព្រះនាមស្ដេចបាយស្កោរ, ព្រះរាជបុត្រីព្រះនាមនាង សបូករ: ។ ព្រះនាងមានព្រះជន្ម ១៩ ឆ្នាំ ។

ថ្ងៃមួយព្រះអង្គម្ចាស់ក្សត្រី ក៏កើតក្ដៅក្រហាយក្នុងព្រះទ័យ, បង់យានីចេញទៅមុជទឹកលេង នៅត្រង់មុខវត្តជើងកញ្ចុំ ដែលអ្នកយើងគេអើជាចៅអធិការ ។ អាស្រ័យហេតុដូច្នេះ ព្រះនាងក៏ទ្រង់ត្រាស់ហៅស្រីស្នំក្រមការ ឲ្យជូនព្រះនាងទៅស្រង់ទឹកនៅមុខវត្តនោះ ។

មានដំណាលថា: នៅមុខវត្តនោះមានក្រពើមួយកាចសាហាវណាស់ ។ ក្រពើនោះបានកាច់របាំងឃាំងហើយ ហែលចេញមកចាប់ព្រះនាងពាំយកទៅជាមួយវាទៅ ។ ព្រះមហាក្សត្រទាំងពីរព្រះអង្គ ជាព្រះ

បិតាមាតាព្រះនាង បានចាត់មន្ត្រីអ្នកកងការ ឲ្យចេញទៅរកពេទ្យហ្ម ដែលចេះមន្តអាគម ខាងចាប់ក្រពើឲ្យមកចាប់ក្រពើ ដែលបានពាំព្រះរាជបុត្រីព្រះអង្គទៅ ។

គ្រូហ្មក៏រៀបធ្វើពែមួយដាក់លាជពីលើ ។ កាលធ្វើរួចហើយ, គាត់ក៏បានសូត្រមន្តអាគមប្រសិទ្ធិពរលើពែនោះ រួចក៏បណ្តែតពែនោះឲ្យចេញទៅតាមរកក្រពើ ។ កាលបើពែនោះបានរសាត់ទៅដល់ខាងជើងព្រៃទ្រមូង ៖ ព្រះរាជាដែលទ្រង់បានយាងតាមពែនោះជាប់ជានិច្ចមក, ក៏ទ្រង់ត្រាស់បង្គាប់ឲ្យគេបញ្ឈប់ពែនោះ ដើម្បីឲ្យពួកពលព្រះអង្គឈប់សម្រាកដណ្តាំបាយបរិភោគ ។ លុះពួកពលបានចំអិនបាយម្ហូបអាហារសព្វគ្រប់អស់ហើយ , ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យគ្រូហ្មចូលរូបខ្លួនឯងមើល ( បញ្ជាន់រូប ) ។ នៅពេលនោះព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យគេផ្ទុំបុំពក ដើម្បីប្រគំគ្រូដែលស្ថិតនៅខាងលិចព្រៃនោះ ។ គ្រូហ្មក៏តាំងមន្តគាថាសំបូងសង្រួង ដើម្បីហៅក្រពើឲ្យឡើងមកលើទួលខ្សាច់ ដែលស្ថិតនៅខាងទិសពាយ័ព្យនៃព្រៃទ្រមូង ។ ដោយព្រះអាទិត្យមានកំដៅក្តៅពន់ពេក ព្រះរាជាទ្រង់ត្រាស់បង្គាប់ឲ្យគេយកផ្ទិតទៅពាំងឲ្យហ្ម ។ ទោះបើគ្រូហ្មខំសូត្រសែកមន្តអាគមយ៉ាងណា ក៏នៅតែរកក្រពើពុំឃើញ ។ អាស្រ័យហេតុនោះ, ទើបព្រះបាទបាយស្គោរទ្រង់ព្រះរាជបញ្ជាដល់កងសេនាទាហានទាំងអស់ ឲ្យលើកទំនប់ទប់ទឹកកុំឲ្យហូរមកពីលើ ហើយ

បបួលគ្នាបាចឲ្យរឹងដើម្បីចាប់ក្រពើ ។

លុះចាប់ក្រពើបានកាលណា គេក៏សម្លាប់វា វះពោះទាញយកសពព្រះអង្គម្ចាស់ក្សត្រីចេញមក ។ ព្រះមហាក្សត្រជាព្រះវរបិតាព្រះនាងទ្រង់ដោះយកគ្រឿងមាសប្រាក់ ដែលជាប់នៅនឹងព្រះកាយព្រះនាងទាំងប៉ុន្មានចេញអស់ ។ បន្ទាប់មក, ព្រះអង្គទ្រង់ត្រាស់បង្គាប់ឲ្យពលពាហនឆ្ការព្រៃមួយកន្លែង ដើម្បីដាំល្ងយកគ្រាប់ធ្វើនំ រៀបធ្វើបុណ្យបូជាព្រះសពព្រះរាជបុត្រីព្រះអង្គ ។

គឺចាប់តាំងពីពេលនោះមកហើយ បានជាកន្លែងខ្លះនៃតំបន់នោះមានឈ្មោះថា: ទំនប់ក្អក្រពើ, ភូមិព្រៃអំពក, ភ្នំផុត, ភូមិបឹងអិដ្ឋ, វត្តទ្រមូង, ភូមិត្រពាំងសម្ង, ព្រៃធំ ។

ដំណាលពីព្រះនាងសក់ក្រអូបវិញ ដែលជាមហេសីនៃស្តេចគំលង់ ព្រះរូបសម្ផស្សដ៏ល្អឆើតឆាយរបស់ព្រះនាង ត្រូវបានលេចឮខ្ទរដល់ទៅប្រទេសចិន និងប្រទេសសៀម ។

ព្រះរាជានៃប្រទេសចិន កាលបើទ្រង់ជ្រាបថាព្រះទេពីនៃស្តេចគំលង់ សោយរាជ្យនៅក្នុងនគរស្រីអយុធ្យា មានព្រះរូបឆោមលោមពណ៌ល្អប្រិមប្រិយ៍ក្រៃលែង គ្មានស្រីណាមួយនៅក្រោមមេឃលើដីអាចប្រៀបផ្ទឹមបាន ក៏ទ្រង់ត្រាស់បង្គាប់ដល់នាយសំពៅចិនម្នាក់ ឲ្យបើកសំពៅចេញ

មក មានដាក់ទាំងឪឡឹកបីផង តម្រង់មកនគរស្រីអយុធ្យា ដើម្បីមកចាប់ដណ្ដើមយកព្រះនាងសក់ក្រអូប ដាក់សំពៅនាំយកទៅថ្វាយព្រះអង្គឲ្យបានកុំខាន ៗ

ម្ចាស់សំពៅទទួលបង្គាប់ព្រះរាជា បើកសំពៅចូលមកក្នុងនគរស្រីអ-យុធ្យាឈប់បោះយុថ្កានៅមុខវត្តដើមកញ្ជុំដែលអ្នកយើងអិកអីគង់នៅ ៗ

លុះស្អែកឡើង, នាយសំពៅក៏យកឪឡឹកបីនោះទៅថ្វាយព្រះបាទបាយង្កោរ សូមឲ្យព្រះអង្គរកអ្នកប្រាជ្ញឯណាដែលចេះទាយ ឲ្យទាយថាតើឪឡឹកនីមួយ ៗ នោះមានគ្រាប់ប៉ុន្មាន ៗ នាយសំពៅបានពោលបន្ថែមថា បើព្រះនរបតីពុំអាចរកអ្នកប្រាជ្ញណាមួយទាយត្រូវទេ, នោះត្រូវព្រះអង្គប្រគល់ព្រះនាងសក់ក្រអូបទៅឲ្យស្ដេចក្រុងចិន ៗ ទ្រង់ព្រះសណ្ដាប់ដូច្នោះ, ស្ដេចគំលង់ក៏ទ្រង់ភិតភ័យជាខ្លាំង ទើបចាត់ព្រះរាជបំរើឲ្យទៅតាមរកអ្នកយើងអិកអី ៗ អ្នកយើងកាលបើបានឮដំណឹងថា ស្ដេចត្រូវការឲ្យទាយអំពីរបស់ដូចគ្នាយ៉ាងនេះ ក៏យល់ថាពុំអាចទាយត្រូវទេហើយសម្រេចចិត្តថានឹងទៅលោតទឹកសម្លាប់អាត្មាល្អជាជាង ៗ គិតដូច្នោះហើយ, អ្នកយើងក៏និមន្តទៅលោតទឹកទន្លេសម្លាប់ព្រះអង្គមែន ៗ ប៉ុន្តែ, ដល់លោកទៅធ្លាក់ទឹក, លោកក៏នឹកស្រឡាញ់ជីវិតលោកវិញហើយទំហែលទឹកទៅប្រទះនឹងសំពៅចិន ក៏តោងនៅនឹងខ្សែយុថ្កាសំពៅ

នោះទៅ ។ នៅខណៈនោះ លោកបានស្ដាប់ឮនាយសំពៅចិននិយាយថា ឪឡឹកដែលធំជាងគេមានគ្រាប់បី, ឪឡឹកធំល្មមមានគ្រាប់ពីរ, ឯឪឡឹកដែលតូចជាងគេបង្អស់ មានគ្រាប់តែមួយទេ ។

កាលបើបានឮដូច្នោះ អ្នកយើងក៏ត្រឡប់ហែលសំដៅទៅទាង ហើយក៏និមន្តចូលទៅក្នុងវត្តវិញ ។

លុះថ្ងៃស្អែកឡើង, នាយសំពៅឡើងចូលទៅគាល់ស្ដេចត្រលង់ យកទាំងឪឡឹកបីនោះទៅជាមួយផង ហើយទូលរៀបរាប់អំពីបេសកកម្ម ដែលស្ដេចក្រុងចិនបានទ្រង់ចាត់គាត់ឲ្យមកកាន់ទីនេះ ។ ក្រោយពីទ្រង់ព្រះសណ្ដាប់ការក្រាបទូលនៃនាយសំពៅហើយ ស្ដេចត្រលង់ទ្រង់ភ័យញាប់ញ័រក្នុងព្រះចិន្ដាជាក្រៃលែង ទ្រង់ចាត់ព្រះរាជបំរើឲ្យទៅនិមន្តអ្នកយើងអិតអឺ ។ កាលអ្នកយើងអិតអឺនិមន្តមកដល់, ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូល ទូលរឿងហេតុនោះដល់អ្នកយើងភ្លាម ហើយទ្រង់ត្រាស់បង្គាប់ឲ្យលោកឆ្លើយតាមហេតុការណ៍នោះ ។ អ្នកយើងមានពុទ្ធដីកាហៅអាមោកនឹងអាតាំងជាកូនសិស្ស ឲ្យយកក្ដារឈ្នួនទឹងដីស ។ លុះបានក្ដារហើយ អ្នកយើងក៏ធ្វើហាក់ដូចជាខំយកចិត្តទុកដាក់ណាស់ រួចក៏ទាយថា កាលបើគេពុះឪឡឹកបីនេះទៅ គេនឹងឃើញឪឡឹកធំជាងគេមានគ្រាប់បី, ឪឡឹកកណ្ដាលមានគ្រាប់ពីរ, និងឪឡឹកតូចជាង

គេបង្អស់មានគ្រាប់មួយ ៗ គេក៏ពុះផុឡើកទាំងប៉ីនោះឡើង ហើយបាន ឃើញចំនួនគ្រាប់ពិតដូចអ្នកគ្រូឃើងបានទាយមែន ៗ តមក, នៅពេល ដែលទាយសំពៅថ្វាយបង្គំព្រះរាជាលាត្រឡប់ទៅកាន់សំពៅ រួចលើក ក្ដោងបើកសំដៅត្រឡប់ទៅប្រទេសចិនវិញ, អ្នកឃើងអ៊កអ៊ក៏និមន្ដត្រឡប់ ទៅវត្តវិញដែរ ៗ

លុះកាលក្រោយបន្ទិចមក, ព្រះមហាក្សត្រនៃប្រទេសសៀមក៏ ទ្រង់ចាត់ខាលួងម្នាក់ ឲ្យបើកសំពៅកេត្រាបញ្ជូះពួកក្មេងទីងពួកនាដការី ជាច្រើនចូលមកនគរអយុធ្យា, ដើម្បីនាំយកនាងសក់ក្រអូបទៅថ្វាយ ព្រះអង្គ ៗ

ខាលួងក៏បានបើកសំពៅមកឈប់នៅទៀបព្រៃ ជិតក្នុងព្រះបាទ ជាន់ជុំ ៗ ក្រោយបន្ទិចមក, គេលេងក្មេងកំប្រៀងពេញលើសំពៅនោះរួច ពួកខាលួងក៏ចាត់មន្ត្រីមានបណ្ដាស័ក្ដិម្នាក់ឲ្យចូលទៅក្រាបទូលសុំឲ្យស្ដេច គំលង់ មានព្រះរាជបញ្ជាឲ្យរាយដួងទូងគេរី ដើម្បីឲ្យអស់មន្ត្រីធំ-តូច ការណាប្រជានុរាស្ត្រទូទៅបានដឹងបបួលគ្នាមកមើលល្ខោនដែលស្ដេចក្រុង សៀម បាននាំយកមកលេងថ្វាយស្ដេចនគរស្រីអយុធ្យា ៗ កាលបើបាន ឮសេចក្ដីអញ្ជើញដូច្នេះ ព្រះនាងសក់ក្រអូបទ្រង់មានព្រះទ័យសោមនស្ស ជាក្រៃលែងនឹងយាងទៅទតរបាំនោះ ៗ ដូច្នេះព្រះនាងក៏យាងចូលទៅ

សុំសេចក្ដីអនុញ្ញាតពីព្រះស្វាមី , តែស្ដេចគំលង់បានទ្រង់ប្រកែកជាដាច់ខាតមិនព្រមឲ្យព្រះនាងយាងទៅទតមហោស្រព ។ ព្រះទេពីក៏ទ្រង់ព្រះវិតក្កអផ្សុកក្រៃលែង, ទើបនៅពេលពាក់កណ្ដាលអាធ្រាត្រ ព្រះនាងទ្រង់ត្រាស់ហៅស្រីស្នំក្រមការ , យាងចេញពីមហាប្រាសាទ, ទៅគង់លើសំពៅបើកសំដៅ ទៅកាន់សំពៅខាល្ងង ។ អាស្រ័យដោយហេតុដូច្នេះ ទើបព្រះនាងបានយាងទៅទតមហោស្រពសៀមដោយសេចក្ដីរីករាយ ។

លុះដល់មាន់រងាវទៀបភ្លឺ នៅពេលដែលពួកក្មេងកំពុងតែបញ្ចេញសិល្បៈរបស់ខ្លួនយ៉ាងប៉ិនប្រសប់ ខាល្ងងក៏លបប្រាយពួកលីកយុក្ថាសំពៅបើកក្ដោងសំដៅទៅប្រទេសសៀម ។ ព្រះនាងសក់ក្រអូបទំរាំតែបានទ្រង់ជ្រាបថា គេបានបើកសំពៅសំដៅទៅប្រទេសសៀម, ពេលវេលាក៏កន្លងជ្រុលហួសអស់ , ទើបព្រះនាងទ្រង់ស្រែកផ្ដែផ្ដាំលាព្រះនគរ លាព្រះស្វាមី , លាព្រះរាជបុត្រនឹងពួកស្រីស្នំទាំងឡាយដែលពុំបានទៅជាមួយព្រះនាង ។

លុះព្រះនាងមានព្រះសវនីយ៍ផ្ដែផ្ដាំចប់, ខាល្ងងបង្គាប់ឲ្យពួកក្មេងលេងបទផ្ដាំផ្ញើ ហើយនៅពេលដែលគេកំពុងប្រគំបទខាងក្រោយនេះ សំពៅក៏បានលឿនទៅមុខ, នាំព្រះនាងយកទៅថ្វាយព្រះចៅក្រុងសៀមដែលកំពុងគង់រង់ចាំជាយូរមកហើយ ដោយសេចក្ដីអន្ទះអន្ទែងឥតឧបមា;

លុះព្រះនាងបានយាងទៅដល់ដែនដីសៀមកាលណា, ស្តេចស្រុកសៀម ក៏លើកព្រះនាងធ្វើជាព្រះអគ្គមហេសីទីមួយ, ហើយឃាត់ឃាំងព្រះនាងទុកនៅក្នុងមហាប្រាសាទអស់ពេលជាច្រើនឆ្នាំ ។

សូមជំណាលពីព្រះបាទបាយអ្នោរវិញ នៅពេលដែលខាល្អួងបានលួចចាប់ដោយកលល្បិចយកព្រះនាងសក្រអូបជាព្រះវរមាតា ទៅឃុំឃាំងទុកនៅស្រុកសៀមនោះ, ព្រះអង្គទ្រង់មានព្រះជន្មាយុបាន២០ឆ្នាំហើយ ។ នៅពេលនោះ ព្រះអង្គម្ចាស់ក៏ទ្រង់មានព្រះបន្ទូលសួរទៅព្រះវរបិតាថា ព្រះមាតាគង់នៅឯណា ? ។ ព្រះបិតាទ្រង់មានព្រះបន្ទូលប្រាប់ថា ព្រះមាតាត្រូវវាញ់កលល្បិចខាល្អួង, ខាល្អួងបានចាប់នាំយកទៅថ្វាយស្តេចក្រុងសៀមបាត់ទៅហើយ ។ កាលបើទ្រង់ព្រះសណ្តាប់ព្រះបន្ទូលព្រះបិតាចប់ហើយ, ព្រះអង្គម្ចាស់បាយអ្នោរទឹកភ្នែកព្រះទ័យជាក្រៃលែង, ក៏ទ្រង់ក្រាបបង្គំសុំអនុញ្ញាតព្រះបិតា ដើម្បីលើកទ័ពទៅច្បាំងនឹងនគរសៀមដណ្តើមយកព្រះមាតាមកវិញ ។ ព្រះកជាទ្រង់យល់ព្រម ហើយប្រជុំកងទ័ពទាំងអស់នៅក្នុងស្រែ ខាងកើតភ្នំព្រះបាទជាន់ជុំ ។ កងទ័ពនោះមានចំនួនទាំងអស់ប្រហែលជាមួយម៉ឺននាក់ គឺបានសេចក្តីថាកងទ័ពស្ថិតនៅត្រៀមត្រាលើផ្ទៃស្រែចំនួនមួយម៉ឺន (ពល់ ១ ម៉ឺនស្រែ) ។

បន្ទាប់មក, ព្រះអង្គម្ចាស់បាយអ្នោរទ្រង់បញ្ជាកងទ័ពតម្រង់ទៅ

ប្រទេសសៀម, វាយប្រហារទ័ពសត្រូវ ហើយចាប់បានស្ដេចសៀម, រួចក៏ធ្វើគុតទៅ ទើបលើកកងទ័ពវាយសម្រុកចូលសំដៅទៅព្រះរាជធានី, ដណ្ដើមយកបានព្រះនាងសក់ក្រអូប, ដែលនៅតែមានព្រះសម្រស់ល្អដដែល, មានតែល្អលើសពេលមុនសៀមចាប់យកទៅទៀត ។ ប៉ុន្តែព្រះអង្គម្ចាស់ឥតបានស្គាល់ព្រះនាងសក់ក្រអូបថាជាព្រះមាតាទេ, ក៏ទ្រង់រួមរក្សស្នេហាជាមួយព្រះនាង ហើយនាំព្រះនាងមកព្រះនគរធ្វើជាមហេសីទៅ ។ លុះយាងមកដល់ព្រះនគរវិញ, ព្រះអង្គម្ចាស់បានចូលទៅក្រាបទូលពត៌មានដល់ព្រះបិតា អំពីដំណើរនៃបេសកកម្មដែលព្រះអង្គបានបំពេញដើម្បីសងសឹកស្ដេចក្រុងសៀម, ព្រះវរបិតាក៏ទ្រង់ជាក់ព្រះទ័យ, ហើយទ្រង់ប្រគល់រាជសម្បត្តិទាំងអស់ ក្នុងព្រះរាជអាណាចក្រទាំងមូលឲ្យព្រះរាជបុត្រ ។

លុះពេលកន្លងក្រោយបន្តិចមក ព្រះនាងសក់ក្រអូបទ្រង់បានសង្កេតមើលព្រះកេសព្រះបាទបាយន្ដោរជាព្រះស្វាមី, ឃើញស្នាមមួយដែលធ្វើឲ្យព្រះនាងស្គាល់ ហើយនឹកឃើញថា ព្រះស្វាមីព្រះនាង គឺជាព្រះរាជបុត្រព្រះនាង ។ ព្រះនាងក៏មានព្រះសវនីយ៍ពីរឿងនោះប្រាប់ព្រះអង្គម្ចាស់ ។ ទ្រង់មានព្រះបន្ទូលរាប់រៀបទូលព្រះនាងសក់ក្រអូប អំពីហេតុបណ្ដាលឲ្យព្រះអង្គលើកទ័ពទៅធ្វើសង្គ្រាមជាមួយនឹងប្រទេសសៀម ។

អាស្រ័យហេតុនេះ, ព្រះទេពីក៏ទ្រង់ស្គាល់ព្រះអង្គម្ចាស់ថាជាព្រះរាជបុត្រពិតប្រាកដ ។ ព្រះនាងក៏ទ្រង់ព្រះកន្សែងរៀបរាប់ប្រាប់ព្រះរាជបុត្រអំពីរឿងហេតុផ្សេងៗ ដែលបានកើតមានឡើងតាំងតាំងពីថ្ងៃដែលក្រុងសៀមបានចាប់ព្រះនាងយកទៅ ។ ព្រះបាទបាយន្ដោរបានឮព្រះមាតាមានព្រះសវនីយ៍ដូច្នោះ, ក៏ទ្រង់គិតភ័យជាក្រៃលែង ហើយដោយនឹកបង់លាងបាបដែលព្រះអង្គបានប្រព្រឹត្តអំពើពុតប្បី, ព្រះអង្គក៏ទ្រង់សាងព្រះចេតិយ ១០០០ និងស្រះ ១០០០ (ស្រះអង្គត្រពាំង) ។ ព្រះវរបិតារបស់ព្រះអង្គទ្រង់បានដាក់ទំនាយថា ព្រះរាជបុត្រព្រះអង្គនឹងចាកចេញផុតពីស្ថានរកេមកវិញបាន លុះត្រាតែចេតិយនិងស្រះទាំងឡាយលោយបាត់អស់ហើយគេយកកន្លែងទាំងនោះ ធ្វើជាស្រែសម្រាប់ដាំស្រូវទៅវិញ ។ អាស្រ័យហេតុដូចបានរាប់រៀបមកនេះហើយ, បានជានៅកន្លែងខ្លះមានឈ្មោះជាប់រហូតមកដល់សព្វថ្ងៃនេះដូចជាឈ្មោះថា ស្រែរាល់ពល,ត្រពាំងស្រង់ និងព្រៃយុក្កា ។

កាលបើសង់ព្រះចេតិយ និងជីកស្រះទាំងឡាយរួចស្រេចហើយ, ព្រះបាទបាយន្ដោរក៏ទ្រង់តាត់ព្រះរាជប្រតិកូ ឲ្យចូលទៅដណ្ដឹងព្រះរាជបុត្រីព្រះបាទអង្គរបុរីធ្វើជាមហេសី ប៉ុន្តែព្រះបាទអង្គរបុរីទ្រង់ប្រកែកពុំព្រមឲ្យដោយទ្រង់មានព្រះបន្ទូលថា ព្រះបាទបាយន្ដោរទ្រង់មានទោសធ្ងន់

ណាស់ ។ ព្រះបាទបាយក្អោរទឹកតូចព្រះទ័យជាខ្លាំងក៏លើកទ័ពចេញទៅច្បាំងតតាំងនឹងស្តេចអង្គរបូរីដើម្បីដណ្តើមយកព្រះរាជបុត្រ ប៉ុន្តែត្រូវបរាជ័យ ហើយទ្រង់យានត្រឡប់មកព្រះនគរវិញ , អាស្រ័យហេតុនេះហើយ , បានជានៅត្រង់កន្លែងមួយជិតទីសមរភូមិនោះ គេហៅថាប្រកស្បូរឈាម ។

---

## រឿងព្រេងប្រទេសវេណេហ្ស៊ុយអេឡា (១)

## ចែងអំពីបម្រៀងខ្លុយ

ភិក្ខុ ម៉ែន-រៀម

សិស្សពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ

ប្រែចាកភាសាអង់គ្លេស

---

សម័យមួយ មានព្រះមហាក្សត្រមួយព្រះអង្គ ទ្រង់មានព្រះរាជបុត្រ ៣ ព្រះអង្គ ព្រះនាម ប៉េដ្រូ, ហ្វ៊ុយអាន និងហ្ស៊ូសេ ។ ពេលមួយនោះ ព្រឹត្តិការណ៍បានកើតឡើងដល់ព្រះអង្គ បណ្តាលឲ្យចក្ខុវិញ្ញាណរបស់ព្រះអង្គ ទន់ខ្សោយចុះបន្តិចម្តង ៗ ដរាបដល់ទ្រង់នឹងតែលែងទតមើលឃើញ ។ ពេទ្យដ៏ជំនាញៗ ទាំងឡាយក្នុងប្រទេសរបស់ព្រះអង្គ បានខំជួយព្យាបាលណាស់ដែរ តែអ្នកទាំងនោះមិនអាចធ្វើអ្វីកើតឡើយ ។

ទីបំផុត, វេជ្ជបណ្ឌិតម្នាក់ទូលព្រះអង្គថា ដម្បីព្រះចក្ខុរបស់ព្រះអង្គនោះ មិនទាន់ចុះដល់ថ្នាក់អតេកិច្ឆាពាធនៅឡើយទេ, មានឱសថម្យ៉ាង ដែលវិភាគពីផ្កាអូលីវ អាចព្យាបាលឲ្យជាបាន ។

កាលទ្រង់ឮពាក្យនេះ, ទ្រង់សប្បាយព្រះទ័យពន់ពេក ៗ ប៉ុន្តែ

---

១- នៅអាមេរិកខាងត្បូង ។

ពេលនោះ ទ្រង់រំពឹងថា តើអញនឹងរកផ្កាឈូករ័ត៌ទីណាបាន ? បើប្រទេសរបស់អញគ្មានដើមឈូករ័ត៌សោះយ៉ាងនេះ ! „

ដោយសេចក្ដីអស់សង្ឃឹម, ព្រះអង្គបានហៅព្រះរាជបុត្រទាំង ៣ មកប្រាប់ពីរឿងសុបិនដែលត្រូវវិកាត យកមកព្យាបាលព្រះចក្ខុទ្រង់ឲ្យជាបាន បើប្រសិនណាជាបានផ្កាឈូករ័ត៌មួយមុខមកថែមទៀត ។ ពេលនោះទ្រង់សុំឲ្យព្រះរាជបុត្រទាំង ៣ អង្គនោះ ជួយទ្រង់ក្នុងរឿងនេះ ។

ក្នុងណានោះ, ព្រះអង្គម្ចាស់ប៉េជ្រូ ជាព្រះរាជបុត្រច្បង ទ្រង់ថ្លែងទៅកាន់ព្រះបិតាថា ៖

– « ខ្ញុំព្រះអង្គសូមទទួលភារៈ ទៅរកផ្កាឈូករ័ត៌នោះ; ប៉ុន្តែការដើរគ្រប់ទីកន្លែង ក្នុងការស្វែងរកយ៉ាងនេះ ត្រូវចំណាយលុយកាក់ច្រើន ដូច្នេះ សូមព្រះបិតាមេត្តាព្រះរាជទានមត៌ក ជាចំណែកខ្ញុំព្រះអង្គនោះមក ខ្ញុំព្រះអង្គនឹងចាប់ផ្ដើមធ្វើដំណើរស្វែងរកឥឡូវនេះ » ។

ព្រះមហាក្សត្រ បានព្រះរាជទានមត៌កនោះតាមពាក្យសុំ, បានហើយព្រះអង្គម្ចាស់ប៉េជ្រូ ក៏ទ្រង់ត្រាច់ចេញទៅ ។ ព្រះរាជបុត្រនេះបានធ្វើដំណើរចេញទៅឆ្ងាយ រួចបានជួបស្ត្រីចាស់ម្នាក់ អង្គុយសុំទាននៅលើចិញ្ចើមថ្នល់ ។ ប៉ុន្តែ ព្រះអង្គម្ចាស់ប៉េជ្រូ មិនបានជាអ្នកមានចិត្តសប្បុរសទូលំទូលាយទេ, ទ្រង់ប្រកែកមិនព្រមដាក់ទានអ្វីបន្តិច

ឲ្យយាយយាចកនោះសោះឡើយ ។ ព្រះអង្គម្ចាស់ចេះតែបន្តព្រះដំណើរទៅមុខទៀត ព្រោះទៅរកទីដៅតែមួយ គឺស្វែងរកផ្កាអូលើរនោះឯង ។ សប្តាហ៍ និងខែជាច្រើន ចេះតែកន្លងទៅ ៗ ព្រះអង្គម្ចាស់នៅតែរកផ្កាអូលើរ មិនទាន់បាន ។

ព្រះមហាក្សត្រ ដោយបាត់ព្រះរាជបុត្រច្បងអស់កាលយូរ មិនឃើញត្រឡប់វិលវិញដូច្នោះ, ទ្រង់ត្រាស់ហៅព្រះរាជបុត្របន្ទាប់ព្រះនាមហ៊្សុយអាន; មកហើយ ទ្រង់បង្គាប់ឲ្យចេញដំណើរ ទៅស្វែងរកផ្កាអូលើរនោះទៀត ។ ព្រះអង្គម្ចាស់ ហ៊្សុយអាននេះ បានសុំមតិជាចំណែកខ្លួនចំនួនពាក់កណ្តាល រួចទ្រង់ធ្វើដំណើរចេញទៅ ។ នៅលើចំណោមផ្លូវ, ទ្រង់បានជួបនឹងយាយយាចក ដែលអង្គុយសុំទាននោះទៀត ។ ដូចព្រះរៀមព្រះអង្គដែរ, ព្រះអង្គម្ចាស់នេះ បានប្រកែកមិនព្រមដាក់ទានអ្វី ឲ្យយាយអភ័ព្វនោះទេ គិតតែទ្រង់ធ្វើដំណើរទៅមុខទៀត ។ ទ្រង់ត្រាច់ទៅគ្រប់ទិសទី, ពិនិត្យមើលទេសភាពដោយចក្ខុទ្រង់ តែមិនបានប៉ះព្រះនេត្រ នឹងដើមអូលើរនោះឡើយ ។ សប្តាហ៍ជាច្រើន ក៏ចេះតែកន្លងទៅ ៗ ។

កាលដែលព្រះរាជបុត្រពៅព្រះនាមហ៊្សាសេ មិនឃើញព្រះជេដ្ឋាទាំងពីររបស់ទ្រង់ វិលត្រឡប់មកវិញដូច្នោះ ហើយដោយព្រះចក្ខុកេត

របស់ព្រះមហាក្សត្រជាព្រះបិតាទ្រង់ បេះតែមានដំណើរមិនស្រួលកាលៗ ថ្ងៃផងនោះ, ទ្រង់ចូលទៅទូលព្រះមហាក្សត្រជាព្រះបិតាថា ៖

- " សូមព្រះបិតា មេត្តាប្រសិទ្ធិពរដ៏យមកខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គនឹងល្បងចេញទៅកេផ្កាកូលាបនោះ ដើម្បីព្យាបាលព្រះចក្ខុព្រះបិតាឲ្យជាសះស្បើយ ។ " ។

ព្រះមហាក្សត្រ បានប្រទានពរសព្ទសាធុការដល់ព្រះរាជបុត្រទៅរួចហើយព្រះរាជបុត្រនេះ ក៏ចាប់ផ្ដើមធ្វើដំណើរចេញទៅ ។ ព្រះអង្គធ្វើដំណើរទៅឆ្ងាយ ឆ្ងាយណាស់តែបានទៅដល់កន្លែងស្ពានតាសំ ដែលអង្គុយសុំទានទោះឯង ។ ព្រះអង្គម្ចាស់ហ្នឹងសោ មានព្រះហឫទ័យពេញណែន ដោយមេត្តានឹងករុណា ចំពោះទុគ៌តភាពរបស់យាយកំសត់នោះយ៉ាងក្រៃលែង ទ្រង់ពោលទៅកាន់យាយទុគ៌តថា ៖

- " យាយ ! ខ្ញុំគ្មានប្រាក់ជូនយាយទេ, តែខ្ញុំនឹងចែកអាហារជូនយាយពិសារ ដោយសប្បាយចិត្ត, " ។

ពោលរួចហើយ ទ្រង់ស្រាយស្បៀងចេញ រួចជូនអ្វីដែលមានក្នុងស្បៀងនោះចំនួនពាក់កណ្ដាល ទៅយាយអភ័ព្វ ។ អ្នកទាំងពីរប្រាណ បានអង្គុយបរិភោគជាមួយគ្នា រួចទ្រង់បានរ៉ាយរ៉ាប់ប្រាប់រឿងស្វែងរករបស់ទ្រង់ ដល់យាយនោះ ។

ជូនចាស់ ពោលតបថា

- " ឱចៅអើយ ! អ្នកណាអាចរកដើមអូលីវក្នុងប្រទេសនេះបាន ! " ។

ព្រះអង្គម្ចាស់ បានងក់ព្រះសិរក្នុងការយល់ស្រប ។ ប៉ុន្តែនៅពេលដែលយាយបង្ហើយកិច្ចបរិភោគរួចហើយ, គាត់មានប្រសាសន៍បន្តទៅទៀតថា ៖

- « យាយសូមប្រាប់ចៅឯង ឲ្យស្គាល់កន្លែងដែលមានដើមអូលីវនោះផុះ ។ ចំនួនជាច្រើនម៉ៃល៍(១)ទៅខាងលិចឯណោះ, មានភ្នំមួយ, ឡើងតាមជំរាលប៉ែកខាងកើតនៃភ្នំនោះទៅ, មានព្រៃជង្គំមួយ ពេញទៅដោយដើមអូលីវ; នៅទីនោះ ចៅឯងមុខតែបានឃើញផ្កាអូលីវដោយពិត » ។

ពេលនោះ អ្នកទាំងពីរបានបែកគ្នា ព្រះអង្គម្ចាស់ហៀបសេ ទ្រង់យាងឆ្ពោះទៅទិសខាងលិច ដរាបដល់ភ្នំនោះឯង ។ នៅតាមចំណោតភ្នំប៉ែកខាងកើត ទ្រង់បានឃើញជង្គុំព្រៃអូលីវមានផ្ការីកស្គុះស្គាយ ដូចពាក្យយាយទុគិតប្រាប់មែន ។ ព្រះអង្គមានព្រះទ័យរីករាយយ៉ាងខ្លាំង, បានបេះផ្កាអូលីវនោះ រួចនាំយកត្រឡប់វិលទៅឯទីព្រះបិតាវិញ

(១) ១ ម៉ៃល៍ ១៦០៩ ម៉ែត្រ ។

យ៉ាំងស្រួសកន់ ។

នៅតាមផ្លូវ ទ្រង់បានជួបព្រះជេដ្ឋាទាំងពីររបស់ព្រះអង្គ ដែលមិនអាចស្វែងរកផ្កាអូលីវបាន សូម្បីមួយទេឡើយ ។ ជំនួសសេចក្តីរីករាយចំពោះព្រះកនិដ្ឋារបស់ព្រះអង្គ ដែលបានជោគជ័យក្នុងការស្វែងរកផ្កាអូលីវ, ព្រះជេដ្ឋាទាំង ២ នោះ ទៅជាមានសេចក្តីច្រណែនចំពោះការបំពេញកិច្ច បានសំរេចនេះទៅវិញ ។ ភ្លាមនោះ ទ្រង់ទាំងពីរក៏ដណ្តើមផ្កាអូលីវ អំពីប្អូន ហើយកាលដែលទ្រង់ដណ្តើមនោះ ទ្រង់វាយប្អូនយ៉ាំងដំណំ ដរាបដល់ដួលចុះទៅលើផែនដី, បាត់ព្រះវាចាលែងមានចលនាតទៅទៀតបាន ។

ភ័យចំពោះអំពើលាមក ក្រែងគេដឹងឮ, ព្រះរាជបុត្រច្បងទាំងពីរបានកកាយដីកប់ប្អូនពៅនោះក្បែរមាត់ផ្លូវ រួចប្រញាប់ប្រញាល់ឆ្ពោះទៅដំណាក់ព្រះបិតាព្រះអង្គ ។

ព្រះមហាក្សត្រ, កាលប៉េជ្រូ ទីនហ្ស៊ុយអាន ជាព្រះរាជបុត្រច្បងទាំងពីរ បានត្រឡប់មកវិញ យកទាំងផ្កាអូលីវមកជាមួយផងដូច្នោះ, ព្រះអង្គសោមនស្សយ៉ាំងក្រៃលែង ។ ពេលនោះ ចក្ខុប្រសាទព្រះមហាក្សត្រ ត្រូវវេជ្ជបណ្ឌិតព្យាបាលឲ្យជាល្អវិញដូចដើម, ម៉្លោះហើយមហាកិត្តិយស ក៏បានធ្លាក់មកលើព្រះរាជបុត្រច្បងទាំងពីរនោះ ។ តែ

ដោយព្រះកជបុត្រពៅរបស់ព្រះអង្គ មិនឃើញត្រឡប់វិលវិញ ហើយបេះតែបាត់ទៅ ៗ នោះ, ព្រះទ័យព្រះមហាក្សត្រ ពេញណែនទៅដោយសេចក្តីទុក្ខព្រួយពល់វេលា ។

នៅលើទីដែលព្រះអង្គម្ចាស់ ហ៊្យយការ ទឹងប៉េជ្រូ កប់ប្អូនពៅព្រះអង្គនោះ, វត្ថុចម្លែកមួយ បានកើតឡើង ។ ដើមប្របុសទាំងឡាយ បានដុះចេញមកក្រៅ ចំពីលើផ្នូរនោះ ។

ថ្ងៃមួយ អ្នកគង្វាលចៀមម្នាក់ បានដើរកាត់តាមទីនោះ ស្រាប់តែឮសម្លេងក្មេង ផ្សាយចេញពីដើមប្របុសទាំងនោះមក ៗ គាត់ចូលទៅជិត រួចផ្ទៀងស្តាប់, ចម្រៀងនៃប្របុសកំឡោះ បានហោះចេញមកយ៉ាងពីរោះថា ៖

ឲបង – ឃ្វាលចៀមជុំខ្ញុំមក ! ...
ដើម្បី – ខ្ញុំយកអំណាចស្តី ...
ថ្លែងប្រាប់ – រឿងពិតតាមសេចក្តី
ដល់ជនប្រុសស្រីពីផ្កាអូឈើ ! ... „ (១) ។

ព្តីពីរោះដូច្នេះ, អ្នកគង្វាលចៀម ក៏កាត់យកប្របុសនោះមួយដើម

(១) បទនេះ, បើអ្នកអាន បេះបទសម័យថ្មីឈ្មោះ «ផ្កាណាត្រី» អាចមើលត្រូវតាមសង្កាក់ឥឡូវនេះ ។

មកធ្វើជាខ្លុយ ។ កាលណាគាត់ផ្លុំខ្លុយនោះ ចម្រៀងដ៏ពីរោះ ក៏ដរ ដោយបទភ្លេងដដែលនោះ ក៏លាន់ចេញមកដូចមុន ។ អ្នកគង្វាលចៀម តែងត្រាច់ទៅគ្រប់ទីកន្លែងក្នុងប្រទេស ជាមួយនឹងខ្លុយដ៏វិចិត្ររបស់គាត់នោះ, ម្ល៉ោះហើយ ជនគ្រប់ដំបន់ បានស្តាប់ហើយចាប់ចិត្តចំពោះចម្រៀងខ្លុយនោះគ្រប់គ្នា ។

កិត្តិនាមនៃខ្លុយ បានផ្សាយទៅគ្រប់ទីកន្លែង, ជ្រាបរហូតដល់ព្រះមហាក្សត្រ ជាហេតុឲ្យព្រះអង្គ ចង់ស្តាប់ចម្រៀងដ៏ចំឡែកនោះ ។ ពេលនោះ អ្នកគង្វាលចៀម បានត្រូវព្រះមហាក្សត្រ បង្គាប់ឲ្យចូលខ្លួនទៅគាល់ ដើម្បីផ្លុំខ្លុយថ្វាយទ្រង់ព្រះសណ្ដាប់ ។ គាត់បានចូលខ្លួនទៅឈរពីមុខព្រះភក្ត្រព្រះមហាក្សត្រ, រួចហើយ គាត់ក៏លើកខ្លុយមកផ្លុំ ថ្វាយទ្រង់ព្រះសណ្ដាប់ដោយសុភាពរាបសារ ។ ចម្រៀងនៃប្រុសកំលោះក៏លាន់ចេញមកថា ៖

« ឱព្រះ - បិតាផ្លុំខ្ញុំមក ! . . .
ដើម្បី - ខ្ញុំយកអំណាចស្តី . . .
ក្រាបទូលរឿងពិតតាមសេចក្តី
បានជ្រាបតាមន័យផ្កាអូលីវ ! . . . » ។

ចម្លែកណាស់, ព្រះមហាក្សត្រ ក៏ក្រោកយកខ្លុយនោះមកផ្លុំ

ដោយព្រះអង្គឯង ៗ ពេលនោះ ព្រះអង្គឮច្បាស់ជាសម្មេងហើរ្ភសេ បុត្រពៅរបស់ព្រះអង្គ ទូលព្រះអង្គអំពីការដែលខ្លួនរកឃើញផ្កាម្លូលីវ និងពីអំពើដែលបុត្របងទាំងពីរបានវាយទ្រង់ រួចកប់ទ្រង់ក្បែរផ្លូវថ្នល់ ៗ

ដោយសេចក្ដីទុក្ខព្រួយ និងការគានតិងតប់ប្រមល់ព្រះហឫទ័យពេក, ព្រះមហាក្សត្របានឲ្យគេចាប់ខ្លួន ប៉េដ្រូ និងហ្វិយអាន ទៅដាក់គុក ៗ ក្រោមនោះ ទ្រង់ក៏ចេញដំណើរឆ្ពោះទៅរកផ្នូរនៃព្រាពជបុត្រពៅរបស់ព្រះអង្គ ៗ កាលទាហានរបស់ព្រះអង្គ បានរកឃើញកន្លែងមើមប្របុសនៅទីក្បែរថ្នល់នោះហើយ ក៏ជីកគាស់ដត្រង់នោះ រួចបានឃើញព្រះអង្គម្ចាស់ហើរ្ភសេ ត្រង់ទីនោះមែន ៗ ប៉ុន្តែ អព្ភតហេតុ មិនទាន់ចប់នៅឡើយទេ, ព្រះអង្គម្ចាស់ហើរ្ភសេ មិនទាន់សុគត ដូចដែលព្រះជេដ្ឋាទាំងពីរស្មាននោះទេ ៗ ព្រះអង្គបានក្រោកឡើង រួចស្ទុះទៅឱបព្រះមហាក្សត្រជាព្រះបិតា ១ ទ្រង់ព្រះសំណាក ដោយសេចក្ដីសប្បាយព្រះទ័យខ្លាំងពេក ៗ ពេលនោះឯង មានធ្វើពិធីបុណ្យ យ៉ាងទុឡារិកទទួលអំណរចំពោះការនិវត្តន៍នៃព្រះពជបុត្រពៅ ៗ

ដោយព្រះមហាក្សត្រ សប្បាយព្រះទ័យខ្លាំង ដោយហេតុបានជាសះស្បើយនៃចក្ខុរោគ និងការនិវត្តន៍វិញ នៃព្រះពជបុត្រពៅនោះ ព្រះអង្គបានដោះលែង ហ្វិយអាន និង ប៉េដ្រូ ចេញពីពន្ធនាគារវិញហោង ៗ

---

# ក្បួនដឹងទំនៀមខ្លះ នៅប្រទេសឥណ្ឌូណេស៊ី

អ្នកស្រី ពេជ-សល់ នាមដើម សារ៉ះយ៉ាន់ ប្រែ

---

គ្រណាំមធំបំផុតនៅប្រទេសឥណ្ឌូណេស៊ី គឺមិនឲ្យពាល់ដល់ម្លូកឈ្មួតក្បាល មុខ ឬ សក់នៃជនប្រុសស្រីឲ្យសោះ ។ ការពាល់ដូច្នេះជាការមើលងាយគេ ព្រោះថាក្បាលជាកំឡាំងធំ ហើយគេគោរពក្បាលណាស់ ប្រហែលគ្នានឹងទំនៀមខ្មែរយើងដែរ ។

បើអ្នកដើរទៅជួបនឹងមនុស្សស្រីដែលអ្នកស្គាល់, ការបើកមួកមិនមែនជាការចាំបាច់ទេ, ព្រោះអ្នកកាន់សាសនាមុយស៊ុលម៉ានពាក់មួកជាដរាប; ប៉ុន្តែអ្នកត្រូវឱនគោរពគេ ហើយចាប់ដៃស្តាំ ឬ យកដៃអ្នកទាំងពីរទៅចាប់ដៃស្តាំគេទៅវិញ ហើយពួកមុយស៊ុលម៉ានច្រើនតែបំពេញការគោរពដោយយកដៃទាំងពីរមកដាក់នៅទ្រូងម្តងទៀត ។

ពេលបរិភោគអាហារ, បើអ្នកជាម្ចាស់ផ្ទះ អ្នកមិនត្រូវឈប់បរិភោគមុនភ្ញៀវទេ ហើយមិនត្រូវលែងមុនភ្ញៀវផង ។ ប៉ុន្តែបើអ្នកជាភ្ញៀវវិញ អ្នកត្រូវបរិភោគឲ្យរួសរាន់ដើម្បីកុំឲ្យម្ចាស់ផ្ទះពិបាកចាំអ្នក ។ បើអ្នកអញ្ជើញទៅពិសាបាយនៅស្រុកស្រែវិញ អ្នកត្រូវពិសាដោយផ្ទាល់ដៃ, ហើយម្ចាស់ផ្ទះកាលបើពុំទាន់បានសួរអ្នកជាមុនថាតើអ្នកលែងត្រូវការអ្វីទៀតហើយឬ ? នោះគេពុំហ៊ានលាងដៃទេ ។ ឯចំណែក

អ្នកជាភ្ញៀវវិញ ត្រូវចាំឲ្យម្ចាស់ផ្ទះលាន់ដៃសិន សឹមហោនតាមក្រោយ បើពុំនោះទេ គេថាអ្នកជាមនុស្សឥតច្បាប់ ឬថាមើលងាយគេទៀតផង ។

បើចង់ហុចអ្វីឲ្យគេ ត្រូវចៀសវាងកុំហុចដៃឆ្វេងឲ្យសោះ ប្រើដៃឆ្វេងសំដែងអាការឥតច្បាប់បំផុត ។ បើនិងនិយាយទៅកាន់មនុស្សប្រុសចាស់ ទោះមនុស្សនោះបានជាអ្វីក៏ដោយ (អ្នកបោសជូត អ្នកសូមទាន អ្នកបំរើ នាយមន្ទីរ ឬ រដ្ឋមន្ត្រី) អ្នកត្រូវហៅថា "ឪពុក" ទាំងអស់ ឲ្យតែមនុស្សនោះចាស់ច្រើនជាងអ្នក ។ បើនិងនិយាយទៅកាន់ស្ត្រីវិញ ទោះស្ត្រីនោះជាអ្វីក៏ដោយក៏ត្រូវហៅ "ម៉ែ" ដែរ ។

បើកាលណាត្រូវទទួលអ្នកធំ មនុស្សដែលទៅទទួលនោះ ស្រែកថា „ មែរដើស ! មែរដើស ! ឬ ថាមែរដេកា មែរដេកា ! ដែលមានសេចក្តីថា "សេរីភាព ! សេរីភាព". ។

ចំពោះស្ត្រីជ្វា ៖ នៅក្រៅអំពីក្រុង ហ្សាកាតា ឬ ក្រៅអំពីកំពង់ចំណតនាវា ស៊ូរ៉ាបាយ៉ា ស្រីក្រមុំច្រើនពុំសូវកាន់ច្បាប់តឹងរឹងទេ ។ ក្រៅអំពីទីទាំងពីរខាងលើនេះ អ្នកត្រូវប្រយ័ត្នកុំពោលពាក្យលែបចង់ស្រីដោយផ្ទាល់ឲ្យសោះ ព្រោះសាសនា អ៊ីស្លាមគេហាមដាច់ បើអ្នកធ្វើដូច្នេះ មុខជាមានរឿងនាំឲ្យអំពល់ជាពុំខាន ។

នៅក្រុងស៊ូម៉ាត្រា ដែលគេនិយមយកម្តាយជាធំ ត្រូវកុំយក

ឈ្មោះឪពុកទៅហៅកូនគេឲ្យសោះ អ្នកហៅដូច្នេះហាក់ដូចជាជេរគេថា គេគ្មានត្រកូលត្រឹមត្រូវ ប៉ុន្តែត្រូវយកឈ្មោះបងប្រុសរបស់ម្តាយកូននោះទៅហៅវិញទើបប្រសើរ ហើយអ្នកកុំភ្លេចប្រកលុយឲ្យក្មេងនោះបន្តិចបន្តួចផង ។ នៅស្រុកនេះ ប្តីគេទុកជាអ្នកបន្ទាប់បន្សំទេ កូនមិនមែនជារបស់គេ ។

បើអ្នកទៅសំណាក់ផ្ទះគេ ហើយនៅពេលដែលគេនាំអ្នកទៅបង្ហាញបន្ទប់ បើគេសួរអ្នកថា «អ្នកត្រូវការប្រពន្ធជាតិហូល្លង់ដែរឬទេ ?» នោះ អ្នកកុំស្មានថាគេនាំស្រីម្នាក់មកឲ្យអ្នកឲ្យសោះ, ពាក្យនោះគេសម្រាប់ហៅខ្នើយឱបម្យ៉ាង ដែលទន់ជារណបសម្រាប់កល់ខ្លួនដើងអ្នក ឲ្យបានស្រួលប៉ុណ្ណោះទេ ។

អាវុធមិនៅក្រុងបាលី មានសភាពល្អគួរឲ្យពេញចិត្តណាស់ ហើយពិបាកដល់ជនជាតិប៉ែកបស្ចិមប្រទេសទៀតផង ព្រោះកូនស្រុកនោះមានចែកជនជាពួកជាកូន ប្រហែលគ្នានឹងនៅប្រទេសឥណ្ឌាដែរ ។

គោលធំបំផុត គឺយើងត្រូវតែដឹងខ្លួនថា តើយើងត្រូវបានច្បាប់អនុញ្ញាតឬទទួលតានដំណេកកំពស់ណា ។ ធម្មតាកូនស្រីរបស់ព្រាហ្មណ៍ត្រូវដេកខ្ពស់ជាងអ្នកបម្រើយ៉ាងតិចត្រឹម ១ ម៉ែត្រ ៥០ ។ បើដូច្នេះ គួរតែយើងរង់ចាំគេបង្គលបង្ហាញកន្លែងសិនសិមអនុញ្ញាត ឬ ទទួលតានដំណេក ។

ចំពោះជនបស្ចិមប្រទេសវិញគេច្រើនតែឲ្យរីករាយនឹងខ្ពស់ជាងគេ ។ គេរ៉ា អី ឬ ដើងម៉ា ជាទីខ្ពស់បំផុត ដែលគេអាចជូនជាកិត្តិយសដល់អ្នកអធិយ ។

បើអ្នកឃើញស្រីក្រមុំក្តី ស្រីមានប្តីក្តី ស្រីចាស់ក្តី ដែលដោះទទេ អ្នកកុំស្មានថាគេដែលបញ្ចោរអ្នកឲ្យសោះ គឺជាធម្មតារបស់គេទេ ។ ស្រីអ្នកស្រែ បើកាលណាគេឃើញអ្នកហើយ គេទាញក្រមាមកពីទូក មិនមែនជាគេខ្មាសអ្នកទេ, គឺគេគួរសមគំនាប់អ្នកហើយ ។ ប៉ុន្តែ បើចូលទៅប្រជុំវិញ ស្រីស្រុកបាលីតែងសំលៀកបំពាក់ណាស់ ។ បើអ្នកទៅលេងផ្ទះគេ ចូរអ្នកកុំភ្លេចយករបស់អ្វីបន្តិចបន្តួចទៅជូនគេជាការគួរសមផង ព្រោះជនជាតិបាលីកប់អានការឲ្យគ្នាណាស់ ហើយតែកាលណាអ្នកមានការទាក់ទងជិតដិតនឹងគេហើយ. មុខជាគេជូនរបស់អ្វីដល់អ្នកជាពុំខាន ។ ប៉ុន្តែ ចូលអ្នកប្រយ័ត្ន ! កុំយកផ្កាកដែលដាក់ថ្លៃរបស់នោះចេញឲ្យសោះ គេទទួលអំណោយដោយសប្បាយចិត្ត នឹងបានដឹងតម្លៃរតរបស់អ្នក ហើយគេនឹងបានលែលកយកមកជូនអ្នកវិញ ឲ្យបានប្រសើជាងបន្តិចផង ។

បើអ្នកឃើញស្រី ១ ដែលដោះទទេ អ្នកកុំសង្ឃឹមថានឹងបានចំណេញអ្វីក្រៅទៀត ហួសអំពីការដែលគ្រាន់តែបានមើលទទេនោះ

ឡើយ ទៀតផងតែជាមួយនឹងស្រីផ្កាមាស ។

បើអ្នកចង់បានទរគ លុះត្រាតែអ្នកមានទឹកខ្ទង់ត្រឹមត្រូវ ហើយអ្នកជណ្ដើងគេការទៅ ពេលនោះអ្នកចង់ការប្រពន្ធប៉ុន្មានក៏បាន ចង់បានអ្នកបំរើប៉ុន្មានក៏បាន ។

បើគេអញ្ជើញអ្នកទៅបុណ្យខ្មោច ចូរអ្នកជៀសវាងកុំធ្វើទឹកមុខស្រស់ធាន ព្រោះបុណ្យខ្មោចជាបុណ្យដែលគេត្រូវសប្បាយ ហើយទឹងស្រូបរញ្ញាញសេចក្ដីក្ដៀវក្ដាជាទីបំផុត ។ ប៉ុន្តែ បើគេអញ្ជើញអ្នកទៅបុណ្យខ្មោចពួកជនដែលនៅ «តាណាគម» ដែលជាភូមិនៅលើភ្នំវិញនោះ អ្នកមុខជានឹងត្រូវគេឲ្យបរិភោគបាយ ដែលចំអិនដោយទឹកដែលយកទៅស្រោចលើខ្មោច ហើយត្រងយកពីក្រោមមឈូសពុំខានឡើយ ។ គេបរិភោគដូច្នេះ ដើម្បីឲ្យបានទទួលនូវគុណសម្បត្តិរបស់បុគ្គលនោះ ។

# រឿងជ្រូកតច្ឆកៈ

## (ហាកនិបាតជាតក.បកិណ្ណកនិបាត)

ដោយ ហេង-សមអាន

---

## សាមគ្គីជាកម្លាំង

បទព្រហ្មគីតិ

ក្នុងកាលដ៏យូរយារ    នៅក្រុងពារាណសី
កាលនោះមានវឌ្ឍកី[១]    ខំឃ្លាតខ្ចីបរលីលា ។
ចូលព្រៃរកកាប់ឈើ    យកមកធ្វើកិច្ចនានា
ជួបកូនជ្រូកកំព្រា    ញ័ររងាក្នុងរណ្តៅ ។
ជាងឈើបានឃើញហើយ    ពុំកន្តើយបរចុះទៅ
លើកចេញពីរណ្តៅ    នាំយកទៅទុកឯផ្ទះ ។
ចិញ្ចឹមឲ្យបាយទឹក    ទាំងយប់ព្រឹកមិនឲ្យខ្វះ
ជ្រូកធាត់ធំរហ័ស    ឲ្យឈ្មោះតច្ឆកៈប្រសើរ ។
ជ្រូកជួយធ្វើកិច្ចការ    ប្រមៀលក្តារនិងអូសឈើ
តាមការសព្វសារពើ    ដែលអាចធ្វើបាននោះណា ។
ជាងឈើគាត់អាណិត    គិតក្នុងចិត្តម្នាក់ឯងថា

---

១– ជាងឈើ ។

"បើទុកជ្រូកនេះណា　　នៅទីនេះលុះយូរទៅ ៗ
ក្រែងមានមនុស្សលួចចាប់　　កាប់សម្លាប់នាំហ្មងសៅ
គួរតែអញនាំទៅ　　លែងព្រៃជ្រៅទើបបានសុខ" ៗ
នាំជ្រូកធាប់វៃៗ　　ចូលក្នុងព្រៃធំជ្រៅស្លុក
លែងជ្រូកឲ្យដើររុក　　រើរកសុខតាមចិន្តា ៗ
ជ្រូកដើរតែឯកឯង　　វែងចំបែងក្នុងព្រឹក្សា
បានជួបហ្វូងសុករ　　ក៏ពោលថា "អើ! ពួកក្រុម! ៗ
ពួកយើងដើរស្វែងរក　　ញាតិតាមញកច្រកល្ហកក្តុំ
តាមព្រៃព្រឹក្សតូច-ធំ　　ក៏ឯខ្ញុំស្វែងរកញាតិ ៗ
គ្រាន់ទឹងបានពឹងពួន　　ឥឡូវជួនជួបនឹងជាតិ
ជាក្រុមសង្គមញាតិ　　ដូចបំណងខ្ញុំប្រាថ្នា ៗ
មើមឈើមានគគោក　　បរិភោគតាមចិន្តា
មានទឹកស្រះរងថ្លា　　ជាកន្លែងគួររើកកាយ ៗ
យើងនឹងបានក្សេមក្សាន្ត　　សុខសាន្តគ្រាណសែនសប្បាយ"
ឮហើយជ្រូកតាំងឡាយ　　មិនខ្វល់ខ្វាយប្រាប់ទៅថា ៗ
"តប្ចកៈ! អ្នកចូរទៅ　　រកលំនៅទៀតចុះណា៎
នៅនេះមិនសុខា　　មានសត្រូវបៀតបៀនក្រុម ៗ

ចាប់ជ្រូកស៊ីពល់ថ្ងៃ មិនសំចៃទាំងតូច-ធំ។
គប្ចកៈសួរពួកក្រម ថា "ប្រាប់ខ្ញុំទៅណាអេះ ? ។
អង្គាសចាសយោរយៅ ជាសត្វនៅទីនេះ
ញាំញីអ្នកដល់ម្ល៉េះ ឲ្យវេបះស័ត្តមជាតិ ? ។
ដែលរួមគ្នាជិតស្និទ្ធ ចិត្តគំនិតមិនវៀត
ចូរប្រាប់អ្នកពិឃាត ធាប់ៗមកកុំតក់ស្លុត ? " ។
ហ្វូងជ្រូកប្រាប់ទៅថា "នៃអ្នកក្លាហានមោះមុត
មានខ្លាធំបំផុត បង្ខំមកគកៈចពេកក្រៃ ។
វាមកចាប់ជ្រូកស៊ី នៅកន្លែងទីនេះពល់ថ្ងៃ"
គប្ចកៈប្រាប់ថា "ហៃ មិត្ររួមឈាមគ្រប់រូបកាយ ។
ពួកយើងចង្កូមគាន តែយើងមានកម្លាំងកាយ ។
ឲ្យតែចិត្តស្រុះស្រោយ រួបរួមគ្នាជាសាមគ្គី ។
កំសាចទន់ចាប់សត្វ ដែលមុនីមាត់ដោយឫទ្ធិ
សម្លាប់ផ្តាច់ជីវិ កុំឲ្យនៅមានជីវា" ។
ហ្វូងជ្រូកស្តាប់ព្យញាស់ គ្រែកអរណាស់ឥតឧបមា
ឆ្លើយប្រាប់ទៅវិញថា "មិត្រស្នេហាពោលពីរោះ ។
ពីពេះណាស់គប្ចកៈ ពាក្យដែលអ្នកពោលមកនោះ

សែនពេញជាពីរោះ ត្រចៀកខ្ញុំពន់ពេកក្រៃ ។
ពួកយើងត្រូវតែប្តូរ ច្បាំងតស៊ូឲ្យដឹងដៃ
នឹងអាខ្លាចង្រៃ យកជាញជ័យខានតែបាន ។
ពេលច្បាំងថែនណា រត់ព្រោះការមិនក្លាហាន
ច្បាំងរួបយើងមិនខាន សម្លាប់ទោអ្នកនោះណា » ។
តប្ចកៈចិត្តអង់អាច ទាំងមានប្រាជ្ញាឈ្លាសវៀវក្លា
នាំជ្រូកក្នុងព្រៃក្បា ឲ្យរួមគ្នាជាសាមគ្គី ។
ហ្វូងជ្រូកស្រុះស្រួលចិត្ត មូលគំនិតស្និទ្ធមេត្រី
បេះស្តាប់ពាក្យសំដី ពាក្យបង្គាប់គ្នានឹងគ្នា ។
ហើយជ្រូកតប្ចកៈ ដែលជាអ្នកឲ្យបញ្ជា
បាកចេញចរលើលា រកភេទដីគ្រប់កន្លែង ។
ដោយឆ្លាសយុទ្ធវិធី យល់ថាទីឋាននេះឯង
នឹងយកជ័យជាក់ស្តែង ក្នុងកន្លែងនេះពុំបាន ។
ក៏ខំប្រឹងឃ្លាតខ្ចី រកភេទដីគ្រប់សណ្ឋាន
ដើររកពាល់តែបាន ភេទដីល្អពេកណាស់ណា ។
តប្ចកៈ រៀបក្បួនប្រ- យុទ្ធតាំងតនឹងស្តេចខ្លា
បាត់រៀបក្បួនយុទ្ធនា គឺរៀបក្បួនបទុមព្យូហ៍ ។

ក្បួនបទុមព្យូហ៍នេះ　　តាមខ្ញុំបេះបានគិតគូរ
ជាក្បួនបទុមព្យូហ៍　　នេះគឺក្បួនសំបុកឃ្មុំ(១) ។
តម្កល់រៀបទ័ពជ្រូក　　ដូចផ្កាឈូកនៅក្រពុំ
ឬដូចជាសត្វឃ្មុំ　　កំពុងហើរលើអាកាស ។
ចាត់រៀបជ្រូកដក　　ដែលគ្រាំគ្រាទ្រុឌទ្រោមណាស់
ទីងកូនជ្រូកដេរដាស　　នៅពៅដោះព្រមទាំងមេ ។
ឲ្យនៅកន្ទុងមួយ　　មិនឲ្យព្រួយគិតរះរេ
ចាត់ជ្រូកខ្វាយជាងគេ　　ទីងជ្រូកមេពេញក្រមុំ ។
ឲ្យនៅថែរក្សា　　ញាតិគ្រួសារដែលនៅជុំ
ចាត់ជ្រូកមាឌធំៗ　　ឲ្យពទ្ធហ៊ុំក្រុមគ្រួសារ ។
ហើយចាត់ជ្រូកកម្លោះ　　នៅចន្លោះនោះឯណា
ដើម្បីឲ្យជួយការ-　　ពារមុតមាំបានរឹងប៉ុង ។
រួចជ្រើសជ្រូកចំណាន　　ចិត្តក្លាហានស្វាតរឹង
សម្រាប់គ្រាន់ទីងពីង　　បេញចព្វាំងទីងខាកម្ចៅ ។
ហើយចាត់ជ្រូកឲ្យឈ្មុស　　ដឹទម្លុះជារណ្ដៅ

(១) សម័យមុនហៅថា«ក្បួនបទុមព្យូហ៍» បច្ចុប្បន្នសម័យនេះហៅថាក្បួនសំបុកឃ្មុំ (Formation en essaim)

បញ្ឆោតខ្លាធំខ្លៅ ឲ្យធ្លាក់ស្លាប់សូន្យជីវា ៗ
តក្កៈ រៀបក្បួនហើយ ពុំកន្ដើយទូន្មានថា
«ម្នាល! មិត្តជាតិសុករ ប្អូនអ្នកកុំភ្លេចស្មារតី ៗ
តាំងចិត្តឲ្យអង់អាច កុំភ័យខ្លាចចោរពៃរី
កម្លាំងសាមគ្គី អាចយកជ័យជំនះបាន ៗ
ពេលសាយណ្ហសម័យ នៅក្នុងព្រៃព្រឹក្សាឋាន
ហ្វូងជ្រូករួមគ្រប់ប្រាណ មូលមិត្រស្និទ្ធជាផ្នែកក្រុម ៗ
ត្រៀមខ្លួនទុកសម្រាំង ចាំប្រុងច្បាំងនឹងខ្លាធំ
ការពារក្រុមសង្គម ឲ្យរួចចាកពីទុក្ខា ៗ
ក្នុងពេលនោះឯងព្រះ- អាទិត្យរះស្មើព្រឹក្សា
បំភ្លឺមនុស្សលោកា ក្នុងទ្វីបាគ្រប់ទាំងអស់ ៗ
ពេលភ្ញាក់ពីដេក មានចិត្តត្រេកអរមុខស្រស់
ស្វែងរកទ្រព្យរបស់ សម្រាប់រស់នៅជាសុខ ៗ
ថ្ងៃពីងស្ដេចខ្លា ភ្ញាក់កាលណាមិនស្រណុក
ក្នុងពោះញ័រប៉ផ្អុក ឃ្លានចង់ឆីសាច់ជ្រូកឆៅ ៗ
ចេញចាកពីសំណាក់ ផងដិលម្នាក់ចិត្តឃោរឃៅ
ដើរលៀនគ្គោះត្រង់ទៅ ទីលំនៅហ្វូងសុករ ៗ

ហ្វូងជ្រូកបានឃើញហើយ មិនកន្ទើយប្រាប់ទៅថា
"លោកមេបញ្ជាការ ឥឡូវខ្លាវ៉ាមកហើយ" ៗ
តប្ចូក: បានឃើញពិត ពោលថា "មិត្រទាំងឡាយអើយ
ចូរអ្នកកុំភ័យឡើយ ប្រុងស្មារតីកុំបណ្ដោយ ៗ
បើខ្លាធំវ៉ាធ្វើ នូវអំពើណាក៏ដោយ
ចូរមិត្រកុំឲ្យធ្លោយ ធ្វើឲ្យដូចវ៉ាកុំខាន ៗ
ដើម្បីឲ្យដឹងថា ហ្វូងសុករប្រុងប្រៀបប្រាណ
ប្រឆាំងជាមិនខាន គួរតយុទ្ធយ៉ាំងពេញទី ៗ
ខ្លាលុតខ្លួនប្រុងតែ ស្រែករន្ធត់ញ័រធរណី
នោមរ៉ាត់ជាន់ញក់ញី ល្អិតខ្ទិចខ្ទីព្រៃព្រឹក្សា ៗ
ហាក់លោតស្ទុះទៅលូក សង្គ្រប់ជ្រូកដូចធម្មតា
ជ្រូកធ្វើនូវកិរិយា តាមស្ដេចខ្លាគ្រប់រូបកាយ ៗ
ខ្លាយល់អាការ: យ៉ាំងច្បាស់ជាក់ពីចម្ងាយ
ក៏ងាកបៀសចេញឆ្ងាយ ដោយគិតស្ដាយពន់ពេកក្រៃ ៗ
ខ្លាគិតក្នុងចិត្តថា "ថ្ងៃនេះណាថ្ងៃកជាងថ្ងៃ
មុនៗគួរសង្ស័យ គួរពិភាល់ទឹងសុករ ៗ
ប្រហែលជាវ៉ាបាន អ្នកក្លាហានគបបញ្ញា

ជាមេនាំចាត់ការ    បានជារាប្រឹងប្រយ័ត្ន ។
រួមគ្នាជាសង្គម    តាំងតូចធំច្រើនពេកក្តាត់
អញគួរកុំចាប់សត្វ    ដំក្លាហានយ៉ាងនេះឡើយ ។
គិតហើយក៏ចូលទៅ    ទីលំនៅៗកទ្ដើយ
គ្មានស្ដីធ្វើព្រងើយ    សម្ងំនៅតែឯកឯង ។
ជជិលកោងអង្គុយ    ស្ងៀមមុយៗផ្អែកចំខែង
ចាំខ្លាត្រង់ផ្លូវកែង    មិនដែលមានថ្ងៃណាម្ដង ។
ពេលមុនខ្លាវិលមក    តែងនាំយកសាច់ពល់ជង
ពេលនេះមិនដូចប៉ង    ដែលធ្លាប់មានហើយពោលថា ។
«ថ្ងៃនេះថ្ងៃស្អាក់ស្អើរ    ឥតអំពើ គ្មានបានការ
ប្រហែលជាស្ដេចខ្លា    វៀរចាកបាណាតិបាត ។
អភ័យទានឲ្យដល់    សត្វសាកលមិនឲ្យផ្លាត
ឬមានគេធ្វើឃាត    ទិនចង្រៃបាក់ឬអ្នក ? ។
បានជាអ្នកចូលទៅ    ដល់លំនៅហ្វូងសុករៈ
មកវិញញញ័រញញាក់    អាណិតអ្នកពេកណាស់ណា» ។
ខ្លាធំស្ដាប់ឮហើយ    ក៏ថ្លងឆ្លើយប្រាប់ទៅថា
«ក្របកទីងតាហា(១)    តាំងកម្លាំងខ្ញុំនៅមាន ។

១ បង្កួម ។

តែខ្ញុំឃើញសុកក នៅត្រៀបត្រាក្នុងព្រៃហាន
ប្រុងប្រៀបប្រយ័ត្នប្រាណ រួបរួមគ្នាជាសាមគ្គី ។
ថ្ងៃមុនជ្រូកឃើញខ្ញុំ រត់ចោលក្រុមទៅកេទី
ពួនខ្លួនក្បែរគេរ គ្រប់ទិសទីតាំងតូច-ធំ ។
ថ្ងៃនេះជ្រូកទាំងឡាយ ព្រមព្រៀងកាយជាស័ន្ធម
ប្រយ័ត្នទាំងតូច-ធំ រួមមូលផ្តុំជិតគ្នា ។
ហ្វូងជ្រូកចេះរួមក្បែរ ដោយមានអ្នកមេបញ្ជា
ឲ្យជាតិរបស់វា មូលមិត្រគ្នាជាសាមគ្គី ។
ហ្វូងជ្រូកទាំងឡាយនោះ ប្រុងប្រទុស្តខ្ញុំពេញទី
ឃើញខ្ញុំមិនញញី ញញ័រកេតពួនអាត្មា ។
បានជាខ្ញុំមិនហ៊ាន ចូលចំពានចាប់សុកក
តែក្រែងនាំឲ្យថ្ងសការ ដល់អាត្មាក្ស័យជីវ" ។
ជជិលគោងបានស្តាប់ ខ្លាសាស័ព្ទប្រាប់សព្វទី
យល់ថាមិនបានស៊ី ឆ្អឹងជំនីជ្រូកមែនពិត ។
ហើយពោលបញ្ឆោរថា «នែះស្តេចខ្លា! មានពលឫទ្ធិ
មានទាំងអំណាចពិត កុំភ័យភិតតក់ស្លុតខ្លាច ។
គ្រាន់តែស្រែកសំឡុត ហក់ស្ទុះលុតចូលអង់អាច

សម្តែងថ្វីអំណាច　　ជ្រូកមិនអាចរួមគ្នាបាន" ។
ខ្លាឮពាក្យបញ្ឈោរ　　ឡើងដំនោរហួសប្រមាណ
កើតចិត្តយ៉ាងក្លាហាន　　មិនខ្លាចប្រាណបានមក: ។
ហើយបោលចូលសំដៅ　　ឆ្ពោះលំនៅហ្វូងសុករ:
ជាគូប្រតិបក្ស　　ប្រុងប្រយ័ត្នគ្រប់អាត្មា ។
ខ្លាលោតទន្ទ្រាំដី　　ស្ទុះក្រញីចាប់សុកក
បំជ្រូកមេចាត់ការ　　តែដោយសារស្ហាវតើរង ។
គប្ចក: លោតចេញជាក់　　ខ្លាក៏ធ្លាក់ក្នុងរណ្តៅ
ដែលបានជីកយ៉ាងជ្រៅ　　ទុកបញ្ឆោតនូវស្តេចខ្លា ។
គប្ចក: សុករ:　　ស្ទុះលោតចាក់បុកប្រហារ
នឹងខ្នាយស្រួចមុតថ្លា　　ដល់ជីវាសូន្យក្សណក្ស័យ ។
គប្ចក: បានសម្លាប់　　ស្តេចខ្លាស្លាប់ត្រេកអរក្រៃ
នាំគ្នាចូលតដៃ　　នឹងជដិលគោងទៀតណា ។
ហ្វូងជ្រូកបោលចូលទៅ　　ទីលំនៅរបស់តា -
ជដិលដែលត្រូវជា　　ចៅហ្វាយនាយខ្លាកំឡោ ។
នាំគ្នាខាំប្រតាយ　　ទាញប្រញាយហែកធីទៅ
ធីអស់មិនឲ្យនៅ　　សេសសល់ទុកជាកំរៃ ។

ពេលនោះទេពារក្ស ដែលជាអ្នករក្សាព្រៃ
ឃើញហេតុអស្ចារ្យក្រៃ បានបន្ទឹភាសិតថា ។
"ញាតិមានច្រើនប្រពៃ ឈើក្នុងព្រៃក៏ដូចគ្នា
ហ្វូងជ្រូកមានសាមគ្គា ព្រមព្រៀងគ្នាជាសង្គម ។
ញុំាងសេចក្តីអង់អាច មិនភ័យខ្លាចឲ្យមូលមុម
សម្លាប់ខ្លាយ៉ាងធំ ទីងជដិលឲ្យស្លាប់បាន" ។
ហ្វូងជ្រូកបានសម្លាប់ សត្រូវស្លាប់ទាំងពីប្រាណ
រួចស្រេចហើយក៏បាន លើកតប្ចកៈឲ្យជាធំ ។
ជាស្តេចគ្រងត្រួតត្រា លើសុកកទាំងសង្គម
ការពារទាំងតូច-ធំ ក្នុងសង្គមតៈទៅហោង ! ! ។

## សារណកាព្យ

### បទកាកគតិ

ពួកជ្រូកគ្រប់ប្រាណ
ជាជាតិតិរច្ឆាន នៅក្នុងព្រឹក្សា គ្មានសៀវភៅមើល
គ្មានគ្រូអាចារ្យ គ្មានបានសិក្សា ន.មោ-យសិទ្ធ ។
វាចេះស្រឡាញ់
ទឹកចិត្តគួចកាញ់ រួមគ្នាជិតស្និទ្ធ ការពារសាច់ញាតិ

រួមជាតិលោហិត    រួចរាកភ័យភិត    ពីមហន្តរាយ ៗ

ជ្រករួមសាមគ្គី

ទាំងឈ្មោលទាំងញី    ចិត្តស្រួលស្រុះស្រាយ    កំចាត់សត្រូវ

ដល់នូវអន្តរាយ    វិនាសខ្ចាត់ខ្ចាយ    រូបកាយមតំ ៗ

ហេតុនេះជាតិអើយ

កុំនៅព្រងើយ    ស្ទុះក្រោកឡើងខ្មី    ឈរឲ្យត្រង់ខ្លួន

ទឹងទួនស្មារតី    ខំប្រឹងឃ្មាតខ្មី    ពួតកម្លាំងគ្នា ៗ

ចូររួមសាមគ្គី !

ទាំងប្រុសទាំងស្រី    ប្រឹងប្រែងតុះតារ    នូវឧបសគ្គ

រួមរក្សមូលគ្នា    ដើម្បីការពារ    នូវប្រទេសជាតិ ៗ

ចូររួមសាមគ្គី !

ទាំងប្រុសទាំងស្រី    ប្រឹងប្រែងខ្មីឃ្មាត    ព្រោងពុទ្ធសាស្នា

សាស្តាលោកនាថ    ឲ្យថ្កើងដល់ខ្នាត    ប្រាំពាន់វស្សា ៗ

ចូររួមសាមគ្គី !

ទាំងប្រុសទាំងស្រី    ការពាររក្សា    ព្រះរាជបល្ល័ង្ក

រាំងបច្ចា–    មិត្រគ្រប់ទិសា    កុំឲ្យក្បត់បាន ៗ

នឹងអព្យាក្រឹត្យ

ឯកពជ្យពិត១ ជាតិខ្មែរគ្រប់ប្រាណ ប្រឹងប្រែងពង្រឹង
ឲ្យរឹងប៉ុនបាន រុងរឿងថ្កើងថ្កាន ជាជាវរៈ ។
បើរួមសាមគ្គី
គ្មានអំណាចអ្វី ឬឧបសគ្គៈ ចូលមកកំងព
យាយីឲ្យធ្លាក់ ចុះក្នុងហីនៈ ទាសៈបានឡើយ ។
មានតែថ្កុំថ្កើង
ចំរើនខ្ពស់ឡើង សម្បូណ៌ឥតសៅយ បានសន្តិសុខ
គ្មានទុក្ខព្រួយឡើយ ពស្ត្របានហើយ ទាំងអ្នកពជការ ។

## ផ្នែកកំណត់ហេតុប្រវត្តិការណ៍

# ពិធីបុណ្យព្រហ្មទាន

ចែករង្វាន់សមណនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត និង ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជឆ្នាំ ១៩៦០ ក្រោមព្រះរាជាធិបតីភាព នៃសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ។

*កាលពីថ្ងៃទី ១៩ វិច្ឆិកា ១៩៦០ វេលាម៉ោង៨, ៣០នាទី ក្រសួងធម្មការបានធ្វើពិធីបុណ្យព្រហ្មទាន ចែករង្វាន់ដល់សមណនិស្សិតពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ចំនួន ៦០ រូប និងពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ចំនួន ៧១ រូប រួមជា ១៣១ រូប ក្រោមព្រះរាជាធិបតីភាពនៃសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ។*

*មានឥស្សរជនទាំងបព្វជិតទាំងគ្រហស្ថ បាននិមន្ត បានអញ្ជើញមកជាច្រើនក្នុងពិធីបុណ្យនេះ ។*

*ឥស្សរជនផ្នែកខាងបព្វជិត គឺសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ, សម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្ត, រាជាគណៈ, ឋានានុក្រម, សាស្ត្រាចារ្យ ព្រមទាំងព្រះថេរានុត្ថេរៈទាំងឡាយ ។*

*ឥស្សរជនផ្នែកខាងគ្រហស្ថមាន : សហជីវិន ជួប-ហែល ប្រមុខ*

រដ្ឋស្តីទី, សហជីវិនប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ សហជីវិននាយករដ្ឋមន្ត្រីស្តីទី សមាជិករដ្ឋាភិបាល, នាហ៊ុនសព្ទមុខមន្ត្រីទីធំម្ចាស់ព្រហ្មទានជាដើម ។

ពេលម៉ោង ៩ ព្រឹក, សម្តេចព្រះមហាក្សត្រិយានី ស្តេចយាងមកដល់ មានក្រុមទាហានកេក្សាព្រះអង្គធ្វើគារវកិច្ច និង ភ្លេងជាតិប្រគំថ្វាយជាព្រះរាជកិត្តិយស ។

ពេលម៉ោង ៩,០៥ នាទី, សហជីវិន សរ-គិមកួយ អនុរដ្ឋលេខាធិការក្រសួងធម្មការ បានថ្លែងនូវសុន្ទរកថាដូចតទៅនេះ ៖

សូមព្រះតេជៈដកល់លើត្បូង !

សូមព្រះរាជទានក្រាបបង្គំទូល សម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិត

សូមទ្រង់ជ្រាប ក្រោមល្អងធូលីព្រះបាទ ។

ក្នុងនាមនៃព្រះរាជរដ្ឋាភិបាល និងក្នុងនាមនៃទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានថ្លែងនូវអំណរព្រះករុណាធិគុណដ៏ជ្រាលជ្រៅចំពោះសម្តេចជាម្ចាស់ ដែលបានស្តេចយាងជាព្រះរាជាធិបតីនាពេលក្នុងពិធីបុណ្យចែកព្រហ្មទានដល់សមណនិស្សិតក្នុងថ្ងៃនេះ ។

សូមទ្រង់ព្រះមេត្តាប្រោស !

ភេរីនព្រហ្មទានដែលបានរៀបចំយ៉ាងវិចិត្រដ៏គាល់នៅចំពោះព្រះភក្ត្រព្រះអង្គនេះ គឺជាព្រះរាជអំណោយដ៏ថ្លៃថ្លារបស់ព្រះអង្គ ទ្រង់ព្រះមេត្តាប្រោសព្រះរាជទានដល់សហជីវិន ប្រធានសមាគមពុទ្ធិកវិទ្យាល័យ នូវព្រហ្មទានជាគម្ពីចំនួន ៧៦ ចំពោះ ៤៩ ដែលពួកក្រុមអភិបាលសមាគមនិងពុទ្ធបរិស័ទ បានចាត់ចែងរៀបចំគ្រឿងបរិក្ខារ និងព្រហ្មទានថែមទៀតដើម្បីសូមព្រះរាជទានចាប់មគ្គផលជាមួយព្រះអង្គ បានគ្រប់ជាព្រហ្មទានចំនួន ១៣១ ។

ព្រះឧត្តមគតិជាមហាកុសល ដែលបានផុសអណ្តែតត្រសែតក្នុងពេលនេះ អាចចាត់ទុកបានថាជាមហាពលិកម្ម ១ ដ៏ថ្លៃថ្នូរ ចំពោះព្រះពុទ្ធសាសនា ប្រៀបបីដូចជាឧសថដ៏វិសេស សម្រាប់ប្រស់ព្រំទឹកព្រះទ័យរបស់សមណនិស្សិតពុទ្ធិកវិទ្យាល័យ និងពុទ្ធិកមហាវិទ្យាល័យ ឲ្យមានសេចក្តីក្លាហាន តស៊ូក្នុងការរៀនសូត្រខាងព្រះពុទ្ធសាសនា ឲ្យបានចំរើនលូតលាស់ឡើង ។

មួយវិញទៀត, ព្រះពលិកម្មជាមហាកុសលរបស់ព្រះអង្គនេះ ជាទីញុំាងទឹកព្រះទ័យនៃព្រះសង្ឃទាំងអស់ មានសមណនិស្សិតជាដើមឲ្យរីករាយ ហើយចងចាំជានិច្ចពុំបានភ្លេចឡើយ ព្រោះព្រះពលិកម្មនេះអាចជួយសម្រាលនូវបន្ទុកដ៏ធ្ងន់ នៃសមណនិស្សិតដែលមានសេចក្តីខ្វះខាត

ចំពោះគ្រឿងបរិក្ខារ ជាមធ្យោបាយដ៏ប្រសើរ សម្រាប់គោលព្រះពុទ្ធសាសនាឲ្យមានរស្មីតែភ្លឺត្រចះត្រចង់ឡើង ក្នុងសាកលលោក ។

ដោយព្រះអង្គទ្រង់ព្រះតម្រិះឈ្វេងយល់អត្ថប្រយោជន៍ជាសារវន្តនេះ ទើបព្រះអង្គទ្រង់សព្វព្រះរាជហឫទ័យ ព្រះរាជទានទូវព្រហ្មទានខាងលើនេះ ជានិមិត្តរូបដ៏ឧត្តមនៃទឹកព្រះរាជហឫទ័យដ៏ស្មោះសរបស់ព្រះអង្គ ។

សូមទ្រង់ព្រះមេត្តាប្រោស !

បន្ទាប់តពីនេះទៅ ទូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទានព្រះបរមរាជ-វរោកាសព្រះអង្គ ថ្លែងសេចក្តីប្រាស្រ័យជាមួយព្រះសង្ឃនិងអស់លោកទាំងឡាយ ដែលបាននិមន្ត អញ្ជើញមកកាន់ពិធីបុណ្យនេះ ។

សូមក្រាបថ្វាយបង្គំសម្តេចព្រះសង្ឃនាយកទាំង ២ គណៈ ព្រមទាំងព្រះថេរានុត្ថេរៈទាំងអស់ -

-ទ្រង់

-ឯកឧត្តម

-អស់លោក

វេលានេះ ខ្ញុំព្រះករុណា-ខ្ញុំ មានសេចក្តីត្រេកអររីករាយក្រៃពេក ដោយបានឃើញសម្តេច-ទ្រង់-ឯកឧត្តម និងអស់លោកទាំងឡាយ បាននិមន្ត-យាង-អញ្ជើញមកជួបជុំក្នុងទីនេះ ដោយព្រះទ័យប្រកបដោយ

សោមនស្សប្រេតនាជាមហាកុសលដ៏ប្រសើរ ដើម្បីបំពេញកិច្ចការកុសលនេះឲ្យមានសភាពរុងរឿងជាទ្វេរគុណ សមតាមប្រវេណីនៃពុទ្ធសាសនាជាពិសេសគឺអស់លោក ដែលបានចូលព្រហ្មាន ជារៀងរាល់សមណនិស្សិតថែមទៀត ដើម្បីជួយហែហមព្រះព្រហ្មានសម្ដេចជាព្រះមាតាជាតិឲ្យបានអធិកអធម ជាកិយោភាព ។

ក្រសួងធម្មការមានសេចក្ដីសង្ឃឹមយ៉ាងមាំទុកជាមុន លើព្រះតេជព្រះគុណជានិស្សិតគ្រប់ព្រះអង្គនេះ ថានឹងព្យាយាមសិក្សារៀនសូត្រខាងពុទ្ធសាសនាឲ្យបានចំរើនលូតលាស់ដុសដាលឡើងជាលំដាប់ នឹងបានជាអនាគតរបស់ប្រទេសកម្ពុជាផែកខាងពុទ្ធចក្រ ព្រមទាំងខំបំរើជាតិ-សាសនា-នឹងព្រះមហាក្សត្រ ដែលជាត្រៃរត្នដោយស្មោះត្រង់អស់ពីដួងព្រះទ័យគ្រប់ព្រះអង្គ ។

ជាអវសាននៃសុន្ទរកថានេះ ទូលព្រះបង្គំជាខ្ញុំ ខ្ញុំព្រះករុណា-ខ្ញុំសូមសំដែងដោយគោរពនូវកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅ ចំពោះសម្ដេចព្រះមហាក្សត្រិយានី ជាកម្ចាស់ជីវិតលើត្បូង ហើយសូមលើកយកកុសលរាសីដ៏ថ្លៃថ្លានេះ ថ្វាយចំពោះព្រះអង្គ នឹងសម្ដេចព្រះឧបយុវរាជ សូមព្រះអង្គបិតនៅក្នុងព្រះបរមសុខ នឹងជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋ ទាំងព្រះសង្ឃនឹងគ្រហស្ថគ្រប់រូប សូមព្រះអង្គឈ្នះមារសត្រូវគ្រប់ទិសទីប្រកប

ដោយសិរីសួស្តីជ័យមង្គលគ្រប់ប្រការ សូមសត្វទាំងឡាយលោយ រលត់បាត់បង់ទៅជាអហោសិកម្ម ។

មួយវិញទៀត ខ្ញុំព្រះករុណា-ខ្ញុំ សូមប្រគេន ជូន សម្តេចទាំង ២ ព្រះអង្គ ទាំងអស់លោកទាំងអស់ដែលបានជួយបាច់មគ្គផលកង្កការកុសល នេះ សូមឲ្យបានជួបប្រទះនូវសេចក្តីសុខចំរើន ចាប់ពីពេលនេះតរៀងទៅ ។

លុះសហជីវិន អនុរដ្ឋលេខាធិការ ក្រសួងធម្មការ បានថ្លែង សុន្ទរកថាចប់ហើយ, ព្រះតេជៈព្រះគុណព្រះពោធិវង្ស អគ្គាធិការពុទ្ធិក. សិក្សា តាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត បានថ្លែងនូវសុន្ទរកថាដូច តទៅនេះ ។

សូមថ្វាយព្រះពរ សម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិត !

ឱកាសនេះ អាត្មាភាព កងនាមនៃសាស្ត្រាចារ្យនិងបុគ្គលិកទាំង អស់ នៅពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ និងពុទ្ធិកវិទ្យាល័យព្រះ សុរាម្រិត សូមថ្លែងនូវមនោសញ្ចេតនាដ៏សម្បយុត្តដោយប្រីតិប្រាមោជ្ជ ចំពោះសម្តេចជាព្រះមាតាជាតិ ដែលទ្រង់មានព្រះរាជហឫទ័យប្រកប ដោយមេត្តាករុណា ស្តេចយាងមកជាព្រះរាជាធិបតីនៃពិធីបុណ្យប្រគេន ព្រហ្មទានដល់សមណនិស្សិតទាំងឡាយនៅពុទ្ធិកវិទ្យាល័យ និងពុទ្ធិក. មហាវិទ្យាល័យនេះ ។

បុណ្យប្រគេនព្រហ្មទានដល់សមណនិស្សិតទាំងឡាយ ដែលមានព្រះអង្គសម្តេចព្រះមាតាជាតិជាព្រះរាជាធិបតី ព្រមទាំងសម្តេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ទឹងទ្រង់ឯកឧត្តម អស់លោកទាំងឡាយ ដែលបានទិមន្ត ស្តេចយាង អញ្ជើញមករួបរួមជាមួយផងនេះ អាចចាត់ទុកជាមហាកិត្តិយសដ៏ប្រសើរ ទឹងជាមហាមង្គលដ៏ឧត្តម នាំឲ្យពុទ្ធិកមហាវិទ្យាល័យ ទឹង ពុទ្ធិកវិទ្យាល័យ ចារឹកទុកក្នុងប្រវត្តិរបស់ខ្លួនតទៅអនាគត ។

សូមថ្វាយព្រះពរ !

ព្រហ្មទានដែលសម្តេចទ្រង់សព្វព្រះរាជហឫទ័យ ប្រោសព្រះរាជទាន ប្រគេនដល់សមណនិស្សិតទាំងឡាយក្នុងគ្រានេះ ឈ្មោះថាជាមហាកុសលមួយដ៏ថ្លៃថ្លាណាស់ ដោយរួបរួមជាមួយនឹងព្រហ្មទានរបស់សមាគមពុទ្ធិកវិទ្យាល័យ ទឹងពុទ្ធបរិស័ទទាំងឡាយផង ព្រោះជាហេតុនាំឲ្យសមណនិស្សិតទាំងឡាយ មានចិត្តរីករាយប្រកបដោយកតញ្ញូតាធម៌ចំពោះព្រះមហាករុណាទិគុណនៃសម្តេចជាព្រះមាតាជាតិ ដែលមិនអាចនឹងបំភ្លេចបានឡើយ ។

អាត្មាភាពមានសេចក្តីសង្ឃឹមថា ព្រហ្មទាននេះ នឹងអាចប្រព្រឹត្តទៅជាគ្រឿងឧបករណ៍មួយយ៉ាងវិសេសវិសាល បណ្តាលឲ្យទឹកចិត្តនៃសមណនិស្សិតទាំងឡាយ ជិតជាប់ក្នុងការសិក្សាតទៅ រហូតដល់បាន

ទទួលនូវលទ្ធផលក្នុងអនាគតពុំខាន ។

លំដាប់អំពីនេះ អាត្មាភាពសូមព្រះរាជទានព្រះរាជឱកាស ដើម្បីថ្លែងនូវសេចក្តីរំលឹក ចំពោះសមណនិស្សិតទាំងឡាយ ។

អស់លោកជាសមណនិស្សិត !

លោកគ្រប់រូបសុទ្ធសឹងតែជាកូនចៅ នៃប្រជាពលរដ្ឋក្នុងប្រទេសកម្ពុជា បានលះបង់ញាតិញោមដែលនៅតាមខេត្ត ស្រុក-ឃុំ និងមជនបទ ហើយបានចូលមកសិក្សាក្នុងមហាវិទ្យាល័យ និងវិទ្យាល័យនៅក្នុងរាជធានីនេះ ជាកន្លែងសិក្សាដែលឋិតនៅក្រោមព្រះបរមរាជូបត្ថម្ភ នៃសម្តេចព្រះមហាក្សត្រិយានី ជាព្រះមាតាជាតិ និងសម្តេចជាព្រះប្រមុខរដ្ឋ ដោយមានរាជរដ្ឋាភិបាលនៃសង្គមរាស្ត្រនិយមជួយជ្រោមជ្រែងគាំទ្រផង ។

ព្រះបរមរាជូបត្ថម្ភនៃព្រះរាជបល្ល័ង្ក និងការជួយជ្រោមជ្រែងនៃរាជរដ្ឋាភិបាល ចំពោះពុទ្ធិកវិទ្យាល័យ និងពុទ្ធិកមហាវិទ្យាល័យនេះ នាំឲ្យពុទ្ធិកសិក្សាមានដំណើរប្រព្រឹត្តទៅស្រួល តាំងពីអតីតកាលរហូតមកដល់ក្នុងបច្ចុប្បន្នកាលនេះ និងតទៅក្នុងអនាគតកាលទៀត ។

ដូច្នេះ, សូមឲ្យអស់លោកទាំងឡាយ បណ្តុះកតញ្ញូតាធម៌ឲ្យមាននៅក្នុងចិត្តជានិច្ច ចំពោះព្រះគុណដ៏ខ្ពង់ខ្ពស់នេះ កុំបីធ្វេសប្រហែសឡើយ ហើយខំសិក្សាឲ្យបានចេះដឹងយ៉ាងជ្រៅជ្រះ ឲ្យសមតាមពុទ្ធវចន

នៃព្រះសម្មាសម្ពុទ្ធជាព្រះបរមគ្រូផង ឲ្យសមតាមគោលបំណងនៃរាជរដ្ឋាភិបាល ដែលមានសម្ដេចព្រះប្រមុខរដ្ឋជាព្រះអគ្គមគ្គុទ្ទេសក៍ផង ។

អស់លោកតាំងឡាយជ្រាបច្បាស់ទេ ? ការសិក្សាខាងព្រះពុទ្ធសាសនានេះ កាលពីក្នុងសម័យអាណាព្យាបាលបារាំងសែស មានបន្តិចបន្តួចមិនសូវមានសេចក្ដីដុះដាលចំរុងចំរើនប៉ុន្មានទេ ។ តាំងពីប្រទេសកម្ពុជាយើងបានទទួលឋានៈជាប្រទេសឯករាជ្យឡើង សម្ដេចព្រះប្រមុខរដ្ឋកាលគង់លើព្រះរាជបល្ល័ង្កនៅឡើយ ព្រះអង្គបានលើកស្ទួយការសិក្សាខាងព្រះពុទ្ធសាសនានេះឲ្យមានកំពស់ខ្ពស់ឡើង គឺឲ្យមានពុទ្ធិកវិទ្យាល័យនិងពុទ្ធិកមហាវិទ្យាល័យជាវិទ្យាល័យ ដែលប្រកបដោយមុខវិជ្ជាខ្ពង់ខ្ពស់ ទាំងខាងព្រះពុទ្ធសាសនា ទាំងខាងផ្លូវលោក សម្រាប់កុលបុត្រជាអ្នកបួសក្នុងព្រះពុទ្ធសាសនា គឺភិក្ខុសាមណេរ បានសិក្សាឲ្យបានចេះដឹងចំណេះវិជ្ជាប្រសើរឡើង ព្រោះសម្ដេចព្រះប្រមុខរដ្ឋទ្រង់ប្រកបដោយព្រះវិចារណញ្ញាណ ឥតមានអ្នកណាប្រៀបផ្ទឹមបានឡើយ ទ្រង់ឈ្វេងយល់ឃើញថា:

១-ព្រះពុទ្ធសាសនាក្នុងប្រទេសកម្ពុជា ជាសាសនារបស់រដ្ឋពេញទី

២-ប្រជាពលរដ្ឋក្នុងប្រទេសមានចំនួន ៩៩ ភាគរយ សុទ្ធតែជាអ្នកគោរពព្រះពុទ្ធសាសនា

៣- ព្រះសង្ឃពុទ្ធសាសនិកក្នុងប្រទេសកម្ពុជា កាលពីក្នុងអតីត-

សម័យ ធ្លាប់ធ្វើជាគ្រូអាចារ្យនៃយុវកុលបុត្រ ជាកូនចៅនៃប្រជាពលរដ្ឋ តមកកិច្ចនេះ និស្ស័យនាំឲ្យប្រជាពលរដ្ឋមានគារវភក្តិចំពោះព្រះសង្ឃ ជាដរាបមក;

៤- ក្នុងសម័យបច្ចុប្បន្ននេះ ប្រទេសទាំងអស់ក្នុងលោករួមទាំងប្រទេសកម្ពុជាផង កំពុងភ្ញាក់រឭកហើយក្រោកដើរបែរមុខឆ្ពោះទៅរកវឌ្ឍនភាព ខាងចំណេះវិជ្ជាការចេះដឹង ។

៥- ព្រះសង្ឃពុទ្ធសាសនិកក្នុងប្រទេសកម្ពុជាឯករាជ្យបច្ចុប្បន្ននេះ មិនគួរនឹងបណ្ដោយឲ្យបិតនៅក្នុងសភាពល្ងង់ងងឹតឥតទីពឹងស្មានឡើយ ។ ព្រោះព្រះសង្ឃនេះធ្លាប់តែមានចំណេះចេះដឹង តែងធ្វើជាគ្រូអាចារ្យ លើគ្រហស្ថតាំងពីអតីតសម័យមក គួរតែចាត់ចែងរៀបចំបណ្ដុះបណ្ដាលឲ្យព្រះសង្ឃពុទ្ធសាសនិក មានចំណេះវិជ្ជាច្រើនឡើងខ្ពស់ឡើង កុំឲ្យអន់ថយជាងគ្រហស្ថ ដើម្បីរក្សាទុកគារវភក្តិរបស់គ្រហស្ថចំពោះព្រះសង្ឃឲ្យគង់នៅបិតថេរតទៅ ព្រោះថា បើកាលណាព្រះសង្ឃល្ងង់ខ្លៅហើយ គារវភាព និងភក្តីភាពរបស់គ្រហស្ថទាំងឡាយ នឹងលោយលេតបាត់ទៅបន្តិចម្ដង ៗ រហូតដល់អស់រលីងក្នុងពេលនោះឯង ហើយព្រះពុទ្ធសាសនានឹងត្រូវអស់ពន្លឺរស្មី គឺជាត្រូវសាបសូន្យ ។

មួយវិញទៀត ដើម្បីឲ្យព្រះសង្ឃក្នុងប្រទេសមានគុណសម្បត្តិប្រសើរ

ឡើង ដោយសារការចេះដឹងច្រើន កុំឲ្យអន់ថយជាងព្រះសង្ឃពុទ្ធ-
សាសនិកបរទេស ព្រោះប្រទេសទាំងឡាយ ឯទៀតដែលមានព្រះពុទ្ធ-
សាសនាដូចប្រទេសយើងដែរ គេបានរៀបចំបង្កើតឲ្យមានមហាវិទ្យាល័យ
ខាងព្រះពុទ្ធសាសនា សម្រាប់បណ្តុះបណ្តាលព្រះសង្ឃក្នុងប្រទេសគេ
មុនប្រទេសយើងច្រើនឆ្នាំមកហើយ ។

ដោយអាស្រ័យហេតុដូចខាងលើនេះ ទើបសម្តេចព្រះប្រមុខរដ្ឋ
ទ្រង់បានសម្រេចព្រះរាជហឫទ័យ បង្កើតឲ្យមានការសិក្សាខាងព្រះពុទ្ធ-
សាសនា ព្រមទាំងទ្រង់មានព្រះរាជបញ្ជាឲ្យរៀបចំការសិក្សានេះ ឲ្យមាន
របៀបរៀបរយល្អឡើង គឺឲ្យមានពុទ្ធិកបឋមសិក្សា ពុទ្ធិកមធ្យមសិក្សា
និងពុទ្ធិកឧត្តមសិក្សា ដូចសព្វថ្ងៃនេះ ។

អស់លោកជាសមណនិស្សិតទាំងឡាយ គប្បីដឹងឲ្យច្បាស់ម្យ៉ាង
ទៀតថា ពុទ្ធិកសិក្សាដែលកើតឡើងហើយ ប្រសិនបើខ្វះការឧបត្ថម្ភ ខ្វះ
ការជ្រោមជ្រែង ក៏មិនអាចនឹងមានជីវិតរស់នៅបានឡើយ ដែលមានជីវិត
រស់នៅហើយបានចំរើនដោយលំដាប់រហូតមកនេះ គឺប្រាកដជាដោយ
សារសេចក្តីឧបត្ថម្ភ និងការជ្រោមជ្រែងនៃរាជរដ្ឋាភិបាលសង្គមរាស្ត្រ
និយម ដែលមានសម្តេចព្រះប្រមុខរដ្ឋជាប្រធាន ក្នុងការផ្គត់ផ្គង់ឲ្យមាន
គ្រឿងសម្ភារៈ ឲ្យមានសាស្ត្រាចារ្យ និងបុគ្គលិកគ្រប់ប្រភេទ មិនឲ្យខ្វះ

ខាត ជាពិសេសទៅទៀត គឺជួយផ្តល់អាហារូបករណ៍ដល់សមណនិស្សិតទាំងឡាយ នៅពុទ្ធិកមហាវិទ្យាល័យ ព្រះសីហនុរាជ ។

អស់លោកជាសមណនិស្សិតទាំងឡាយ ប្រហែលជាធ្លាប់បានដឹងដែរ ក្នុងប្រទេសកម្ពុជាយើងនេះ តាំងពីបុរាណកាលមក មានប្រវត្តិសាស្ត្រប្រាប់យើងឲ្យដឹងច្បាស់ថា ព្រះពុទ្ធសាសនាក្តី ការសិក្សាខាងព្រះពុទ្ធសាសនាក្តី រមែងបានដុះដាលចំរើនឡើង រុងរឿងឡើង ដោយអាស្រ័យនឹងព្រះមហាក្សត្រ ។ រឿងនេះមិនមែនជារឿងព្រេងទេ គឺជារឿងពិត សឹងមានប្រវត្តិនៃពុទ្ធិកសិក្សាក្នុងបច្ចុប្បន្ននេះ ដែលបានរៀបរាប់ដោយសង្ខេបរួចមកហើយ ជាសក្ខីភាពយ៉ាងច្បាស់ទៃង ។

ដូច្នេះ, ខ្ញុំសូមរំលឹកអស់លោកទាំងឡាយ សូមកុំឲ្យធ្វេសប្រហែសឲ្យខំយកចិត្តទុកដាក់ក្នុងការរៀនសូត្រ បើទុកជាជួបប្រទះនឹងឧបសគ្គខ្លះក្នុងពេលកំពុងសិក្សា ក៏ត្រូវខំប្រឹងអត់ធន់ ហើយតស៊ូពុះពារឧបសគ្គនោះឲ្យគ្រាតែបានសម្រេចដល់អវសាននៃការសិក្សា ដើម្បីនឹងបានបំពេញករណីយកិច្ចរបស់ខ្លួន ដែលជាកិច្ចតបឧបការគុណ ចំពោះព្រះពុទ្ធសាសនា ចំពោះព្រះរាជបល្ល័ង្ក និងចំពោះរាជរដ្ឋាភិបាល ដែលអស់លោកទាំងឡាយបានជ្រកកោន បានពឹងផ្អែករួចមកហើយ ឲ្យសមដល់ឋានៈរបស់ខ្លួនជាសមណៈ និងជាកតញ្ញូបុគ្គល ។

ក្រៅពីនេះ មានកិច្ចម្យ៉ាងទៀត ដែលអស់លោកទាំងឡាយត្រូវយកចិត្តទុកដាក់គឺអនាគតនៃព្រះពុទ្ធសាសនា ។ អនាគតនៃព្រះពុទ្ធសាសនានោះ នឹងជាភារៈលើអស់លោកទាំងឡាយ ជាយុវសមណនិស្សិត ។ សូមអស់លោកទាំងឡាយ កុំបណ្ដោះគំនិតលាក់លៀមគិតដោះខ្លួនចេញពីព្រះពុទ្ធសាសនាឡើយ ព្រោះព្រះពុទ្ធសាសនា បើតាមធម្មតានឹងតាមការពិត នឹងត្រូវការប្រគល់អនាគតដល់អស់លោកទាំងឡាយដែលជាយុវសមណៈ ហើយជាអ្នកសិក្សាមានចំណេះចេះដឹងអាចនឹងទទួលភារៈនេះបាន ។

នៅអវសាននេះ អាត្មាភាពសូមរំលឹកនូវគុណនៃព្រះរតនត្រ័យ ហើយសូមអានុភាពនៃព្រះពុទ្ធសាសនា ជួយអភិបាលរក្សាសម្ដេចព្រះមហាក្សត្រិយានីជាព្រះមាតាជាតិ នឹងសម្ដេចព្រះប្រមុខរដ្ឋ សូមទ្រង់បានប្រកបដោយសុខសួស្ដីនឹងជ័យមង្គលគ្រប់ប្រការ អស់កាលជានិច្ចនិរន្តរតរៀងទៅ ដើម្បីនឹងបានជាម្លប់ជាទីជ្រកកោននៃពុទ្ធសាសនិកជនទាំងឡាយ នឹងប្រជាពលរដ្ឋទៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ម្យ៉ាងទៀត ដោយតេជានុភាពនៃព្រះរតនត្រ័យ សូមសម្ដេចព្រះសង្ឃនាយកទាំងពីរព្រះអង្គ ព្រះរាជាគណៈនុរង្ស ឥស្សរជនទាំងឡាយ នឹងពុទ្ធបរិស័ទទាំងឡាយ បានបិតទៅក្នុងសេចក្ដីសុខ-ចំរើនអស់កាលជានិច្ច

គេរៀនទៅកុំបីឃ្លៀងឃ្លាតឡើយ ។

លុះចប់សូត្រគាថាព្រះពោធិវង្សហើយ, ទើបសម្ដេចព្រះមហាក្សត្រិយានី ទ្រង់ប្រគេនព្រហ្មទានទី ១ ចំពោះព្រះមហា ឃួន-ពីន សមណនិស្សិត ពុទ្ធិកមហាវិទ្យាល័យព្រះសីហនុរាជ ថ្នាក់ទី ២ រួចទើបព្រះតេជព្រះគុណព្រះពោធិវង្ស អគ្គាធិការពុទ្ធិកសិក្សា បានសូត្រព្រះនាមព្រះសង្ឃទាំង ១៣១ រូប ដែលត្រូវទទួលព្រហ្មទាន ។

លំដាប់តមក, ព្រះសង្ឃសូត្រជយន្តោ និងអនុមោទនាគាថាតាមគួរជាកិច្ចបង្ហើយបុណ្យ ។

ម៉ោង ១០ ព្រឹក សម្ដេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូងទ្រង់ស្ដេចព្រះរាជនិវត្តន៍ទៅព្រះបរមរាជវាំងវិញ ។

រួច, ទើបសហជីវិន ឈឹម-ស៊ុមន៍ សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ʻ បានសូត្រតាលប័ត្រឲ្យឥស្សរជនមានម្ចាស់ព្រហ្មទានជាដើមប្រគេនសមណនិស្សិតទាំង ១៣០ រូបដែលនៅសល់ពុំទាន់ប្រគេន ។

ពិធីបុណ្យនេះបានបញ្ចប់នៅម៉ោង ១១ គត់ ។

# វចនានុក្រមសំស្ក្រឹត-ខ្មែរ

(តមក)

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

---

អតិនិៈគ្ឃ គុ. ដែលមានសំឡេងមិនមានរោះយក្រៃលែង, ដែលមិនមានសំឡេងសោះ, ដែលស្ងាត់ស្ងួនស្ងៀមឈឹង ។

អតិនិៈគ្ស៊ ធាតុ. ដកដង្ហើមញាប់ ។

អតិនិប្កុរណោ គុ. ដែលឥតមានករុណាក្រៃពេក ។

អតិនិប្ណូត គុ. ដែលល្បងមើលនោយក្រៃលែង, ដែលជំនាញណាស់ ។

អតិនិហ្នុ ធាតុ. បដិសេធក្រៃលែង, ទាត់ចោល ។

អតិនី ធាតុ នាំចេញក្រៃលែង. ស្រោចស្រង់ ។

អតិនីបេស៊ ក្រិ. វិ. តូចក្រៃពេក, ទាបក្រៃពេក ។

អតិនេទិ, ធាតុ. ពេញក្រៃពេក, ពេញព្រៀប ។

អតិបដិយាំស៊ គុ. ដែលវៀងវៃដាងក្រៃពេក, ដែលរស់រវើកដាង ។

អតិបឋ៊ ធាតុ. និយាយលើក, សរសើរ ។

អតិបត៊ ធាតុ. ធ្លាក់ក្រៃពេក, ហោះហើរ, ១កខាន,ស្កុន ប្រព្រឹត្តទុច្ចរិត ។

អតិបទ៊ ធាតុ. ប្រមាទ, ប្រហែស, ទុប ។

(នៅមានត)